# អរិយសច្ចកថា

របស់ព្រះសពមហាវិមលធម្ម នាមដើម ថោង
ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ
ប្រែ និង រៀបរៀងទុក

ព្រះសពព្រះឧត្តមមុនី **អ៊ុម-ស៊ូរ**
អធិបតីរងក្រុមជំនុំប្រែព្រះត្រៃបិដក ក្នុងពុទ្ធសាសនបណ្ឌិត នៅព្រះរាជបណ្ណាល័យកម្ពុជា

បានចម្លងជូនព្រះរាជបណ្ណាល័យបោះពុម្ពផ្សាយ
គណៈរដ្ឋមន្ត្រី និង សម្តេចសង្ឃនាយកទាំងពីរគណៈ
បានអនុញ្ញាតិហើយ

លេខ១៣៦អឺ០ ចិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

ព.ស. ២៥៤១ គ.ស. ១៩៩៨

អភ័យ សប្ទុក, ថា

# របស់ព្រះសពព្រះមហាវិមលធម្ម ឆាមដើម ហោង

នាយកសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ ប្រែនិងរៀបរៀងទុក

## ព្រះសពព្រះឧត្តមមុនី អ៊ុម-ស៊ូរ

អធិបតីរងក្រុមជំនុំប្រែព្រះត្រៃបិដក ក្នុងពុទ្ធសាសនបណ្ឌិត្យ

នៅព្រះរាជបណ្ណាល័យកម្ពុជា បានចំឡងជូនព្រះរាជបណ្ណាល័យបោះពុម្ពផ្សាយ

តាមអ្នកដែលត្រូវការ

គណៈរដ្ឋមន្ត្រី និងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

លើកទី ៤ វ ១៤ ពាន់

BIBLIOTHÈQUE ROYALE DU CAMBODGE

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៩៤

# ARIYASACCAKATHĀ

TEXTE REVU ET CORRIGÉ

PAR LE FEU

VÉNÉRABLE PRÉAS UTTAMAMUNÎ (OUM-SOU)

ACHAR A LA BIBLIOTHÈQUE ROYALE

D'APRÈS

LA TRADUCTION ORIGINALE ET LES COMMENTAIRES

DU FEU

VÉNÉRABLE PRÉAS MAHÂ VIMALADHAMMA (THONG)

FEU DIRECTEUR DE L'ÉCOLE SUPÉRIEURE DE PÂLI DU CAMBODGE

Cette publication a reçu l'approbation du Conseil des Ministres
et des deux Chefs de Secte

Quatrième Édition, 14e mille.

PHNOM-PENH
ÉDITIONS DE LA BIBLIOTHÈQUE ROYALE
1941

# មាតិកាធម៌


| | ទំព័រ | បន្ទាត់ |
|---|---|---|
| សេចក្ដីផ្ដើម.......................... | ៧, | |
| **ទុក្ខអរិយសច្ច**................ | ១៥, | ១ |
| សំដែងអំពីជាតិទុក្ខ......................... | ១៦, | ១០ |
| សំដែងអំពីជរាទុក្ខ......................... | ២០, | ១៣ |
| សំដែងអំពីព្យាធិទុក្ខ......................... | ២២, | ១០ |
| សំដែងអំពីមរណទុក្ខ......................... | ២២, | ១៦ |
| សំដែងអំពីសោកទុក្ខ......................... | ២៥, | ១ |
| សំដែងអំពីបរិទេវទុក្ខ......................... | ២៥, | ៤ |
| សំដែងអំពីទុក្ខទុក្ខ......................... | ២៥, | ៧ |
| សំដែងអំពីទោមនស្សទុក្ខ......................... | ២៥, | ១០ |
| សំដែងអំពីឧបាយាសទុក្ខ......................... | ២៥, | ១៣ |
| សំដែងអំពីអប្បិយេហិសម្បយោគទុក្ខ................ | ២៦, | ១ |
| សំដែងអំពីបិយេហិវិប្បយោគទុក្ខ................ | ២៦, | ៤ |
| សំដែងអំពីយម្បិច្ឆំនលភតិទុក្ខ................ | ២៧, | ១ |
| សំដែងអំពីបញ្ចុបាទានក្ខន្ធទុក្ខ................ | ២៧, | ៧ |
| អត្ថនៃទុក្ខសច្ច......................... | ៣០, | ៧ |

ទំព័រ បន្ទាត់


## សមុទយអរិយសច្ច................ ៣៣, ១០

សំដែងអំពីតណ្ហា ១០៨.................... ៣៦, ៦

អត្ថនៃសមុទយសច្ច...................... ៣៩, ១១

## ទុក្ខនិរោធអរិយសច្ច............ ៤១, ១៣

អាយតន ១២ ជាទីប្រជុំនៃតណ្ហា................ ៤៤, ៧

ពាក្យបុច្ឆាអំពីនិព្វាន.................... ៤៦, ១៥

អត្ថនៃនិរោធសច្ច...................... ៧១, ១

## មគ្គសច្ច............... ៨៣, ៣

អង្គអរិយមគ្គទី ១...................... ៨៦, ១៣

អង្គអរិយមគ្គទី ២...................... ៨៧, ៦

អង្គអរិយមគ្គទី ៣...................... ៨៧, ៨

អង្គអរិយមគ្គទី ៤...................... ៨៧, ១៧

អង្គអរិយមគ្គទី ៥...................... ៨៩, ៧

អង្គអរិយមគ្គទី ៦...................... ៨៨. ១៣

អង្គអរិយមគ្គទី ៧...................... ៨៩, ៦

អង្គអរិយមគ្គទី ៨...................... ៩០, ១៩

សំដែងដោយសមាធិ ៣.................... ៩១, ១៤

អត្ថនៃមគ្គសច្ច........................ ១០០, [illegible]

សម្មាទិដ្ឋិជាលោកិយ.................... ១០២, ១៦

| | ទំព័រ | បន្ទាត់ |
|---|---|---|
| សម្មាសង្កប្បជាលោកិយ . . . . . . . . . . . . . . . . . . . . . . | ១០៧, | ៨ |
| សម្មាវាចាជាលោកិយ . . . . . . . . . . . . . . . . . . . . . . . . | ១១០, | ៩ |
| ព្រះសម្ពុទ្ធទ្រង់ទេសនារឿងភរិយា ៧ ចំពួក . . . . . . . . . . . . . . | ១១១, | ៨ |
| សម្មាកម្មន្តជាលោកិយ នឹងវិរត្តិ ៣. . . . . . . . . . . . . . . . . | ១១៥, | ១០ |
| សម្មាអាជីវជាលោកិយ នឹងភាណិជ្ជ ៥ . . . . . . . . . . . . . . . . | ១២០, | ៥ |
| សម្មាវាយាមជាលោកិយ . . . . . . . . . . . . . . . . . . . . . . . | ១២១, | ១ |
| សម្មាសតិជាលោកិយ . . . . . . . . . . . . . . . . . . . . . . . . | ១២៧, | ១៩ |
| សម្មាសមាធិជាលោកិយ . . . . . . . . . . . . . . . . . . . . . . . | ១២៩, | ១៣ |
| ធម្មចក្កមានប្រភេទ ២. . . . . . . . . . . . . . . . . . . . . . . . | ១៣១, | ៥ |

# សេចក្ដីផ្ដើម

កាលដែលខ្ញុំបានទទួលការជាអ្នករៀបរៀងធម៌អរិយសច្ចកថានេះ ហើយ ខ្ញុំបានទៅជ្រើសរើសគេធម៌ដែលព្រះតេជព្រះគុណមហាវិមលធម្ម (ថោង) តាំងហ្វាងសាលាបាឡីជាន់ខ្ពស់ លោកបានប្រែនិងរៀបរៀងព្រាង ទុកជាសំណៅតាំងពីប៉ុន្មាន ក្នុងកាលដែលលោកមានសង្ខារាយុនៅឡើយ គឺបានឃើញសេចក្ដីសំណៅធម៌ (អរិយសច្ចកថា) នេះជាការស្នាដៃរបស់លោក ខ្ញុំក៏មានសេចក្ដីសោមនស្សដោយក្រៃលែងដោយស្ថានបីយ៉ាង គឺ

១ – ព្រោះគិតថា ឧបាសិកា ឌួ ដែលមានសេចក្ដីប្រាថ្នានឹងបោះពុម្ពធម៌នេះ ចែកជាធម្មទាន នោះនឹងបានសម្រេចដោយឆាប់ហើសតាមសេចក្ដីប្រាថ្នា

២ – ខ្លួនខ្ញុំដែលជាអ្នកទទួលការរៀបរៀងធម៌នេះ ក៏នឹងមិនមានកង្វល់ដោយគិតចូននឹងរៀបរៀងធម៌នេះឡើយ ជាហេតុនាំឲ្យខ្ញុំបានចំណេញពេលនឹងរៀបរៀងធម៌ឯទៀតៗ ជាប្រយោជន៍ទៅខាងមុខ

៣ - ព្រោះយល់ឃើញថា ធម៌នេះកើតឡើងដោយស្នាដៃរបស់ព្រះតេជព្រះគុណ ព្រះមហាវិមលធម្ម ដែលជាធម្មាចារ្យរបស់យើងខ្ញុំ ដែលលោកទំរៀបរៀងដោយសេចក្តីព្យាយាមដ៏មាំ ដើម្បីឲ្យកើតប្រយោជន៍ដល់សាសនិកជនអ្នកត្រូវការនឹងប្រតិបត្តិតាម មិនទាន់បានសម្រេច ក៏មានមរណសង្គ្រាមមកផ្តាច់សេចក្តីព្យាយាមនោះ លោកក៏មិនអាចនឹងតទល់នឹងមរណសង្គ្រាមនោះបាន ទើបលោកនិមន្តចេញអំពីលោកនេះ ទៅកាន់លោកខាងនាយទៅ ។

គួរខ្ញុំនឹងជួយបន្តសេចក្តីព្យាយាមរបស់លោកឲ្យបានសម្រេចតាមសេចក្តីប្រាថ្នាដើមរបស់លោក ។

ទើបខ្ញុំបានតាក់តែងឲ្យសរសេរចំលង ជារបៀបក្បួនល្មមនឹងយកទៅបោះពុម្ពបាន លុះឲ្យចម្លងរួចហើយក៏បានយកទៅជូនម៉ាដឹមូអាហ្សែល ការប៉ឺឡែស ជាអ្នកគ្រប់គ្រងព្រះរាជបណ្ណាល័យតាមសេចក្តីត្រូវការ ។

ឯសេចក្តីធម៌នេះដែលព្រះតេជព្រះគុណ មហាវិមលធម្មលោកបានប្រែរៀបរៀងឡើងនោះ លោកប្រែពីគម្ពីរបាឡីណា ខ្ញុំមិនអាចដឹងប្រាកដ ព្រោះធម៌អរិយសច្ចនេះមាននៅក្នុងគម្ពីរដោយច្រើន តែបានពិនិត្យសេចក្តីទៅឃើញថាប្រហែលជាលោកប្រែចេញមកពីគម្ពីរសារត្ថសមុច្ចយអដ្ឋកថាភាណវារ ជាគម្ពីរអធិប្បាយសេចក្តីធម្មចក្កប្បវត្តនសូត្រ ។

ទៅទីបំផុតនេះ សូមអស់លោកអ្នកដែលជាសប្បុរសទាំងឡាយដែលមានសទ្ធាបានសិក្សារៀនធម៌អរិយសច្ចកថានេះហើយ សូមតាំងមេត្តា

ចិត្តផ្សាយចំណែកបុណ្យដល់លោកដែលបានរៀបរៀងធម៌នេះ ហើយនិមន្ត

ទៅកាន់បរលោកហើយនោះផង តាមកំឡាំងសទ្ធាតិចច្រើន តែកុំចូលចិត្ត

ប្តូរចិត្តជាក្រែងផ្សាយចែកផលបុណ្យទៅហើយ នឹងនាំឲ្យខាតផលដើម

របស់ខ្លួននោះមិនមែនដូច្នោះទេ គឺនឹងរឹងរិតតែកើនចំរើនផលនោះទ្វេឡើង

ជា ១០០ គុណ ១០០០ គុណវិញ ប្រៀបដូចជាអ្នកប្រាប់លេខប្រាប់អក្សរ

ឬបង្រៀនធម៌អាថ៌ដល់អ្នកទាំងពួង ធម្មតាអ្នកប្រាប់លេខ ប្រាប់អក្សរ នឹង

ធម៌អាថ៌គេនោះ មិនមែនវិជ្ជាទាំងនោះរបូតចេញពីមាត់ឬពីសន្តានចិត្តរបស់

ខ្លួននោះអស់ទេ គឺរឹងរិតតែចូលចិត្តជាថែមទៀត ជាកំឡាំងច្រើនជាងមុន

ពុំនោះសោត ប្រៀបដូចអ្នកដែលឲ្យគេបន្តភ្លើង ពះភ្លើងទៀន ។ ឬពីបទីប

របស់ខ្លួននោះឯង ។ល។—

ព្រះឧត្តមមុនី អ៊ុម-ស៊ូរ

អធិបតីនៃក្រុមជំនុំប្រែព្រះត្រៃបិដក ក្រុងភ្នំពេញ

# អរិយសច្ចកថា

គ្រានេះនឹងបានសែដ្ឋាក្នុងចតុរារិយសច្ចទាំង ៤ គឺ

១ ទុក្ខអរិយសច្ច ២ សមុទយអរិយសច្ច

៣ និរោធអរិយសច្ច ៤ មគ្គអរិយសច្ច

តាមលំនាំគាថាដែលអង្គសម្តេចព្រះសព្វពេជ្ញសម្មាសម្ពុទ្ធជាម្ចាស់ ត្រាស់ទេសនាប្រោសបញ្ចវគ្គិយភិក្ខុទាំង៥អង្គ មានព្រះអញ្ញាកោណ្ឌញ្ញ ជាប្រធាន មួយអន្លើនឹងពពួកព្រហ្មទាំង ១៨ កោដិ ក្នុងព្រៃឥសិបតនមិគទាយវន ទៀបក្រុងពារាណសីកជនទី នឹងសំដែងជានិទ្ទេសក់រ ។

កាលអង្គសម្តេចព្រះគតវត្តមុនីទ្រង់ត្រាស់ទេសនានោះជាគថេតុកម្យតាបុគ្គាដូច្នេះថា ឥត្ថុការតម្ពា ជាតិបិ ទុក្ខា ជរាបិ ទុក្ខា ព្យាធិបិ ទុក្ខា មរណម្បិ ទុក្ខំ សោកបរិទេវទុក្ខទោមនស្សុបាយាសាបិ ទុក្ខា អប្បិយេហិ សម្បយោគោ ទុក្ខោ បិយេហិ វិប្បយោគោ ទុក្ខោ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ

សំខិត្តេន បញ្ចុបាទានក្ខន្ធាបិ ទុក្ខា អធិប្បាយសេចក្ដីក្នុងទុក្ខស ច្ចថា ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ កងទុក្ខដែលតថាគតសំដែងថារមែង បៀតបៀនសត្វឲ្យលំបាកវេទនាជានិច្ចជានិរន្តរ៍មិនចេះដាច់ មិនចេះឈប់ មិនចេះល្ហែនោះ តើទុក្ខដូចម្ដេចខ្លះ ភិក្ខវេ ម្នាលភិក្ខុទាំងឡាយទុក្ខមាន ១៣ កង គឺ ជាតិទុក្ខកងទី ១ ជរាទុក្ខកងទី ២ ព្យាធិទុក្ខកងទី ៣ មរណទុក្ខ កងទី ៤ សោកទុក្ខកងទី ៥ បរិទេវទុក្ខកងទី ៦ ទុក្ខទុក្ខកងទី ៧ ទោមនស្ស ទុក្ខកងទី ៨ ឧបាយាសទុក្ខកងទី ៩ អប្បិយេហិសម្បយោគទុក្ខកងទី ១០ បិយេហិវិប្បយោគទុក្ខកងទី ១១ យម្បិច្ឆំនលភតិទុក្ខកងទី ១២ បញ្ចុបាទាន ក្ខន្ធទុក្ខកងទី ១៣ ។

ឯជាតិទុក្ខនោះ គឺទុក្ខដែលកើតដល់សត្វទាំងឡាយទាំងពួង តាំងពីបដិសន្ធិក្នុងកំណើតទាំង ៤ គឺ អណ្ឌជកំណើត តាំងប្ដើមបដិសន្ធិក្នុងពងជាមុនហើយទើបបានញាស់ចេញជាកូនខាងក្រោយ ២ ជលាម្ពុជកំណើត តាំងបដិសន្ធិក្នុងគភ៌មាតាដូចយើងរាល់គ្នា ៣ សំសេទជកំណើត កើតអំពីចំហាយញើសក្ដៅដូចយ៉ាងសត្វកណ្ដូបកណ្ដៀរ សោនឆ្កួតមូសជាដើម ៤ ឧបបាតិកកំណើត បានដូចទេពកំណើត គឺកំណើតទេវតា តាំងពីបដិសន្ធិកើតឡើងស្រាប់តែធំតែម្ដង ប្រមាណវ័យខ្លួនការប្រហែលមនុស្សមានអាយុ ១៦ ឆ្នាំ មានគ្រឿងអាភរណប្រដាប់ប្រដាដ៏បរិបូណ៌ គឺឧបបាតិកកំណើតនេះមិនតែទេវតាទេ ទុកជាមនុស្សក៏មានខ្លះដែរ ដូចយ៉ាងនាងអម្ពបាលិកាជាស្រីពេស្យាក្ដាមាស ទីនព្រាហ្មណ៍ឈ្មោះបោក្ខរសាតិ ជាតិទុក្ខនេះឯងគ្រប់រូបសត្វ បៀតបៀនសត្វឲ្យបានសេចក្ដីទុក្ខវេទនាមិនរើសមុខថាជារូបណាជា

ប្រូណាស់ឯដូចគ្នាទាំងអស់ ជាហេតុឲ្យវិលវល់វិលមក យកកំណើតក្នុង ផ្ទៃសំសារមិនចេះចប់ មិនចេះផុត មិនចេះឈប់ឈរ សព្វជាតិសព្វភព ឥតគណនា រាប់មិនបាន ហេតុនោះ បានជាតថាគតឲ្យឈ្មោះថាជាតិទុក្ខ សត្វដែលចាប់បដិសន្ធិក្នុងគភ៌នោះ មានអាយតនបរិបូណ៌ខ្លះ មិនបរិបូណ៌ខ្លះ សត្វដែលជាសំសេទជ បដិសន្ធិអំពីចំហាយញើសក្អែលនោះក្តី សត្វដែល យកបដិសន្ធិជាឧបបាតិកក្តី គឺសោយជាតិទុក្ខលើសលុបដូចគ្នាទាំងអស់ សត្វដែលកើតជាជលាម្ពុជដែលបដិសន្ធិក្នុងគភ៌មាតានោះ គឺរមែងសោយ នូវជាតិទុក្ខច្រើនជាងឆ្មិតា ដូចមានព្រះបាលីថា

បឋមំ កលលំ ហោតិ កលលា ហោតិ អព្ពុទំ
អព្ពុទា ជាយតេ បេសិ បេសិយា ជាយតេ ឃនោ
ឃនា ជាយន្តិ សាខាយោ កេសា លោមា នខាបិ ច

សត្វទាំងឡាយដែលយកបដិសន្ធិក្នុងគភ៌មាតានោះ កាលដំបូងជា កលលនៅតូចណាស់ក្រៃលែងណាស់ មានប្រមាណប៉ុនដំណក់ប្រេងល្ងាដ៏ឆ្មារ ល្អិតជាបរិមាណូ ដែលជាប់នៅចុងរោមទ្រាយចាមរ៍ មានពណ៌ថ្លា ដូចសប្បិ រស់នៅបាន ៧ ថ្ងៃទី ១ ។ គឺប្រែជាអព្ពុទ គឺមានពណ៌ដូចទឹក លាងសាច់ នៅបាន ៧ ថ្ងៃទី ២ ។ ទើបកើតជាដុំសាច់នៅបាន ៧ ថ្ងៃ ទី ៣ ។ គឺប្រែហាប់ណែនជាដុំរឹងមានសណ្ឋានដូចជាពងមាន់ក្នុងផ្ទៃ មេមាន់ នៅបាន ៧ ថ្ងៃទី ៤ ។ គឺបែកចេញជាបញ្ចសាខា គឺមែក ៥ ក្បាល ១ ដៃ ២ ជើង ២ នៅបាន ៧ ថ្ងៃទី ៥ ។ ទើបកើតសក់រោម ក្រចក ស្បែកតទៅ តាមតោ បន្ទាយ ចាប់ដើមតាំងអំពីកាលនោះមក

គឺតាំងតែសោយទុក្ខវេទនានៅក្នុងទ្វារមាតានោះពន់ពេកក្រៃ រកអ្វីទីទុ-ចទាម៉ិនបាន អគ្គិយសង្កត់លើអាហារចាស់ ក្បាលទូលអាហារថ្មីនៃមាតា អគ្គិយប្រហោង ដៃទាំង ២ ទប់ផ្គងនឹងផ្ទប់ចង្កា បែរខ្នងទៅខាងផ្ទៃមាតា បែរមុខទៅខាងឆ្អឹងខ្នងមាតា ដូចជាស្វាអគ្គិយនៅក្នុងប្រហោងឈើ នៅវេលាដែលមានភ្លៀងធំនោះឯង ក្រពះសុករុំហ៊ុមកាយទារកតែគ្រប់មិនអាចសណ្តូកលាតដៃលាតជើងចេញបាន សោយទុក្ខវេទនានៅក្នុងទ្វារប្រទេសនៃមាតា ធ្ងន់ពន់ប្រមាណណាស់ ទុក្ខស្មើនឹងសត្វដែលសោយទុក្ខនៅក្នុងស្ថាននរក ដ៏ងងឹតងងល់ចល់ទុក្ខវេទនា មានតែក្លិនអសុភគាប់អួនៅក្នុងផ្ទៃមាតា គួរគប្បីខ្ពើមរអើមជាទីបំផុត ទាំងគេជាធាតុមាតាដុតកំដៅក្តៅទុរន់ពន់ប្រមាណ ប្រដូចជាដុំសាច់ដែលបុគ្គលចំហុយនៅក្នុងឆ្នាំង សត្វទាំងឡាយដែលនៅក្នុងគភ៌មាតាសោយទុក្ខវេទនាជាទម្ងន់យ៉ាងនេះ រួចគ្នាទាំងអស់ សេចក្តីទុក្ខយ៉ាងនេះឈ្មោះថា គព្ភក្កន្តិកមូលកទុក្ខ បានជាជាតិទុក្ខជាបឋមប្រការ ១ ដោយប្រការដូច្នេះ ។

មួយវិញទៀត បើមាតាដើរទៅហើយភ្លាត់ដួលចុះក្តី ប្រែត្រឡប់ខ្លួនក្រោកឡើងអង្គុយចុះក្តី សត្វដែលនៅក្នុងគភ៌នោះ ភ្ញាក់តក់ស្លុតរន្ធត់ខ្លាំង សោយទុក្ខវេទនាជាកំឡាំងណាស់ ទុក្ខយ៉ាងនេះឈ្មោះថា គព្ភបរិហារមូលកទុក្ខ បានជាជាតិទុក្ខជាគំរប់ ២ ។

មួយទៀតទុក្ខឯណា កាលដែលសត្វនៅក្នុងគភ៌មាតា ដេកទទឹងក្នុងផ្ទៃមាតាសម្រាលចេញមិនរួច សោយទុក្ខវេទនាជាទម្ងន់ពន់ប្រមាណ ទុក្ខ

មួយទីសោតកាលបើខ្យល់កម្មជវាត បក់ត្រឡប់សត្វគភ៌ក្នុងផ្ទៃមាតា ជើងឡើងលើ ក្បាលចុះខាងក្រោម ធ្លាក់ចុះទៅតាមទ្វារ កំណើតដូចជាបុគ្គលធ្លាក់ចុះទៅក្នុងជ្រោះកំពង់ជ្រៅពន្លឹក ត្រូវខ្ទាចត្រូវគក់សង្កត់ខ្នងខ្លាំង កាលដែលចេញពីទ្វារយោនីនោះក៏សែនទុក្ខសែនលំបាកវេទនាខ្លាំង ដូចជាដំរីសារចេញពីប្រហោងគាល់ ទុក្ខយ៉ាងនេះឈ្មោះថា គព្ភជាយិកមូលកទុក្ខ ចាត់ជាជាតិទុក្ខជាគំរប់ ៤ ។

មួយទៀតកាលបើទារកសម្រាលចេញពីផ្ទៃមាតាមកហើយ បុគ្គលទទួលយកទៅដំរះមន្ទិលជុសលាង ឈឺផ្សារហាក់ដូចជាចាក់ដោយម្ជុលទីង ធ្លុតដោយមុខកំបិតដែលមុត ឈឺផ្សារសព្វសរីរកាយ ទុក្ខនេះឈ្មោះថា គព្ភ-និក្ខមនមូលកទុក្ខ ចាត់ជាជាតិទុក្ខជាគំរប់ ៥ ។

មួយទៀតចាប់ដើមតាំងពីទារកនោះកើតចំរើនវ័យវឌ្ឍនាការឡើង ជួនកាលបុព្វកម្មអំពើដើមឯណាមួយជិតដោយតាមមកឲ្យផលឲ្យដល់នូវទោសទុក្ខ ត្រូវគាំងចាប់ចងត្រូវពិន័យយកយ៉ាងត្រូវគុកត្រូវច្រវាក់ខ្នោះឃ្នាងគាង ក៏ងក៏មាន ត្រូវទោសដល់ជីវិតក៏មាន ជួនកាលសម្លាប់ខ្លួនឯងក៏សឹងមាន ទុក្ខយ៉ាងនេះឈ្មោះថា អត្តូបក្កមមូលកទុក្ខ ចាត់ជាជាតិទុក្ខជាគំរប់ ៦ ។

មួយទៀតទុក្ខឯណាដែលកើតមកជាមនុស្សហើយៗ ត្រូវគ្រឿងសា-ស្ត្រាវុធអ្នកដទៃប្រហារក្តី ត្រូវប្រួលដោយធនូសាត្តី ទុក្ខយ៉ាងនេះឈ្មោះថា បរូបក្កមមូលកទុក្ខ ចាត់ជាជាតិទុក្ខជាគំរប់ ៧ ។

មួយទៀតបណ្ដាទុក្ខទាំងពួងដែលកើតមានដល់បុគ្គលដែលកើតមកក្នុងលោកសព្វសត្វគ្រប់រូប អាស្រ័យនឹងមានជាតិជាបច្ច័យ ទុកជាសត្វនរកសោយទុក្ខវេទនាផ្សេងៗ មានភ្លើងឆេះខ្លាចរំលាយនោះ ក៏ព្រោះតែមានជាតិជាបច្ច័យឲ្យបដិសន្ធិឈ្មោះថា អត្តុបក្កមមូលកទុក្ខ រាប់ជាជាតិទុក្ខជាគំរប់ ៨ ។

មួយទៀតសត្វទាំងឡាយ ទុកជាសត្វតិរច្ឆាននោះក្ដីដែលសោយទុក្ខវេទនាលំបាកដោយបុគ្គលដទៃបៀតបៀនមានវាយដំចាក់កាប់សម្លាប់ជីវិតជាដើមនោះ ក៏ព្រោះតែជាតិជាបច្ច័យឲ្យបដិសន្ធិក្នុងតិរច្ឆានកំណើត គឺរាប់ជាជាតិទុក្ខជាគំរប់ ៩ ។

មួយទៀតសត្វដែលកើតក្នុងប្រេតវិស័យនោះៗ ក្ដី ដែលសោយទុក្ខវេទនាអត់សេចក្ដីស្រេកឃ្លានទ្រាំខ្យល់ ទ្រាំកំដៅជាដើម គឺរាប់ជាជាតិទុក្ខជាគំរប់ ១០ ។ ជាតិទុក្ខសំដែងតាមពុទ្ធាធិប្បាយមានប៉ុណ្ណេះ ។

ឯជរាទុក្ខនោះព្រះអង្គទ្រង់សំដែងជានិទ្ទេសវារថា កិត្តាវេ ម្នាលភិក្ខុទាំងឡាយ ជរាឯណាដែលព្រះតថាគតទេសនាទុកក្នុងនិទ្ទេសវារ ជរានោះមានសភាពដូចម្ដេច ៗ ជរាឯណាដែលមានសភាពធ្វើឲ្យរន្ធើយគ្រាំគ្រាវិកលវិការវិបរិតប្រែប្រួលទៅផ្សេងៗ មានធ្មេញបាក់ សក់ស្កូវ ជ្រាល់ផតសាច់ស្បែកជ្រួញញ្ញយុលយារស្វិតក្នកងនិងត្រចៀកថ្លង់ជាដើម គូទង សរន្ធិតរូបកាយនេះ - ជរានោះព្រះតថាគតហៅថា ជរាទុក្ខ ជរានេះបុគ្គលទាំងឡាយមិនអាចនឹងប្រមើលមើលឃើញដោយមំសចក្ខុទេ លុះតែបុគ្គលដែលប្រកបដោយបញ្ញាចក្ខុនោះ ទើបនឹងសំឡឹងឃើញច្បាស់ប្រាកដពិត

បាន ជរានេះប្រៀបគួរនាដូចភ្លើងដែលឆេះព្រៃហើយរលត់ទៅ ភ្លើងនោះក៏មិន
បានប្រាកដការដែលឆេះ ស្រាប់តែនៅតែផេះនឹងធ្យូងខ្មៅប្រាកដដល់
ជនទាំងឡាយ នេះមានឧបមាដូចម្ដេចមិញ ជរារូបនេះក៏មិនបានប្រាកដ
ដល់ជនទាំងឡាយដូច្នោះឯង បុគ្គលបានឃើញធ្មេញបាក់ សក់
ស្កូវ ព្រាលផតគ្គី ឃើញសាច់ស្បែកស្វិតជ្រីវជ្រួញយុលយារក្នុកនិត
ត្រចៀកថ្លង់ភ្នែកទើបដឹងថាសេចក្ដី ជរាមកដល់ប្រាកដ ពុំនោះសោតសេចក្ដី
ជរានោះដូចជាទឹកជម្រាញ ក៏ស្រែអ្នកគង្វាលជម្រាញនោះ ហូរត្រលប់ទៅ
មកម្ដងមួយសារ ៗ ខាងមុខកាន់តែតិចទៅ ៗ ខាងក្រោយកាន់តែ
ច្រើនឡើង ៗ នោះមានឧបមាដូចម្ដេចមិញ ជរាដែលលេបអាយុសត្វ
បន្តិច ៗ រាល់កាលរាល់វេលាមិនឈប់មិនឈរបន្តិចពេលណា ខណៈណា
សោះនោះ ក៏មានឧបមេយ្យដូច្នោះឯង អធិប្បាយថាអ្នកដែលកើតមកជា
មនុស្សមានអាយុវ័យកំណត់១០០ ឆ្នាំ លុះកន្លងថ្ងៃ ១ ទៅក៏ខូចអំពីកំណត់
១០០ឆ្នាំ ១ ថ្ងៃ នៅតែ ៩៩ ឆ្នាំ ១១ខែ ២៩ ថ្ងៃ លុះកន្លងទៅបាន ១ ខែក៏
ខូចអំពី ១០០ ឆ្នាំ ១ ខែ នៅតែ ៩៩ ឆ្នាំ ១១ ខែ លុះកន្លងទៅបាន ១ ឆ្នាំ
ក៏ខូចអំពី ១០០ ឆ្នាំ នៅតែ ៩៩ ឆ្នាំ ក៏សេចក្ដីជរាបណ្ដាញបំបាត់អាយុ
សត្វគៀនបញ្ចូលទៅរកសេចក្ដីមរណៈជានិច្ច សព្វថ្ងៃសព្វព្រឹកក្រោពុំដែលដាច់
១ ទៀតជរានោះរមែងតែធ្វើឥន្ទ្រិយទាំង៦ មានចក្ខុន្ទ្រិយជាដើម ឲ្យសៅ-
ហ្មងចុះល្អក់គ្រាគ្រាកល់វេលា - គាថា ៣២ អំពីសក់ជាដើមនោះសោត
កាលពីកាលវ័យទៅកាប្រែប្រួលទៅផ្សេង ៗ រូបកាយក៏កាន់តែស្វិតជ្រីវជ្រួញយុល
យារចុះរាល់កាលរាល់វេលា មើលទៅគួរខ្ពើមរអើម គួរនឹងសង្វេគ

សណ្ឋានសារណោចអនិច្ចារូបកាយយើងតែកល់រូបដូចគ្នាទាំងអស់គ្នាដែរ កត  រូបកាយយើងកល់គ្នានេះមានតណ្ហាជានាយជាងតាក់តែងសង់ធ្វើ បង្កើតឡើង ដូចជានាយជាងធ្វើផ្ទះ កាលបើមានខ្យល់ព្យុះពាលតីជកមក បៀតបៀនរឿយ ៗ ផ្ទះគឺអត្តភាពនេះក៏មិនអាចនឹងទប់ទល់ទ្រាំទ្រស្ថិតនៅ បានក៏កាន់តែត្រាំត្រាទុព្វលភាពចុះទៅកល់វេលា ឥរិយាបថទាំង៤ ក៏កាន់. តែថយចុះនឹងក្រោកនឹងអង្គុយក៏ក្រៃ  នឹងដើរនឹងឈរនឹងឈានដើរដើរ ទៅក៏ពិបាកចរ្យបណ្ដើរផ្គងផ្តើមដំបណ្ដើរ សោយទុក្ខវេទនាកល់កាលកល់ វេលាមិនមានល្ហែ ទេន ទុក្ខិ ជរា ហេតុដូច្នោះព្រះតថាគតពោល ថាទុក្ខនេះឈ្មោះថា ជរាទុក្ខ ។

ឯព្យាធិទុក្ខនោះព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទេសនាថា  ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ  ព្យាធិដែលកើតឡើងក្នុងរូបកាយនៃសត្វទាំងឡាយ ក៏ព្រោះតែធាតុប្រែប្រួល គឺថាជួនកាលត្រជាក់ ជួនកាលក្តៅពេលកលធ្វើ ឲ្យសោយសល់ ព្យាធិសេចក្ដីឈឺចាប់មានកើតគ្រុនកើតឈឺក្បាលវិលមុខ ឈឺពោះជាដើម  ព្យាធិនេះបៀតបៀនសត្វឲ្យដល់នូវសេចក្តីទុក្ខច្រើនប្រ-ការណាស់ ហេតុដូច្នោះទុក្ខនេះព្រះតថាគតឲ្យឈ្មោះថា ព្យាធិទុក្ខ ។

មរណទុក្ខព្រះដ៏មានបុណ្យទ្រង់ត្រាស់ទេសនាថា ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយគឺចុតិលេតចិត្តនៃសត្វក្តី ទំលាយខន្ធនៃសត្វក្តី ពោលសាកសពនៃសត្វក្តី ផ្តាច់បង់ជីវិតនៃសត្វក្តី ធម៌ទាំងនេះព្រះតថា-គតហៅថាមរណធម៌ទាំងអស់ ព្រោះថាសត្វទាំងឡាយកាលបើជិតដល់

មរណកាល តេជោធាតុក្នុងសរីរកាយនោះបង្កើតក្រៀវក្តៅខ្លាំងឡើង ធ្វើឲ្យក្តៅក្រហល់ក្រហាយពេញសព្វសរីរកាយ ដូចជាគប់ភ្លើងដែលបុគ្គលយកទៅដុតលើខ្លួនក្នុងទីជិត ទុក្ខយ៉ាងនេះហៅថា មរណទុក្ខ ១ ។

មួយទៀតសត្វទាំងឡាយដែលបានធ្វើកម្មលាមកអាក្រក់ដោយកាយ វាចា ឥតមានមេត្តាករុណា លុះកាលជិតនឹងដល់នូវមរណភាព គតិនិមិត្តឬទុក្ខនិមិត្តក៏ប្រាកដឡើង គឺឲ្យឃើញភ្លើងក្នុងទីនរកខ្លះ ជួនកាលឲ្យឃើញនាយនិរយបាលកាន់គ្រឿងសាស្ត្រាវុធដេញតាមកាប់ហែកកំទេញ តំរាមធ្វើទុក្ខ ជួនកាលក៏ឃើញជាប្រេតប្រេតក៏ ជួនកាលក៏ឃើញសត្វក្អែកក្អាតមកចោមរោមកំសាំងមានខ្លះ ម្នោះហើយក៏ភ្ញាក់ស្មារតីខ្លួនស្តាយជីវិតក្រែងនឹងលេងបាត់ទៅកាន់គតិថ្មីទៀត ខ្លះក៏ស្រែកបម្រះអង្វរអន្ទងទៅមកគេ ខ្វល់គ្មានសតិអារម្មណ៍ ខ្លះក៏ស្លាប់ដោយគេប្រហារជីវិតក៏មាន ទុក្ខយ៉ាងនេះហៅថា មរណទុក្ខប្រការ ១ ។

ឯសត្វទាំងនេះខ្លាចសេចក្តីស្លាប់ជាទីបំផុតខ្លាច នេះហើយយើងកល់គ្នាកើតមកជាសត្វជាបុគ្គលមានជីវិត កាលបើចិត្តនឹងចេញទៅលះកាយ ស្តាយជីវិតក្រៃបំផុតគ្មាន វៀរលែងតែលោកដែលមានបញ្ញាកិរិយា លោកមិនស្ញប់ខ្លាចទេ ហេតុដូច្នោះព្រះតថាគតពោលថាទុក្ខនេះឈ្មោះជាមរណទុក្ខប្រការ ១. អ្នកប្រាជ្ញមានប្រាជ្ញាគប្បីពិចារណាមើលចុះ ទុក្ខទាំង ៤ ប្រការ គឺជាតិទុក្ខ ១ ជរាទុក្ខ ១ ព្យាធិទុក្ខ ១ មរណទុក្ខ ១ ដូចសត្រូវ ៤ នាក់ ឯខ្លួនយើងទាំងពួងនេះប្រៀបដូចមនុស្សអ្នកមានពៀរសត្រូវ ៤ នាក់នោះក៏តែងស្វែងរកឧបាយនឹងសម្លាប់មនុស្សដែលមានពៀរ

នោះចេញ សត្រូវមួយនាក់ចូលទៅរកមនុស្សនេះ ធ្វើជាមិត្តស្និទ្ធស្នាល និយាយប្រលោមលួងលោមបញ្ឆោតបញ្ឆាតនាយអាយ ធ្វើឲ្យបុរសនោះទុកចិត្តស្និទ្ធមេត្រី បុរសនោះក៏មិនដឹងខ្លួនសោះថាជាសត្រូវមកលួងលោមធ្វើឧបាយកល លុះដោយអំណាចសត្រូវថាជាមិត្តប្រាកដមែន ក៏ជឿតាមពាក្យសំដីសត្រូវនោះ ៗ ក៏ដឹកនាំបបួលបុរសនោះដើរចូលទៅក្នុងព្រៃស្ងាត់ ស្រាប់តែសត្រូវដែលជាគំរប់ ២ ស្ទុះចេញមកចាប់បុរសនោះវាយដំប្រទាក់ជាទម្ងន់ សត្រូវជាគំរប់ ៣ ស្ទុះចេញមកជួយគ្នាវាយដំបន្ថែមទៀតជាទម្ងន់ក្រៃលែង សត្រូវជាគំរប់ ៤ ក៏ស្ទុះទៅកាត់ក្បាលបុរសនោះដោយដាវដ៏មុតដាច់ក្បាលបុរសនោះក្ស័យជីវិតទៅក្នុងខណៈនោះ សេចក្តីនេះមានឧបមាដូចម្តេចមិញ ជាតិទុក្ខនោះប្រៀបដូចសត្រូវដំបូងដែលជាអ្នកលួងបញ្ឆោតលោកយើងកល់គ្នាឲ្យបដិសន្ធិប្រកបដោយបញ្ចខន្ធ ថាជាទីសុខទីសប្បាយ ជរាទុក្ខនោះដូចជាសត្រូវជាគំរប់ ២ ជាអ្នកស្ទុះចេញមកវាយដំប្រដាក់ធ្វើឲ្យថមថយកំឡាំង ធ្វើឲ្យធ្មេញបាក់សក់ស្កូវជាដើម ព្យាធិទុក្ខដូចជាសត្រូវគំរប់ ៣ ជាអ្នកជួយបន្ថែមវាយដំឲ្យដល់ទុក្ខជាទម្ងន់ក្រៃលែងថែមទៀត ទើបមរណទុក្ខដូចជាសត្រូវជាគំរប់ ៤ កាន់ដាវស្ទុះចេញមកកាប់កម្ទេចជីវិតតែម្តង ក៏ទុក្ខទាំង ៤ ប្រការនេះព្រះតថាគតហៅថា អជ្ឈត្តិកទុក្ខ គឺទុក្ខប្រព្រឹត្តទៅខាងក្នុងសន្តានរបស់សត្វទាំងឡាយក្នុងភពទាំង ៣ ។

ទើបព្រះដ៏មានបុណ្យទ្រង់សំដែង សោកទុក្ខ បរិទេវទុក្ខ ទុក្ខទុក្ខ ទោមនស្សទុក្ខ ឧបាយាសទុក្ខនោះតទៅថា កិច្ចាវេ ម្នាលភិក្ខុផង

ទាំងឡាយ សេចក្ដីសោកនោះមានសភាវធ្វើចិត្តនៃសត្វឲ្យរេះក្ដៅក្រហាយ សោប់សោយរីងស្ងួត ទឹងដេកដើរឈរអង្គុយក៏មិនសុខ ទឹងបរិភោគអាហារក៏មិនស្ងប់បាន យ៉ាងនេះឈ្មោះថា សោកទុក្ខ ។

បរិទេវទុក្ខនោះ គឺមានលក្ខណធ្វើឲ្យខ្សឹកខ្សួលអួលអាក់ទឹកភ្នែកហូរចេញសស្រាក់. ដោយហេតុដែលមាតាបិតាបុត្រភរិយាញាតិមិត្តធ្វើកាលកិរិយាក្ស័យជីវិតទៅ យ៉ាងនេះឈ្មោះថា បរិទេវទុក្ខ ។

ទុក្ខទុក្ខនោះ គឺថាទុក្ខឯណាធ្វើឲ្យចិត្តស្លុតញ្រាកដកដង្ហើមធំតុះទញ់ធុញតំនិតគិតមិនធុះធ្លាយដោយនូវហេតុមានកជំណ្ឌបៀតបៀនជាដើម ទុក្ខយ៉ាងនេះឈ្មោះថា ទុក្ខទុក្ខ ។

ទោមនស្សទុក្ខនោះ គឺទុក្ខឯណាដែលប្រកបទៅក្នុងចិត្ត ធ្វើចិត្តនៃសត្វឲ្យទឹងក្រោធប្រណោកតានតឹងក្នុងទ្រូង ឲ្យតូចចិត្តអន់ចិត្ត ទុក្ខយ៉ាងនេះព្រះតថាគតឲ្យឈ្មោះថា ទោមនស្សទុក្ខ ។

ឧបាយាសទុក្ខនោះ គឺថាទុក្ខឯណាដែលកើតផ្ទុកផ្ទើសក្នុងហឫទ័យអាល័យអាឡោះបង្អៀតបង្អល់ខ្ទក់ខ្ទល់លំបាកក្នុងចិត្ត យ៉ាងនេះឈ្មោះថា ឧបាយាសទុក្ខ ។

លំដាប់នោះ ព្រះអង្គទ្រង់សំដែងទុក្ខ ៤ ប្រការ គឺអប្បិយេហិសម្ប-យោគទុក្ខ ១ បិយេហិវិប្បយោគទុក្ខ ១ យម្បិច្ឆំនលភតិតម្បិទុក្ខ ១ បញ្ចុ-បាទានក្ខន្ធទុក្ខ ១ តទៅទៀត

អប្បិយេហិសម្បយោគទុក្ខនោះ សេចក្ដីថាអារម្មណ៍ទាំង ៥ គឺរូបារម្មណ៍ ១ សទ្ទារម្មណ៍ ១ គន្ធារម្មណ៍ ១ រសារម្មណ៍ ១ ផោដ្ឋព្វារម្មណ៍ ១ ដែលមិនជាទីប្រាថ្នា មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត បើបុគ្គលឯណាបានសេពគប់គប់ប្រសព្វសមាគមផងហើយ ក៏មានចិត្តជាទុក្ខកើតទៅជាខ្ពើមទៅជាពើមស្អប់ មិនចង់អង្គុយជិតដេកជិតឈរជិត ចង់តែគេចវេះវៀរចេញឲ្យផុត ព្រោះចិត្តនោះមិនស្រឡាញ់មិនប្រាថ្នា ហើយស្រាប់តែមកជួបប្រទះ ទុក្ខនេះព្រះតថាគតឲ្យឈ្មោះថាអប្បិយេហិសម្បយោគទុក្ខប្រការ ១ ៗ

បិយេហិវិប្បយោគទុក្ខនោះ ថា រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ក្ដី ដែលជាទីប្រាថ្នាមានចំណង់ចង់សេពគប់សមាគមផង ហើយរបស់ទាំងនោះព្រាត់ឃ្លាតចេញទៅ មិនសមតាមសេចក្ដីប្រាថ្នា ទុក្ខយ៉ាងនេះក៏ចាត់ជាបិយេហិវិប្បយោគទុក្ខប្រការ ១ ៗ អធិប្បាយថាបុគ្គលទាំងឡាយក្នុងលោកនេះ បើព្រាត់ប្រាសឃ្លាតចាកមាតាបិតាបុត្រភរិយាបងប្អូនញាតិសាលោហិតជាដើម ដែលជាទីស្រឡាញ់ពេញចិត្តនោះហើយក៏កើតទុក្ខ ទុក្ខយ៉ាងនេះក៏បានឈ្មោះថា បិយេហិវិប្បយោគទុក្ខដែរ បុគ្គលព្រាត់ព្រាកចាកទ្រព្យសម្បត្តិគ្រឿងឧបភោគ ឬព្រាត់ព្រាកចាកទី ចាកស្ថានហើយទុក្ខក៏កើតមានឡើង យ៉ាងនេះក៏ឈ្មោះថា បិយេហិវិប្បយោគទុក្ខដូចគ្នា បុគ្គលដែលធ្លាប់មានយស មានសក្ដិមានបរិវារ ហើយថយធ្លាក់ចាកយសសក្ដិ បរិវារនោះ យ៉ាងនេះក៏ឈ្មោះថា បិយេហិវិប្បយោគទុក្ខដូចគ្នា ៗ

យម្បិច្ឆំនលភតិតម្បិទុក្ខនោះ គឺទុក្ខដែលកើតឡើងព្រោះសេចក្តីប្រាថ្នា ហើយមិនសម្រេចដូចសេចក្តីប្រាថ្នា អធិប្បាយថា បុគ្គលប្រាថ្នាចង់បានត្រង់ណា ហើយមិនបានត្រង់នោះដូចសេចក្តីប្រាថ្នាក៏កើតទុក្ខ ពីព្រោះមិនបានដូចសេចក្តីប្រាថ្នា គឺធម្មតាសត្វដែលកើតមកក្នុងលោកទាំងអស់ រមែងតែងមានសេចក្តីប្រាថ្នាកល់រូប វៀរលែងតែលោកដែលជាអគ្គព្រះអរហន្ត ទុក្ខយ៉ាងនេះឈ្មោះថា យម្បិច្ឆំនលភតិតម្បិទុក្ខប្រការ ១ ។

បញ្ចុបាទានក្ខន្ធទុក្ខនោះ គឺទុក្ខកើតពីព្រោះឧបាទានក្ខន្ធ ៥ រូបក្ខន្ធនោះគឺជាអារម្មណ៍នៃឧបាទាន វេទនាក្ខន្ធក៏ជាអារម្មណ៍នៃឧបាទាន សញ្ញាក្ខន្ធក៏ជាអារម្មណ៍នៃឧបាទាន សំខារក្ខន្ធក៏ជាអារម្មណ៍នៃឧបាទាន វិញ្ញាណក្ខន្ធក៏ជាអារម្មណ៍នៃឧបាទាន ពីព្រោះខន្ធទាំង ៥ នោះនៅជាលោកិយនៅឡើយ ទើបបានឈ្មោះថាឧបាទានក្ខន្ធ ឧបាទាននោះប្រែថាសេចក្តីប្រកាន់មាំ ប្រែថាជាចំណីនៃតណ្ហា ឯខន្ធរបស់ព្រះអរិយបុគ្គលដែលនឹងនៅជាលោកិយក៏តែរូបក្ខន្ធ ១ ប៉ុណ្ណោះ ត្រង់វេទនាក្ខន្ធ សញ្ញាក្ខន្ធ សំខារក្ខន្ធ វិញ្ញាណក្ខន្ធទាំង ៤ នោះក៏តាំងនៅជាលោកុត្តរ នឹងបានឈ្មោះថាឧបាទានក្ខន្ធក៏ទេ ខន្ធទាំង ៥ ដែលជាលោកិយនោះ ព្រះតថាគតឲ្យឈ្មោះថា សំខិត្តេនបញ្ចុបាទានក្ខន្ធា ប្រការ ១ ព្រោះជាទីកើតនៃកងទុក្ខទាំងពួង មានជាតិទុក្ខជាដើម មានយម្បិច្ឆំនលភតិតម្បិទុក្ខជាបរិយោសាន អ្នកប្រាជ្ញមានប្រាជ្ញាប្រាថ្នានឹងចង់ត្រាស់ដឹងនូវទុក្ខអរិយសច្ច ក៏គប្បីពិចារណាតាមន័យដែលពណ៌នាមកក្នុងខាងក្រោយនោះចុះ ។

ពីនេះនឹងបានអធិប្បាយក្នុងអង្គនៃឧបាទានក្ខន្ធតទៅ តាមអដ្ឋកថាវិ-ភង្គនិងគម្ពីរព្រះវិសុទ្ធិមគ្គ ដោយឲ្យច្បាស់ថា ព្រះយោគាវចរកុលបុត្រអ្នកមានប្រាជ្ញា ប្រាថ្នានូវអរិយសច្ចការនោះ គឺគប្បីដឹងថា ឧបាទានក្ខន្ធទាំង ៥ ប្រការនេះ ជាទីកើតនៃទុក្ខអរិយសច្ច ១២ ប្រការនេះ មានជាតិទុក្ខជាដើម មានយម្ប៉ុនលកតិតម្បុទុក្ខជា បរិយោសាន ព្រោះឧបាទានក្ខន្ធ ជាទីកើតនៃកង់ទុក្ខទាំងពួង គួរនាដូចជាផែនដីជាទីកើតនៃរុក្ខជាតិនិងវល្លិ៍ជាតិទាំងពួង មួយទៀត កង់ទុក្ខទាំងពួងតែងបៀតបៀនឧបាទានក្ខន្ធទាំង ៥ នេះ ជានិច្ចនិរន្តរ៍មិនមានដាច់ ឧបាទានក្ខន្ធទាំង ៥ នេះ នឹងចុះកើតបដិសន្ធិក្នុងភពឯណា ៗ ក្តី កង់ទុក្ខទាំង ១២ ប្រការនេះ គឺជិតដោយជាប់តាមបៀត-បៀនទៅក្នុងភពនោះ ៗ ជានិច្ចនិរន្តរ៍មិនឃ្លៀតឃ្លាឡើយ បីដូចស្រមោលអន្ទោលតាមសរីរៈនៃបុគ្គល ព្រោះបើបុគ្គលនឹងបណ្ដាញបំបរដើរពោលដូចម្តេច ៗ ក្តី ស្រមោលមិនចេះស្ងប់ ចេះតែប្រព្រឹត្តតាមជាធម្មតា យថា មានឧបមាដូចម្តេចមិញ កង់ទុក្ខដែលជិតដោយឲ្យផលតាមបៀតបៀនបុគ្គលនោះ តថា ក៏មានឧបមេយ្យដូចជាស្រមោលតាមសរីរៈនោះឯង ព្រះយោគាវចរកុលបុត្រ ជាពុទ្ធជំនោរស មានប្រាជ្ញាប្រាថ្នានឹងគេចចៀសឲ្យផុតចាកកង់ទុក្ខដូចពណ៌នាមកនេះ គួរកុំមានចិត្តត្រេកអរនឹងឧបាទានទាំង ៥ ប្រការនោះឡើយ គប្បីពិចារណាឲ្យឃើញទោសក្នុងឧបាទានក្ខន្ធនោះ ជាការមែនតែងប្រកបដោយកង់ទុក្ខដកបតាំងពីជាតិទុក្ខជាដើម ៗ ឯឧបាទានក្ខន្ធនោះ លោកចាត់ជាធម៌ ២ ប្រការគឺរូបធម៌ប្រការ ១ នាមធម៌ប្រការ ១ រូបក្ខន្ធនោះឈ្មោះថារូបធម៌ ដោយ

អត្ថថាតែងវិនាសដោយវិរោធិបច្ច័យមានត្រជាក់និងក្តៅជាដើម វេទនាខន្ធ សញ្ញាខន្ធ សង្ខារខន្ធ វិញ្ញាណខន្ធ ទាំង ៤ នោះឈ្មោះថានាមធម៌ ដោយអត្ថថាចេះតែបង្អោនទៅក្នុងអារម្មណ៍ទាំងពួង មានរូបារម្មណ៍ជាដើម ព្រោះយោគាវចរកុលបុត្រអ្នកមានប្រាជ្ញា លុះពិនិត្យច្បាស់ក្នុងរូបធម៌នាមធម៌ជាអារ-ម្មណ៍ ចំរើនទុក្ខានុបស្សនាភាវនាបរិកម្មថា ( នាមរូបំ ទុក្ខំ ) ថាកើតមកជានាមធម៌រូបធម៌នេះ រមែងតែងប្រកបដោយជរាទុក្ខព្យាធិទុក្ខមរណទុក្ខជាដើមយ៉ាងនេះ មិនលះវៀរបុគ្គលណាមួយឡើយ មួយវិញទៀតបុគ្គលដែលជាបុថុជ្ជនមិនស្តាប់ត្រាប់តែងព្រះធម៌ទេសនានោះ កាលបើទុក្ខមកដល់ខ្លួនហើយ ក៏តក់ស្លុតភិតភ័យៈសោកខ្សឹកខ្សួលរន្ធត់ទាំង ឯបុគ្គលជាអរិយសាវកបានស្តាប់ធម៌ទេសនានៃព្រះតថាគតហើយ កាលបើទុក្ខទាំង-ពួងនោះមកដល់ ក៏តាំងចិត្តខ្ជាប់លើទុក្ខនោះបានដោយតាំងប្រាជ្ញាចុះពិចារណាឃើញថា សត្វទាំងឡាយកើតមកក្នុងលោកនេះទុកជាមានបុញ្ញា-នុភាពច្រើនដូចម្តេចៗក្តី ឬមានទ្រព្យធនធានប្រាក់មាសកែវកងប៉ុន្មានៗក្តី ឬមានឥស្សរិយយសបរិវារយសធំយ៉ាងណាៗក្តី ទុក្ខទាំងនេះមិនបានញ-ញើតកោតក្រែងខ្លាចស្បើម ឬនឹងរើសមុខយល់មុខថាអ្នកនេះគួរដល់ទៅសេចក្តីទុក្ខ អ្នកនោះមិនគួរនោះក៏គត់អត្តិមានៈឡើយ ទុក្ខតែងត្រូវគ្រប់រូបសត្វទាំងអស់ ហេតុដូច្នោះព្រះតថាគតត្រាស់ទេសនាថាទុក្ខអរិយសច្ច ព្រោះអរិយបុគ្គលទាំងឡាយនោះ លោកឃើញក្នុងទុក្ខជាក់ច្បាស់ដោយពិត ជារបស់ពិតរបស់អរិយបុគ្គល ព្រះសម្មាសម្ពុទ្ធក្តី ព្រះបច្ចេកពុទ្ធក្តី លោកតែងត្រាស់ដឹងនូវទុក្ខអរិយសច្ចដោយសយម្ភូញាណ គឺ ឃើញដោយ

ប្រាជ្ញារបស់ព្រះអង្គឯង តែព្រះអគ្គសាវកក្តី ព្រះអសីតិសាវកក្តី ព្រះបកតិសាវកក្តី លោកបានដឹងបានឃើញកងទុក្ខទាំងនេះដោយសុតមយញ្ញាណ ព្រោះបានស្តាប់ព្រះធម្មទេសនា ទើបបានដឹងបានឃើញដោយពិតប្រាកដ ហេតុដូច្នេះឯង ទើបសម្តេចព្រះទសពលញ្ញាណ ទ្រង់ប្រទានធម្មទេសនា ឈ្មោះថាទុក្ខអរិយសច្ច ជារបស់ពិតរបស់ព្រះអរិយបុគ្គល ដូចន័យដែលបានពណ៌នាមកនេះ ។

ទុក្ខអរិយសច្ចនេះមានអត្ថ ៤ ប្រការ គឺ

១ បីឡនដ្ឋោ មានអត្ថថាបៀតបៀន

២ សំខតដ្ឋោ មានអត្ថថាបច្ច័យប្រជុំគ្នាតាក់តែង

៣ សន្តាបដ្ឋោ មានអត្ថថាក្តៅក្រហាយ

៤ វិបរិណាមដ្ឋោ មានអត្ថថាប្រែប្រួល

អត្ថខាងដើមគឺ បីឡនដ្ឋោ នោះជាលក្ខណៈនៃទុក្ខ គឺជាលក្ខណៈនៃទុក្ខអរិយសច្ចពិត សំដែងអត្ថថា បីឡនដ្ឋោ ។ នោះ សំដៅឲ្យឃើញសេចក្តីថាកងទុក្ខទាំង ១២ ប្រការ គឺ ជាតិទុក្ខ ។ ដែលកើតមានដល់សត្វ ដែលឧប្បត្តិកើតមកយកកំណើតនៅក្នុងវដ្តសង្សារនេះក្តី ជរាទុក្ខ ។ ដែលមានលក្ខណៈធ្វើឲ្យមានឥន្ទ្រិយគ្រាំគ្រាវិកលវិការវិបរិតប្រែប្រួលនោះក្តី ព្យាធិទុក្ខ ។ ដែលមានលក្ខណៈធ្វើឲ្យឈឺចាប់ លំបាកវេទនាមានប្រការផ្សេង ៗ នោះក្តី មរណទុក្ខ ។ ដែលមានលក្ខណៈកាត់បង់នូវជីវិតិន្ទ្រិយនោះក្តី សោកទុក្ខ ។ ដែលមានលក្ខណៈឲ្យក្តៅក្រហាយស្ងួតស្ងប់ស្ញប់សោបសោយក្នុងចិត្តនោះក្តី បរិទេវទុក្ខ ។ ដែលមានលក្ខណៈធ្វើឲ្យខ្សឹក-

ឲ្យល្អួលណាក់ មានទឹកភ្នែកដំហូរចេញពេញពោះពាសស្រោកនោះក្តី ទុក្ខ-
ទុក្ខ ៗ ដែលមានលក្ខណាធ្វើឲ្យចិត្តតះខញាំញោកធុញថប់ តឹងទ្រូងដក
ដង្ហើមធំនោះក្តី ទោមនស្សទុក្ខ ៗ ដែលមានលក្ខណាធ្វើឲ្យក្តួចចិត្តហាំងថ្នាក់
អន់អាក់ក្នុងចិត្តនោះក្តី ឧបាយាសទុក្ខ ៗ ដែលមានលក្ខណាធ្វើឲ្យក្តួលផ្សូក
ផ្ទេះអាល័យអាលោះនោះក្តី អប្បិយេហិសម្បយោគទុក្ខ ៗ ដែលមានលក្ខ-
ណាធ្វើឲ្យទើសទាល់ទាស់ស្មប់ ពីព្រោះនៅប្រកបដោយសត្វនឹងសង្ខារ
ដែលមិនគាប់ចិត្តមិនជាទីស្រឡាញ់នោះក្តី បិយេហិវិប្បយោគទុក្ខ ៗ ដែល
មានលក្ខណាធ្វើឲ្យស្តាយស្រណោះ ពីព្រោះប្រាសព្រាត់ចាកសត្វនឹងសង្-
ខារដែលជាទីស្រឡាញ់នោះក្តី យម្បិច្ឆំនលភតិតម្បិទុក្ខ ៗ ដែលមានលក្ខ-
ណាធ្វើឲ្យខ្វល់ខ្វាយល្អក់ចិត្ត ក្នុងកាលដែលប្រាថ្នានឹងបានរបស់ម្រែមដូចប្រាថ្នា
នោះក្តី ករណីទុក្ខទាំង ១២ ប្រការនេះ រមែងបៀតបៀនសត្វឲ្យបានសេចក្តី
លំបាកទុក្ខវេទនា កើតមកជាសត្វមានជីវិតហើយ ក៏រៀងតែជាទុក្ខនឹង
បៀតបៀនជាធម្មតា ដែលនឹងចៀសឲ្យផុតកត់ឲ្យរួចពីទុក្ខនោះគ្មានសោះ
ឡើយ ទុកជាអង្គព្រះអរហន្ត មានអង្គព្រះសម្មាសម្ពុទ្ធជាដើមក្តី ក៏គង់
ចៀសមិនផុតសេចក្តីទុក្ខវេទនា ដ៏ប្រព្រឹត្តទៅក្នុងកាយនោះបាន លុះតែ
ដល់សិវស្ថាន ពេលគឺព្រះនិព្វាននោះ ទើបនឹងផុតអំពីសេចក្តីទុក្ខវេទនា
នោះបាន ហេតុដូច្នោះ ទើបសម្តេចព្រះអនាវរញ្ញាណ ទ្រង់សម្តែងអត្ថ
របស់ព្រះអរិយសច្ច គឺ បិណ្ឌត្ថោ ជាលក្ខណានៃខ្លួន ឯអត្ថជាគំរប់ ២
នោះគឺ សំខាតត្ថោ ៗ នោះមានអត្ថាធិប្បាយយោលហេតុដល់សមុទយ-
សច្ច ទីនឹងឲ្យឃើញសេចក្តីថាករណីទុក្ខនេះកើតមានឡើងពីព្រោះតណ្ហា ៗ នេះ

ជាបច្ច័យប្រជុំតាក់តែងឲ្យកើតទុក្ខ តាក់តែងកងទុក្ខឲ្យដល់សត្វដូចតណ្ហា នេះមិនមាន ប៉ុនណាព្រះអង្គទ្រង់សំដែងសមុទ័យឲ្យឃើញសេចក្ដីហេតុដល់សមុទយសច្ចដូច្នេះ ទើបសំដែងនូវអត្ថគឺ សង្ខតដ្ឋោ នេះជាអត្ថនៃទុក្ខអរិយ-សច្ចជាគំរប់ ២ ឯអត្ថជាគំរប់ ៣ គឺ សន្តាបដ្ឋោ ។ នោះមានអត្ថាធិប្បាយពោលរហូតដល់មគ្គអរិយសច្ច ដើម្បីនឹងឲ្យឃើញសេចក្ដីថា កងទុក្ខទាំងពួងនឹងនឹងធ្វើឲ្យសត្វក្ដៅក្រហាយ សោបសល់ខ្វល់ខ្វក់ ព្រោះហេតុថាសត្វទាំងឡាយស្រវឹងស្រវើងទៅដោយសេចក្ដីប្រមាទក្នាក់ក្នាំង មិនមានឧស្សាហ៍ប្រតិបត្តិតាមមគ្គសច្ចដែលប្រកបតាមអង្គ ៨ ប្រការ មានសម្មាទិដ្ឋិជាដើម មានសម្មាសមាធិជាទីបំផុត បើសត្វទាំងឡាយខំឧស្សាហ៍ប្រតិបត្តិតាមមគ្គសច្ចហើយ កងទុក្ខទាំងពួងក៏នឹងមិនបានកើតមាន កងទុក្ខក៏នឹងមិនបានធ្វើឲ្យក្ដៅក្រហាយសោបសល់ឡើយ ព្រោះហេតុនោះហើយបានជាព្រះសម្មាសម្ពុទ្ធទ្រង់សំដែងឲ្យឃើញជាក់ច្បាស់រហូតដល់មគ្គសច្ចដូច្នេះ ទើបបានសំដែងនូវអត្ថគឺ សន្តាបដ្ឋោ ជាអត្ថនៃទុក្ខអរិយសច្ចជាគំរប់ ៣ ឯអត្ថជាគំរប់ ៤ គឺ វិបរិណាមដ្ឋោ នោះ មានអត្ថាធិប្បាយពោលរហូតដល់និរោធសច្ច ព្រោះនឹងឲ្យឃើញសេចក្ដីច្បាស់ថាកងទុក្ខទាំងពួងមានជាតិជាដើមនោះ នឹងធ្វើសត្វលោកឲ្យដល់នូវសេចក្ដីវិបរិតផ្សេង ៗ នោះ ក៏ព្រោះតែថាមិនទាន់បានសម្រេចនូវនិរោធសច្ច គឺព្រះនិព្វាន លោកអ្នកដែលមានវាសនាបារមីមានប្រាជ្ញាចាស់ក្លៀវក្លាបានសម្រេចព្រះអរិយ-មគ្គ អរិយផល ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន បានព្រះនិព្វានជាអារម្ម-ណ៍កាលណាហើយ កងទុក្ខទាំងពួងក៏នឹងផុតរលត់សូន្យ នឹងជាសុខទៀង

ទាត់មិនគ្មានប្រែប្រួល ដែលនឹងប្រែប្រួលរបស់គ្មានខ្លះក្នុងអំណាចខាងក្
នោះ ព្រោះតែមិនបានធ្វើឲ្យដាច់ច្បាស់នូវនិរោធសច្ច ព្រះពុទ្ធអង្គទ្រង់សំ-
ដែងឲ្យឃើញច្បាស់ហេតុដល់និរោធសច្ចដូច្នេះ បានជាទ្រង់សំដែងអត្ថ ទី
វិបរិណាមត្តោ ជាអត្ថនៃទុក្ខអរិយសច្ចជាគំរប់ ៤ ហើយបញ្ចូលគ្នាត្រូវ
ជាអត្ថនៃទុក្ខអរិយសច្ច ៤ ប្រការ ។

« តត្ថកតមំ ទុក្ខសមុទយោ អរិយសច្ចំ យាយំ តណ្ហា ពោ-
នោព្ភវិកា នន្ទិរាគសហគតា តត្រតត្រាភិនន្ទិនី សេយ្យថីទំ
កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ឥទំ វុច្ចតិ ភិក្ខវេ
ទុក្ខសមុទយោ អរិយសច្ចន្តិ »

ពីនេះទៅនឹងវិសជ្ជនាក្នុងសមុទយអរិយសច្ចតទៅ ទើបព្រះសម្មាសម្ពុទ្ធ
ទ្រង់សម្ដែងជាកថេតុកម្យតាបុច្ឆាថា ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ សមុទ-
យអរិយសច្ចនោះតើដូចម្ដេច ទ្រង់វិសជ្ជនាព្រះអង្គឯងថា តណ្ហាឯណា
ដែលនឹងធ្វើឲ្យសត្វទាំងឡាយមកសន្ទួយកំណើតកើតក្នុងភពថ្មីទៀត
តណ្ហានោះគឺសេចក្ដីស្រេកឃ្លានឬចំណង់ស្រើបស្រាល ត្រេកត្រអាលក្នុង
វដ្ដសំសារ សត្វទាំងពួងកើតក្នុងភពឯណា ៗ សេចក្ដីចំណង់ស្រើបស្រាល
ត្រេកត្រអាលក៏មានក្នុងភពនោះ ៗ មិនចៀសវៀរនឹងមិនសោយសោះ
ឡើយ សេចក្ដីចំណង់ក្នុងរូបារម្មណ៍ ក្នុងសទ្ទារម្មណ៍ ក្នុងគន្ធារម្មណ៍
ក្នុងរសារម្មណ៍ ក្នុងផោដ្ឋព្វារម្មណ៍ រឹតរួតក្រៀកខ្ជាប់ម៉ាំមួនទៅក្នុងសន្ដាន
សត្វចងត្រៃបនឹងទុក ឲ្យត្រេចរង្គាត់ក្នុងវដ្ដសំសារ វិលស្លាប់វិលកើតវិលយក
កំណើតក្នុងភពតូចភពធំ សោយទុក្ខវេទនា ពីព្រោះកងទុក្ខ គឺជរាព្យាធិ

ឥតមានបៀតបៀនញាំញីឈ្លីឈ្លប មរណនោះគឺនាយគន់រំពាត់ផ្តាច់ផ្តិលជីវិ-តិន្ទ្រិយឲ្យដាច់ ឧបមាដូចនាយពេជ្ឈឃាដកាត់កផ្តាច់ជីវិតៈដោយដាវដ៏មុតថ្លាសែនទុក្ខ សែនលំបាក ស្លាប់ពីនេះទៅកើតឯណោះ ស្លាប់ពីឯណោះទៅកើតឯណោះតទៅ ស្លាប់ពីឯណោះត្រឡប់វិលមកកើតទីនេះវិញក៏មានចេះតែវិលត្រឡប់ស្លាប់កើតយកកំណើតក្នុងភពតូចភពធំ មិនចេះផុតមិនចេះចប់ត្រឡប់ត្រឡិនដោយវិញ គឺតណ្ហា ជាចំណងតែងដឹកនាំមិនឲ្យរំលៀកចេញរួចបាន ឯតណ្ហានោះមាន ៣ ប្រការ គឺ កាមតណ្ហា ប្រ-ការ ១ ភវតណ្ហា ប្រការ ១ វិភវតណ្ហា ប្រការ ១ កាមតណ្ហានោះបានខាងលោភចិត្ត ប្រាថ្នាក្នុងបញ្ចកាមគុណ ទីងប្រាថ្នាកំណើតក្នុងម-នុស្សស្រុកតទៅទិព្វកាមាវចរ ៦ ស្ថាន អធិប្បាយថា បុគ្គលទាំងឡាយធ្វើទានរក្សាសីល សាងកងការកុសលផ្សេងៗ ព្រោះតែប្រាថ្នាចង់បានមនុស្ស-សម្បត្តិ ទីងទេវសម្បត្តិក្នុងជាន់កាមាវចរនោះឈ្មោះថា កាមតណ្ហា ឯភវតណ្ហានោះបានខាងលោភចិត្តនៃលោកជាព្រះយោគាវចរ ដ៏ប្រកបដោយសស្សតទិដ្ឋិ ឃើញថាបើបានកើតក្នុងរូបព្រហ្មក្តី អរូបព្រហ្មក្តី ទីងបានមានសេចក្តីរាសផុតមរណនោះគឺឥតអន្តីមាន រូបចិត្តជឿខ្ជាប់យ៉ាងនេះហើយចំរើនឈានសមាបត្តិដោយលោភចិត្ត ប្រាថ្នាទីងទៅកើតក្នុងរូប-ព្រហ្មនោះ ទើបបានឈ្មោះថា ភវតណ្ហា ឯវិភវតណ្ហានោះ គឺលោភចិត្តដ៏ប្រកបដោយឧច្ឆេទទិដ្ឋិ ត្រេកអរក្នុងឈានសមាបត្តិ ដោយសញ្ញាសំគាល់ថាបានទៅកើតក្នុងព្រហ្មលោកហើយ ទីងបានវិលត្រឡប់មកកើតក្នុងមនុស្សលោកនេះវិញក៏ឥតអន្តីមានឡើយ ទីងលែងសំខារធម៌ដាច់

ចូលចិត្តនូវស្ថានគឺព្រះនិព្វានក្នុងព្រហ្មលោកនោះ លោកដែលជាព្រះ
យោគាវចរបុគ្គលមួយប្រការនេះចូលចិត្តយ៉ាងនេះ ហើយមានលោភចិត្តត្រេក
អរព្រួញទាំងនឹងទៅកើតក្នុងអរូបភពនោះ ឈ្មោះថាវិភវតណ្ហា អ្នកប្រាជ្ញមាន
ប្រាជ្ញាគប្បីសន្និដ្ឋានចូលចិត្តចុះ ថា តណ្ហាទាំង៣ប្រការនេះ ឈ្មោះថា
សមុទយអរិយសច្ច ដោយអត្ថថាជាហេតុជាបច្ច័យឲ្យកើតកងទុក្ខមានជាតិ-
ទុក្ខជាដើមដែលពោលមកហើយ កាមតណ្ហាដែលប្រាជ្ញថាទូន្មានកាមគុណ
នោះជាហេតុជាបច្ច័យឲ្យកើតកងទុក្ខ ក្នុងកាមភព ភវតណ្ហានិងវិភវតណ្ហា
នោះគឺជាបច្ច័យឲ្យកើតកងទុក្ខមានជាតិទុក្ខជាដើម ក្នុងរូបភព និងអរូបភព
ហេតុដូច្នោះបានជាលោកថាអត្ថនៃសមុទយនោះថា បណ្ដាកងទុក្ខទាំងពួង
មានជាតិទុក្ខជាដើមនោះ នឹងបានកើតមកអំពីចំណែកគឺឥតអង្គើយទេ កើតពី
អំពីតណ្ហាម្យ៉ាងនេះឯង បើវៀរតែតណ្ហានេះចេញហើយ ជាតិទុក្ខ ជរាទុក្ខ
ព្យាធិទុក្ខ មរណទុក្ខជាដើមជាមិនមានសោះតែម្ដង អ្នកប្រាជ្ញមានប្រាជ្ញាគួរ
នឹងពិចារណាចុះ ថាតណ្ហាតែម្យ៉ាងនេះឯង ~~ធំគម្ពស់ទូលាយវែងវាស់ទ្រុង~~
ទៅក្នុងសមុទ្រ គឺថ្ងៃសំសារអស់កាលយូរលង់នឹងងឹតបាំងគួរបាំងជាតិមិនបាន
មិនឃើញទីពំនាក់ពំនាំនឹងពឹងពាក់ ស្រីយមិនឃើញកោះឃើញត្រើយ ដែល
នឹងឈប់សម្រាកបន្តិចសោះឡើយ ហេតុដូច្នោះទើបព្រះអង្គត្រាស់ពោលថា
តណ្ហាឈ្មោះថាសមុទយ ព្រោះតណ្ហាជាហេតុជាបច្ច័យឲ្យកើតកងទុក្ខទាំង
ពួង ព្រះអរិយបុគ្គលឃើញហេតុច្បាស់ដូច្នេះ បានជាបញ្ញត្តិឈ្មោះថា
សមុទយអរិយសច្ច សម្ដេចព្រះសព្វញ្ញូទ្រង់សម្ដែងប្រភេទនៃ
សមុទយអរិយសច្ច៣ប្រការដូច្នេះហើយ ទើបទ្រង់សម្ដែងហេតុតណ្ហាដែ

ប្រព្រឹត្តទៅក្នុងអារម្មណ៍ផ្សេងៗ នោះទៀត ជាគេថ្មុតឲ្យគេទុកជា កិច្ច-
ទេ ម្តងកើតទាំងឡាយ តណ្ហាទេះកាលបើនឹងកើតឡើងតែងកើតក្នុងប្រាថ្នា
ឯណា កាលបើនឹងផ្សាយកើតផ្សាយទៅក្នុងភពទីណា ទើបត្រូវនៃសត្វឆា
ដោះស្រាយព្រោះអត្ថឯង ថា ធម្មជាតិអ្វីៗទីស្រឡាញ់ជាទីគាប់ចិត្ត ចំរើនចិត្តជា
ទីត្រេកត្រអាលចិត្តហើយ តណ្ហាក៏កើតឡើងក្នុងធម្មជាតិនោះ ផ្សាយទៅ
ក្នុងធម្មជាតិនោះឯង ឯតណ្ហានោះមានដល់ ១០៨ ប្រការ ចែកក្នុងកាម-
ភព ៣៦ ប្រការជាកាមតណ្ហា ក្នុងរូបភព ៣៦ ប្រការជាភវតណ្ហា ក្នុងអ-
រូបភព ៣៦ ប្រការជាវិភវតណ្ហា ទើបត្រូវជាតណ្ហា ១០៨ ប្រការដូច្នេះ ។

ក៏កាមតណ្ហា ៣៦ នោះ គឺតណ្ហាប្រព្រឹត្តទៅក្នុងអតីតកាល ១២
ប្រព្រឹត្តទៅក្នុងបច្ចុប្បន្នកាល ១២ ប្រព្រឹត្តទៅក្នុងអនាគតកាល ១២ ត្រូវ
ជាកាមតណ្ហា ៣៦ ប្រការ គឺតណ្ហាកើតឡើងក្នុងអាយតនខាងក្នុង ៦
ប្រការ កើតឡើងក្នុងអាយតនខាងក្រៅ ៦ ប្រការ ត្រូវជាតណ្ហា ១២
ប្រការ តណ្ហាខាងក្នុង ៦ ប្រការនោះ គឺចក្ខាយតន ១ សោតាយតន ១
ឃានាយតន ១ ជិវ្ហាយតន ១ កាយាយតន ១ មនាយតន ១ ត្រូវជា
តណ្ហាខាងក្នុង ៦ ប្រការដូច្នេះ តណ្ហាខាងក្រៅ ៦ នោះ គឺរូបាយតន ១
សទ្ទាយតន ១ គន្ធាយតន ១ រសាយតន ១ ផោដ្ឋព្វាយតន ១ ធម្មា-
យតន ១ ត្រូវជាតណ្ហាខាងក្រៅ ៦ ប្រការដូច្នេះ និងអធិប្បាយតណ្ហាខាង
ក្នុង ៦ ប្រការនោះគឺថាកាលណាបើបុគ្គលយកកញ្ចក់មកឆ្លុះមើលស្រមោល
មុខរបស់ខ្លួន ឃើញភក្ត្រ ត្រចៀក ច្រមុះ អណ្តាត រូបកាយរបស់ខ្លួន
ហើយ កើតសេចក្តីស្រឡាញ់ពេញចិត្តគាប់ចិត្តចំរើនចិត្តត្រេកអរក្នុងចិត្ត

ខ្លួនថា ភ្នែកអញល្អ ត្រចៀកអញល្អ ច្រមុះអញល្អ អណ្តាតអញល្អ រូប
កាយអញល្អ សំនឹងល្អគ្រប់កន្លែង ស្រឡាញ់ពេញចិត្តរបស់ខ្លួនយ៉ាងនេះ
ឈ្មោះថាតណ្ហាកើតក្នុងអាយតនខាងក្នុង ៦ ប្រការ តណ្ហាដែលកើតខាង
ក្រៅ៦ នោះ អធិប្បាយថាកាលបើបុគ្គលឃើញរូបអ្វី ៗ ទាំងពួង រូបមាន
វិញ្ញាណក្តី រូបឥតវិញ្ញាណក្តី ដែលប្រពៃល្អឲ្យកើតសេចក្តីស្រឡាញ់ឡើង
មានចំណង់ចង់បានរូបនោះ បានស្តាប់សំឡេងអ្វីដែលពីរោះ ៗ ហើយកើត
សេចក្តីត្រេកអរពេកក្រៃចូលចិត្ត បានហិតក្លិនអ្វីក្លិនក្រអូប គឺមានចិត្ត
ត្រេកអរប្រាថ្នាចង់បាន បានលិតរសក្តុកក្រែបដ៏ឆ្ងាញ់ពិសារហើយ
កើតសេចក្តីប្រាថ្នាចង់បានចង់បរិភោគ បានសម្ផស្សត្រូវពាល់គ្រឿងអ្វី ៗ ដែល
មានសាច់ល្អិតសាច់ទន់មានសម្ផស្សល្អជាដើម ហើយស្រឡាញ់ចូលចិត្ត
ចង់បានស្លៀកពាក់ជាដើម បានរំពឹងគិតដល់ធម៌ឯណាជាទីគាប់ចិត្តចូល
ចិត្ត ក៏កើតសេចក្តីលោភប្រាថ្នាចង់បានអារម្មណ៍នោះ ឯតណ្ហាប្រាថ្នាចង់បាន
រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍
ធម្មារម្មណ៍ នោះព្រះតថាគតពោលថាតណ្ហាកើតខាងក្នុង ៦ ប្រការដូច្នេះ
តណ្ហាខាងក្រៅ ៦ ប្រការដែលបានពណ៌នាមកហើយ ផ្សំគ្នាទើបត្រូវជា
កាមតណ្ហា ១២ ប្រការ ចាត់ជាអតីត ១២ បច្ចុប្បន្ន ១២ អនាគត ១២
សរុបបញ្ចូលផងគ្នាត្រូវជាកាមតណ្ហា ៣៦ ដូច្នេះ ។

មួយទៀតតណ្ហាទាំងនេះបើកើតអំពីលោភចិត្តខាងអកុសលក៏សុទ្ធតែ
ជាបាបទាំងអស់ ឯភវតណ្ហានឹងវិភវតណ្ហាក៏ចែកចេញជា ៣៦ ៗ ដូចគ្នា
ត្រូវជាតណ្ហា ១០៨ ប្រការ លោកចែកម្យ៉ាងទៀតថា តណ្ហានុសយជី

ប្រកបដោយទ្វារទាំង ៦ គឺចក្ខុទ្វារ សោតទ្វារ ឃានទ្វារ ជិវ្ហាទ្វារ កាយទ្វារ មនោទ្វារ នោះបានជាអជ្ឈត្តិកតណ្ហាខាងក្នុង ១៨ ជាពាហិរតណ្ហាខាងក្រៅ ១៨ ដូចនេះ បណ្ឌិតគប្បីសន្និដ្ឋានចុះ គឺចាយកតណ្ហា ៣ ប្រការ គឺ កាមតណ្ហា ភវតណ្ហា វិភវតណ្ហានោះមកតាំងទុក ហើយយកអាយតនខាងក្នុង ៦ ប្រការ គឺ ចក្ខាយតនជាដើមមកគុណនឹងតណ្ហាទាំង ៣ នោះជា ៦ បីដង ត្រូវជា ១៨ ឈ្មោះថា អជ្ឈត្តិកតណ្ហា ហើយយកអាយតនខាងក្រៅ ៦ គឺរូបារម្មណ៍ជាដើមមកគុណនឹងតណ្ហាទាំង ៣ នោះទៀត ជា ៦ បីដងត្រូវជា ១៨ ឈ្មោះថាពាហិរតណ្ហា យកអជ្ឈត្តិកតណ្ហា ១៨ នឹងពាហិរតណ្ហា ១៨ មកបូកបញ្ចូលគ្នាត្រូវជាតណ្ហា ៣៦ ហើយយកតណ្ហា ៣៦ នោះមកតាំងទុកនឹង យកកាលទាំង ៣ គឺ អតីតកាល អនាគតកាល បច្ចុប្បន្នកាលគុណទៀត គឺ ៣៦ បីដង ត្រូវជាតណ្ហា ១០៨ ប្រការ អ្នកប្រាជ្ញមានប្រាជ្ញាគប្បីសន្និដ្ឋានក្នុងអត្ថាធិប្បាយចុះ ថាតណ្ហាដែលមានលក្ខណឱ្យប្រាថ្នាកិលេសកាម វត្ថុកាម នោះបើប្រាសចាកសស្សតទិដ្ឋិនឹងឧច្ឆេទ-ទិដ្ឋិ ហើយគឺបានជាកាមតណ្ហា តណ្ហានោះកាលបើប្រកបដោយសស្សតទិដ្ឋិ ប្រកាន់ថាសត្វទៀងលោកទៀង ឃើញថាកើតមកជាសត្វហើយទៀត អ្នកណាធ្លាប់កើតជាអ្វីវេលាដល់ស្លាប់ទៅកើតម្ដងទៀតក៏ជាយ៉ាងនោះ តណ្ហាប្រកបដោយសស្សតទិដ្ឋិយ៉ាងនេះឈ្មោះថា ភវតណ្ហា តណ្ហាដែលប្រកបដោយឧច្ឆេទទិដ្ឋិ ឃើញថាសត្វទាំងឡាយស្លាប់ហើយក៏សូន្យទៅមិនកើតទៀត តណ្ហាប្រកបដោយឧច្ឆេទទិដ្ឋិយ៉ាងនេះ ឈ្មោះថាវិភវតណ្ហា ដែលពេញឈ្មោះថាតណ្ហា សេចក្ដីប្រាថ្នាកាមគុណដែលជាកិលេសកាមវត្ថុកាម

ហើយកំពុងជាទីឯមានតែសេចក្តីទុក្ខ សេចក្តីសោកខ្សឹកខ្សួលអួលអាល័យ ភ័យខ្លបខ្លាចផ្សេងៗ ហេតុដូច្នេះ បុគ្គលដែលមានប្រាជ្ញាខំសង្កត់ ខ្លួនកាយខ្លួនចិត្តឲ្យស្ងប់ឲ្យស្រាលចាកសេចក្តីប្រាថ្នាក្នុងកាមគុណ កាលបើសត្វនោះមិនបានខ្វល់ខ្វាយក្នុងកិលេសកាមវត្ថុកាមនេះហើយ សេចក្តីសោកខ្សឹកខ្សួលអួលអាល័យទុក្ខភ័យទាំងពួង ក៏នឹងរលត់សាបសូន្យសោះទៅដោយពិតប្រាកដ ព្រះអរិយបុគ្គលមានអង្គព្រះសម្មាសម្ពុទ្ធជាដើម លោកអាចលះបង់កងតណ្ហានេះបានដាច់ស្រឡះពីសន្តាន មិនទាំងសល់ខាន សូម្បីតែបន្តិចបន្តួចក៏ឥតគង់មានឡើយ ហេតុដូច្នេះសម្តេចព្រះសពេជ្ញពុទ្ធសព្វញ្ញូទ្រង់ប្រទានធម្មទេសនាឈ្មោះសមុទយអរិយសច្ច ជារបស់ពិតរបស់ព្រះអរិយបុគ្គល ដូចដែលបានពណ៌នាមកនេះ ។

សមុទយអរិយសច្ចនេះមានអង្គ ៤ ប្រការដូចគ្នា គឺ អា.យុ.ហ.នត្ថោ មានអត្ថថាប្រមូលមកប្រការ ១ និ.ទា.នត្ថោ មានអត្ថថាជាហេតុប្រការ ១ សំយោគត្ថោ មានអត្ថថាប្រកបព្រមប្រការ ១ ប.លិ.ពោ.ធត្ថោ មានអត្ថថាកង្វល់រវល់ប្រការ ១ ត្រូវជា ៤ ប្រការ អង្គជាបឋម គឺ អាយុហនត្ថោ ។ នោះជាលក្ខណៈនៃសមុទយអរិយសច្ច អាយុហ.នៈ នោះប្រែថាប្រមូលមក អធិប្បាយថា តណ្ហានោះជាមេកងមេពួកធំ មួយដែរជាអ្នកតាំងតែកងទុក្ខឲ្យសត្វទាំងពួង ប្រមូលមកនូវកងទុក្ខឲ្យដល់សត្វឥតមានពើសមុខ តណ្ហានោះមាន ២ ប្រការ គឺ អត្តត្ថតណ្ហាប្រការ ១ បរត្ថតណ្ហា ប្រការ ១ អត្តត្ថតណ្ហានោះ គឺ ប្រាថ្នាទីដែលជាប្រយោជន៍ផល់ខ្លួនឯង គឺថាទីដែលបានកោតសម្បត្តិបរិក្ខារសម្បត្តិទាំងពួងមកជារបស់

ខ្លួន ឯបរត្ថតណ្ហានោះ គឺប្រាថ្នានូវប្រយោជន៍ផលបុគ្គលដទៃ ជួយទំនុកបំរុង បុគ្គលដទៃបណ្ដាដែលខ្លួនស្រឡាញ់ពេញចិត្តមានទាំងបងប្អូន មានបុត្រភ-រិយាជាដើម សេចក្ដីប្រាថ្នាទាំងពីរប្រការនេះ បើមិនសំរេចមិនសមក្ដីចិត្តប៉ុណ្ណឹងកាលណា ហើយក៏កើតទុក្ខរឿយៗមិនចេះដាច់មិនចេះស្ងប់ បើទុកជាបានតែថាមិនបានដោយឆាប់ដោយរហ័សឲ្យទាន់ចិត្តទាន់គំនិតក៏កើតទុក្ខសៅហ្មងចិត្តក្នុងអារម្មណ៍នោះៗដែរ សូម្បីដោយហេតុទៅទុកជាបន្តួច ៗ សូម្បីផ្កាដូចជាមនុស្ស សង្កើច ស្រមោចស្រមើលគិតនឹកកើតទុក្ខព្រោះសេចក្ដីប្រាថ្នាតាមវិស័យខ្លួនដែលជាសត្វតូចសត្វល្អិត ឈ្មោះថាប្រ-កបដោយតណ្ហា ហើយក៏រៀងតែនឹងប្រកបដោយទុក្ខភ័យអន្តរាយផ្សេងៗ ។ ជាធម្មតា សម្ដេចព្រះបរមសាស្ដាចារ្យ ព្រះអង្គទ្រង់ឲ្យឃើញលក្ខណនៃសមុទយសច្ចយ៉ាងនេះ បានជាទ្រង់សម្ដែងអត្ថជាបឋម គឺអាយូហ-នត្ថោ ជាលក្ខណៈនៃសមុទយសច្ចដោយប្រការដូច្នេះ ឯអត្ថជាគំរប់ ២ គឺនិទានត្ថោ ។ នោះមានអធិប្បាយផ្ទុះហេតុផលទុក្ខអរិយសច្ច ដើម្បីនឹងឲ្យឃើញសេចក្ដីច្បាស់ថា ការទុក្ខដែលនឹងកើតដល់សត្វទាំងពួងនោះ ក៏អាស្រ័យនឹងតណ្ហានេះជាហេតុសម្រាប់តែនឹងឲ្យកើតផល ពោលគឺការទុក្ខទាំងពួងមានជាតិទុក្ខជាដើម ឯអត្ថជាគំរប់ ៣ គឺ សំយោគត្ថោ ។ នោះមានអធិប្បាយផ្ទុះហេតុផលនិរោធអរិយសច្ច ដើម្បីនឹងឲ្យឃើញសេចក្ដីថាដំណើរដែលតណ្ហានឹងប្រកបសត្វទុកនៅក្នុងវដ្ដសំសារនោះ ក៏ព្រោះតែហេតុដែលសត្វមិនទាន់បានធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន សន្តាននោះនៅនឹងនិតដោយ កត ទោស មោហ ព្រះអង្គត្រាស់នឹងឲ្យឃើញហេតុផល

និរោធអរិយសច្ចធម៌នេះ ឯអត្ថជាគំរប់៤ គឺ បលិពោធដ្ឋ នោះមានអត្ថា-ធិប្បាយថា នេះហេតុដល់មគ្គអរិយសច្ច ដើម្បីនឹងឲ្យឃើញច្បាស់ថាសត្វទាំង-ឡាយ មានធុរៈវល់កង្វល់ដោយកិលេសកាមមិនត្រូវកាមៈនោះ ព្រោះតែមិនប្រតិបត្តិតាមមគ្គអរិយសច្ច បើទុះស្ងាត់ប្រតិបត្តិតាមមគ្គអរិយសច្ចហើយ ក៏គាបវលាស់ខ្លួនដោះខ្លួនចេញផុតចាកធុរៈកង្វល់ទាំងពួងបាន ព្រោះតែមិនបានទីកតែប្រែចេញចាកគន្លងផ្លូវប្រតិបត្តិតាមមគ្គអរិយសច្ច ព្រះអង្គទ្រង់ផ្ចាះនឹងឲ្យឃើញសេចក្ដីច្បាស់ថានេះហេតុដល់មគ្គអរិយសច្ចធម៌នេះ ទើបទ្រង់សម្ដែងអត្ថ គឺ បលិពោធដ្ឋ ជាអត្ថនៃមគ្គអរិយសច្ចជាគំរប់៤ ធម៌នេះ ។

«ទុក្ខតាទម្មុក្ខនិរោធោ អរិយសច្ចំ យោ ។ តស្សាយេវ
តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ
អនាលយោ ។ អយំវុច្ចតិ ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ»

---

ពីនេះទៅនឹងបានវិស្សជ្ជនាក្នុងនិរោធអរិយសច្ចតទៅ ៈសេចក្ដីថាសម្ដេចព្រះមហាករុណា កាលបើនឹងត្រាស់ទេសនានិរោធអរិយសច្ចនោះ ទ្រង់សម្ដែងជាកថេតុកម្យតាបុច្ឆាថា ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ និរោធគឺធម៌ជាគ្រឿងរលត់ទុក្ខ ៈ ដែលព្រះអរិយបុគ្គលៈឃើញនោះ តើដូចម្ដេចទើបទ្រង់វិសជ្ជនាដោយព្រះអង្គឯងថា កិរិយារលត់បង់នូវតណ្ហា ១០៨ នោះដោយអរិយមគ្គមិនបានសេសសល់ឯណាក្ដី កិរិយាលះបង់នូវតណ្ហា ១០៨ នោះ ដោយព្រះអរិយមគ្គឯណាក្ដី ទីដ៏កិរិយារួចផុតអំពីតណ្ហា ១០៨ នោះកេការលោះអាល័យគ្មានឯណាក្ដី កិរិយារលត់នឹងលះ-

បន្ទឹងរួចផុតអំពីតណ្ហា ១០៨ រកកពោះអាល័យគ្មាននោះ ៗ ព្រះតថា-
គតពោលបាទនិរោធអរិយសច្ច ទើបកាព្យទោញសិកចូលមកថា អើព្រះដ៏
មានបុណ្យទ្រង់សម្ដែងនិរោធអរិយសច្ចនោះ ដោយចំណែកការលែងទុក្ខ
ផ្សេងទៀត កំហេតុដូចម្ដេចបានជាព្រះអង្គទេសនាថាដោយលែងតណ្ហា
១០៨ នោះវិញ ព្រះអង្គតបកាព្យមានពាក្យវិសជ្ជនាដោះថា ពិតមែនហើយ
ករណីទុក្ខនិរោធនេះ ប្រែថាលែងបន្ទុកករណីទុក្ខទាំងពួង មានជាតិទុក្ខជាដើម
នោះកំមែនដែរ តែថាបើព្រះអង្គទ្រង់សម្ដែងដោយលែងបន្ទុកតណ្ហា ១០៨
ប្រការ ឲ្យកេះសសសល់គ្មានដោយអរិយមគ្គនោះហើយ កំឈ្មោះថាលែង
បន្ទុកករណីទុក្ខដែរ ពីព្រោះថាករណីទុក្ខទាំងពួងមានជាតិទុក្ខជាដើម ជាដើម
ផលដែលកើតពីឫសគល់តណ្ហា ៗ ជាឫសជាគល់ កាលៈបើតណ្ហាមិនទាន់លែង
អស់ស្រឡះដកបណា ករណីទុក្ខទាំងពួងក៏នៅតែកើតមានដរាបតែដកបានោះ
ប្រៀបដូចជាដើមឈើដែលបុគ្គលកាប់ ៗ តែដើមតែមែកការ ត្រង់ឫស
គល់មិនដកគាស់រំលើងចេញ ដើមឈើនោះកំគង់តែទំរុះបំបែកឡើងដូច
ដែល បើបុគ្គលដកគាស់រំលើងឫសគល់អស់កាលណា ដើមឈើនោះក៏មិន
អាចដុះឡើងវិញបាន ហេតុដូច្នោះទើបសម្ដេចព្រះមហាករុណាទ្រង់ត្រាស់
ទេសនាថាលែងបន្ទុកតណ្ហា ១០៨ ឲ្យកេសេសសល់គ្មាន ឈ្មោះថា ទុក្ខ-
និរោធ គឺលែងបន្ទុកករណីទុក្ខទាំងពួង តណ្ហានោះជាហេតុជាបច្ច័យ ករណីទុក្ខ
ទាំងពួងមានជាតិទុក្ខជាដើមនោះជាផល ព្រះយោគាវចរប្រាថ្នានឹងធ្វើឲ្យ
ផុតទុក្ខភ័យក្នុងវដ្ដសំសារ គឺគប្បីទសប្រហារលះបន្ទុកតណ្ហាដ៏ជាហេតុនៃករណី
ទុក្ខនោះ ៗ ឲ្យដាច់ស្រឡះចេញពីសន្ដានកាលឯណា ករណីទុក្ខដ៏ជាផល

ដែលទើបកើតមានតទៅក្នុងកាលមុខនោះក៏ទំនងមិនមានប្រាកដក្នុងកាលនោះ ឯកិរិយាដែលប្រតិបត្តិដើម្បីទទួលផលបន្តទៅតណ្ហានោះ ជាកិច្ចនៃព្រះសម្មា-សម្ពុទ្ធត្រាស់ ព្រះអង្គទ្រង់ប្រតិបត្តិដូចស្ដេចម្រឹគរាជសីហ ឯពួកតិរ្ថិយទាំងពួងនោះប្រតិបត្តិដូចយ៉ាងសុនខ ធម្មតាសុនខនោះជាបើឃើញកំណាត់ឈើចុងដុំដីគប់គ្មលគោលទៅនោះ គឺស្ទុះទៅក្រញាំក់កាំនាំមក ឯខ្លួនមនុស្សអ្នកគោលនោះសុនខមិនបានទាំពារនេះ មានឧបមាដូចម្ដេចមិញ ពួកតិរ្ថិយទាំងពួងក៏ប្រតិបត្តិដូចយ៉ាងសុនខនោះឯង ពួកតិរ្ថិយប្រតិបត្តិប្រាថ្នាទំនងឲ្យបង្កើតទុក្ខក្នុងកាលមុខ ពួកខ្លះប្រព្រឹត្តប្រតិបត្តិដេកលើដែកខង ពួកខ្លះប្រព្រឹត្តប្រតិបត្តិដេកក្នុងបន្ទា ពួកខ្លះប្រតិបត្តិធ្វើកាយឲ្យក្ដៅទាំង ៤ អង្គើ គឺដុតគំនរភ្លើងទាំង ៤ ទិស ហើយអង្គុយក្នុងចំកណ្ដាលហើយសំឡឹងមើលព្រះអាទិត្យផងបងអស្ដង្គតទៅ ប្រតិបត្តិយ៉ាងនេះជាដើម ដោយយល់ក្នុងចិត្តថាប្រតិបត្តិយ៉ាងនេះអាចនឹងនាំខ្លួនឲ្យផុតចាកទុក្ខក្នុងវដ្ដសំសារ ពួកតិរ្ថិយទាំងឡាយរមែងប្រកាន់មិច្ឆាទិដ្ឋិប្រតិបត្តិយ៉ាងនេះជាដើម ដោយស្មានក្នុងចិត្តថានឹងឲ្យរួចចាកទុក្ខ មិនដឹងថានឹងឲ្យកើតក្នុងវដ្ដសំសារ ប្រតិបត្តិយ៉ាងនេះគួរនាដូចសុនខត្រាក់វាំ ពាំយកកំណាត់ឈើនឹងដុំដីដែលគេគោលទៅប៉ុណ្ណោះ មិនទាំពាត្រង់មនុស្សដែលគោលទៅនោះឯង ប្រការ ១ វិញទៀតព្រះយោគាវចរកុលបុត្រក្នុងបវរពុទ្ធសាសនាប្រកបដោយប្រាជ្ញាដ៏ទីងព្យាយាមប្រតិបត្តិកាត់បង់ផែកចេញនូវតណ្ហាឲ្យផុតអស់រលីងចាកសន្ដានគឺគប្បីកាន់យកនូវផ្លូវប្រតិបត្តិដូចយ៉ាងបុរសអ្នកធ្វើចម្ការនោះជាអារម្មណ៍ចុះធម្មតាបុរសអ្នកធ្វើចម្ការ កាលបើឃើញស្មៅយោក ល្មឹងដុះទៀងក្នុងចំការ

ខ្ទះហើយ គឺស្រាវទីដីដើមឈើនោះទាល់តែដល់គល់ ហើយដកលើកអស់ទាំងឫសមិនឲ្យសេសសល់ ហើយចោលទៅឆ្ងាយដើម្បីនឹងមិនឲ្យដុះឡើងទៀតបាន នេះមានឧបមាដូចម្ដេចមិញ ព្រះយោគាវចរកុលបុត្រមានព្យាយាម គឺគប្បីប្រតិបត្តិកាត់បង់នូវឫសកែវ គឺតណ្ហាកុំឲ្យដុះកើតឡើងទៀតបាន មានឧបមេយ្យដូច្នោះ បុរសដែលធ្វើចម្ការនោះប្រៀបដូចព្រះយោគាវចរ ទីដីចម្ការនោះប្រៀបដូចអាយតន ១២ ប្រការ មានចក្ខា-យតនជាដើម អាយតនទាំង ១២ នេះជាទីប្រជុំកើតនៃតណ្ហា ជាអណ្ដូងកើតនៃតណ្ហា ហេតុដូច្នោះទើបសម្ដេចព្រះមហាករុណា ត្រាស់ទេសនាថា តណ្ហានោះជាឫសជាគល់នៃកងទុក្ខទាំងពួង បើលះតណ្ហាបានអស់ចាកសន្ដានហើយ ទុក្ខទាំងឡាយមានជាតិទុក្ខជាដើម ក៏លះអស់ជាមួយគ្នា សម្ដេចព្រះវិជិតមារទ្រង់ត្រាស់ទេសនាថា សាចោបវេឆសា ភិក្ខវេ តណ្ហា ដូច្នេះជាដើមថា ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ គឺតណ្ហានោះដែលបុគ្គលនឹងលះបង់បាន លះបង់បានក្នុងទីដូចម្ដេច រំលត់បានក្នុងទីដូចម្ដេច ទ្រង់វិសជ្ជនាដោយព្រះអង្គឯងថា សភាវធម៌ឯណាដែលជាទីគួរគប្បីស្រ-ឡាញ់ ទីនឹងមានសភាពជាទីត្រេកអរនៅក្នុងលោក តណ្ហានោះកាលបើបុគ្គលនឹងលះបង់បាន ក៏លះបង់បានក្នុងសភាវធម៌ដែលជាទីគួរគប្បីស្រ-ឡាញ់ទីនឹងជាទីត្រេកអរនោះឯង ដែលនឹងរលត់សោតក៏រលត់ក្នុងសភាវធម៌ដែលជាទីគួរគប្បីស្រឡាញ់ទីនឹងជាទីត្រេកអរនោះឯងដែរ នេះឯងហើយបានឈ្មោះថានិរោធអរិយសច្ច កាលសម្ដេចព្រះសារពេជ្ញទ្រង់ត្រាស់ទេសនានូវនិរោធអរិយសច្ចនោះ ព្រះអង្គលើកយកដើមហេតុជាកិច្ចដែល

រលត់តណ្ហា លះបង់តណ្ហាបាន មិនអើពើការណាលំយក្នុងទីខាងមុខ នោះមកសម្ដែងជានិរោធអរិយសច្ច ដោយប្រការដូច្នេះ អ្នកប្រាជ្ញគប្បីជ្រាប ចិត្តដូច្នេះ ថា ការដែលព្រះអង្គលើកយក សមុទយនិរោធ ទៅពោលតណ្ហាមកសម្ដែងជាឈ្មោះនៃនិរោធសច្ចនោះ ប្រាថ្នានឹងឲ្យជាប្រយោជន៍ជាគុណ ដែលនឹងឲ្យគិតពាលណាឃើញផលហេតុតណ្ហា ដូចបាននិពណ៌នាមកដូច្នេះ ក៏នេះនឹងសម្ដែងអត្ថា ឧបការណ៍យ នឹងប្រែក្លាយអត្ថនៃព្រះបាលីដែលព្រះអង្គទ្រង់ប្រោសប្រទានព្រះសម្មាសម្ពុទ្ធ ដែលទ្រង់សម្ដែងថា អសេសវិរាគនិរោធោ នោះ បើនឹងប្រែតាមពាក្យដែលរៀប អសេស បទ១ វិរាគ បទ១ និរោធ បទ១ អសេស នោះប្រែថាមិនមានសេសសល់ វិរាគ នោះប្រែថាអរិយមគ្គ និរោធ នោះប្រែថារលត់ ហេតុដូចម្ដេចបានជា វិរាគសព្ទ ប្រែថាអរិយមគ្គ នឹងមានអត្ថាធិប្បាយយ៉ាងណា ?

ដែលថា វិរាគសព្ទ ប្រែថាអរិយមគ្គនោះ ដោយសេចក្ដីនឹងឲ្យឃើញអត្ថាធិប្បាយថា កាលបើព្រះអរិយមគ្គទាំង ៤ មានព្រះសោតាមគ្គជាដើម មានព្រះអរហត្តមគ្គជាបរិយោសាន ធ្វើព្រះនិព្វានជាអារម្មណ៍ កើតឡើងក្នុងសន្តានហើយនោះ ព្រះសោតាមគ្គក៏លះបង់បាននូវ ទិដ្ឋិសម្បយុត្ត ៤ វិចិកិច្ឆាសម្បយុត្ត ១ ជា ៥ ចិត្ត ព្រះសកទាគាមិមគ្គនោះធ្វើនូវកាម-រាគនឹងព្យាបាទដែលគ្រោតគ្រាតនោះឲ្យស្រាលស្តួចស្តើងជា អណុប្បត្តិនិភេទ ព្រះអនាគាមិមគ្គនោះលះបង់បាននូវកាមរាគនឹងព្យាបាទ ដែលយ៉ាងល្អិតនឹងទោសចិត្តដាច់ចេញអស់ទាំងពីចិត្ត ព្រះអរហត្តមគ្គនោះលះបង់

នូវទិដ្ឋិវិប្បយុត្ត ទាំង ៤ ចិត្តនេះ ឧទ្ធច្ចសម្បយុត្ត ១ ឲ្យសាបសូន្យជាសមុច្ឆេទ នឹងបានសេចក្តីត្រេកអរនៅក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វកាមគុណឯណានីមួយក៏ឥតអង្គើមាន តណ្ហាដែលជាភ្នាក់ងារជាអ្នកកាត់តែងនូវផ្ទះគឺកាយ មានប្រក្រតីធ្វើឲ្យវិលទៅក្នុងភពតទៅមុខ ដែលចំណែកបែកចេញទៅជាកាមតណ្ហា ភវតណ្ហា វិភវតណ្ហា នោះក៏រលត់សូន្យចាកសន្តាននោះៗ មិនបានត្រេកអរក្នុងភព មិនបានត្រេកអរក្នុងកាមគុណឯណានីមួយមិនបានវង្វេងក្នុងអំណាចនៃតណ្ហា អាស្រ័យហេតុដែលនឹងឲ្យឃើញអធិប្បាយយ៉ាងនេះ វិរាគសព្ទ ដែលប្រែថាប្រាសចាកត្រេកអរនោះ ក៏ញែកចេញជាអធិប្បាយថាព្រះអរិយមគ្គ ប្រែតាមអត្ថាធិប្បាយថា ព្រះអរិយមគ្គនេះសមនឹងឧទាហរណ៍ថា វិរាគា វិមុច្ចតិ ប្រែថាបុគ្គលរួចចាកតណ្ហាព្រោះបានសម្រេចនូវអរិយមគ្គ តណ្ហាដែលនឹងប្រាសឃ្លាតចេញពីសន្តាននៃព្រះអរិយបុគ្គលនោះ ក៏អាស្រ័យហេតុដែលព្រះអរិយមគ្គឈោងគាងយកព្រះនិព្វានជាអារម្មណ៍ ព្រះអរិយមគ្គទាំង ៤ មានសោតាបត្តិមគ្គជាដើម មានព្រះអរហត្តមគ្គជាទីបំផុតនោះ ក៏អាស្រ័យហេតុដែលបានព្រះនិព្វានជាឧបនិស្ស័យ បានព្រះនិព្វានជាអារម្មណប្បច្ច័យ ហើយព្រះសោតាបត្តិមគ្គនឹងព្រះសកិទាគាមិមគ្គអនាគាមិមគ្គ ក៏លះបង់បាននូវកិលេសធម៌ទាំងពួងតាមមុខងាររបស់ខ្លួនៗ ដូចបានពណ៌នាមកហើយ ឯជំនាន់ក្រោយឯព្រះអរហត្តមគ្គនោះក៏កំចាត់បង់នូវតណ្ហា ឲ្យវិមុត្តិឃ្លាតចេញចាកសន្តានបានអស់ជាស្រេចជាសមុច្ឆេទប្បហាន ដែលថាសន្តាន នឹងប្រាសចាកសង្កិលេស នឹងប្រាសចាកតណ្ហា នឹងប្រាសចាកសេចក្តីស្នេហា នឹងប្រាស

ចាកសេចក្តីត្រេកអរក្នុងកាមគុណនោះ អាស្រ័យហេតុដែលថាព្រះអរិយ-មគ្គទាំង ៤ ប្រការ បានព្រះនិព្វានជាអារម្មណប្បច្ច័យ ហេតុដូច្នេះវានសព្ទដែលប្រែថាប្រាសចាកត្រេកអរនោះ គឺប្រែជាសេចក្តីអធិប្បាយថាព្រះនិព្វាន ឯនិរោធសព្ទដែលប្រែថាព្រះនិព្វាននោះ ក៏មានអត្ថាធិប្បាយថា កាលបើព្រះអរិយមគ្គទាំង ៤ ធ្វើឲ្យច្បាស់នូវព្រះនិព្វាន លោកកាន់យកព្រះនិព្វានមកជាអារម្មណ៍បានហើយក្នុងកាលឯណា សំកិលេសតណ្ហាក៏រម្ងាប់ស្ងប់ឥតមានអំពីសន្តានដោយលំដាប់ៗ ក្នុងកាលនោះ ត្រូវតែថាសំកិលេសនឹងតណ្ហារលត់ ជាហេតុដោយព្រះអរិយមគ្គទាំង ៤ ប្រការ ហ័កធ្វើព្រះនិព្វានជាអារម្មណ៍បាន អាស្រ័យហេតុដូច្នេះ និរោធសព្ទនោះបានជាលោកប្រែតាមអធិប្បាយថា ព្រះនិព្វាន ឯពាក្យដែលថា វានសព្ទនឹងបដិនិស្សគ្គសព្ទ មុត្តិសព្ទ អនាលយសព្ទ ប្រែថាព្រះនិព្វាននោះសោតក៏មានអត្ថាធិប្បាយថា កាលបើព្រះអរិយមគ្គទាំង ៤ លះបង់បាននូវសំកិលេសនឹងតណ្ហា ផុតអំពីអំណាចនៃសំកិលេសនឹងតណ្ហា មិនបានអើពើអាល័យនៅដោយកាមគុណនោះនឹងកស្រ័យអារម្មណ៍ដទៃនោះឥតអន្លើមានឡើយ ព្រះនិព្វាននោះឯងហើយជាអារម្មណ៍ កាលបើលោកកាន់យកព្រះនិព្វានជាអារម្មណ៍បានក្នុងកាលឯណាហើយ ក៏លះបង់បាននូវតណ្ហាផុតចាកអំណាចនៃតណ្ហា មិនបានអើពើអាល័យទៅដោយកាមគុណក្នុងកាលនោះ ហេតុដូច្នោះវានសព្ទនឹងបដិនិស្សគ្គសព្ទ មុត្តិសព្ទ អនា-លយសព្ទទាំង ៤ សព្ទនេះ បានជាប្រែតាមអធិប្បាយថាព្រះនិព្វានបាន បើនឹងពោលដោយលក្ខណៈ ព្រះនិព្វាននោះមានលក្ខណៈរម្ងាប់សភាវជាបច្ច័យ

ឲ្យផ្តាច់បង់នូវលោភ ទោស មោហ ផ្តាច់បង់នូវអវិជ្ជានិងតណ្ហា ផ្តាច់បង់នូវសំកិលេសទាំងពួងដែលធ្វើឲ្យសៅហ្មង ឲ្យវិលស្លាប់កើតវិលយកកំណើតក្នុងវដ្តសង្សារ នេះឯងជាលក្ខណនៃព្រះនិព្វាន បើនឹងពោលដោយកិច្ច ព្រះនិព្វានមានកិច្ចមិនបានចុតិ មិនដូចសង្ខារធម៌ទាំងឡាយគឺនាមនិងរូប ដែលកុសលនិងអកុសលប្រជុំតាក់តែងនោះរមែងផ្លាស់នូវសភាវៈកើតឡើងនិងរលាយ ហេតុដូច្នេះឯង បានជាថាកិច្ចដែលមិនបានចុតិនេះជាកិច្ចព្រះនិព្វាន អធិប្បាយតាមពាក្យដីកាចារ្យថា ព្រះនិព្វាននោះមានអាការដូចជានឹងប្រលោមចិត្តនៃបុគ្គល ដែលមានសន្តាននឿយណាយចាកសង្សារទុក្ខដែលមានសេចក្តីក្តៅក្រហល់ឲ្យប្រាសចាកសេចក្តីក្តៅក្រហល់ឲ្យស្ងៀមយាត្ត ស្ងៀមក្តៅក្រហាយ ឲ្យរីករាយនូវក្នុងសន្តាន បើនឹងពោលដោយផលនៃព្រះនិព្វាន តាមអធិប្បាយនៃចុល្លដីកាវាក្យនោះថា ព្រះនិព្វាននេះប្រាសចាកសង្ខតនិមិត្តជាផល អធិប្បាយថាសង្ខតនិមិត្តគឺកុសលនិងអកុសល ដែលជាហេតុជាបច្ច័យប្រជុំតាក់តែងនាមនិងរូបឲ្យវិលកើតយកកំណើតក្នុងភពទាំងបី គឺកាមភព រូបភព អរូបភពនោះ និងបានហៅក្នុងព្រះនិព្វានធម៌នោះឥតអត្ថិមាន បបញ្ចធម៌ទាំងពួងមានកងបបញ្ចជាដើម ដែលធ្វើឲ្យសត្វទាំងឡាយយឺតយូរនៅក្នុងវដ្តសង្សារនោះសោត ក៏មិនដែលមានក្នុងព្រះនិព្វាន ។ នេះជាបច្ច័យឲ្យលះបង់នូវកតាទិបបញ្ច ហេតុដូច្នេះបានជាពោលថា ព្រះនិព្វានធម៌នោះមានសភាវប្រាសចាកសង្ខតនិមិត្តជាផល មានសភាវជាហេតុឲ្យលះបង់នូវបបញ្ចធម៌ មានកងជាដើមជាផលដោយប្រការដូច្នេះ ព្រះអដ្ឋកថាចារ្យកាលបើ.

សម្តែងលក្ខណៈទីពឹងនឹងផលនៃព្រះនិព្វានដូចន័យផ្សេងៗ ដែលបានពណ៌នាមកហើយក្នុងខាងក្រោយ គឺលោកពិចារណាឃើញថា សំដៅសតទៅខាងមុខប្រាថ្នាកុសលបុត្រនឹងជួយចុះកល់ជាន់កល់ថ្នាក់ ទើបចូលចិត្តជឿប្រកាន់ថាព្រះនិព្វាននោះមានទៅ ខ្លះក៏ទើបឃើញថាព្រះនិព្វាននោះមិនមាន អ្នកដែលជឿប្រកាន់ថាព្រះនិព្វានមានទៅនោះសោតក៏ទើបចូលចិត្តនោះផ្សេងៗ គឺ អ្នកខ្លះទើបចូលចិត្តថា អតីតអនាគតក្ខន្ធ ដែលមិនមានក្ខន្ធបច្ចុប្បន្នក្ខន្ធនោះជាព្រះនិព្វាន អ្នកខ្លះក៏ទើបចូលចិត្តថាដែលមិនមានបច្ចុប្ប-ន្នក្ខន្ធនោះជាព្រះនិព្វាន • អ្នកខ្លះក៏ទើបចូលចិត្តថាសភាវមិនមានកិលេសក្ខន្ធៗណាដែលព្រះអរិយមគ្គកើតនោះជាព្រះនិព្វាន អ្នកខ្លះក៏ចូលចិត្តថាសភាវអស់ទៅនៃរាគៈទោសៈមោហៈនោះជាព្រះនិព្វាន ទើបចូលចិត្តផ្សេងៗគ្នាយ៉ាងនេះជាដើម ហើយក៏ទើបវិវាទដណ្ដើមគ្រាកល់គ្នាមិនដាច់ស្រេចទៅខាងណា គេអ្នកវិនិច្ឆ័យកាត់សេចក្ដីមិនបាន ក៏ទើបកើតជាបម្រើចប្រែសក្ខន្ធព្រះពុទ្ធសាសនា ព្រះអដ្ឋកថាចារ្យពិចារណាឃើញហេតុយ៉ាងនេះ ទើបតាំងជាពាក្យបុច្ឆា វិសជ្ជនាទុក ដើម្បីនឹងឲ្យកាត់សេចក្ដីសង្ស័យនៃកុលបុត្រដែលនឹងកើតជាចំណែកខាងមុខ ឯពាក្យបុច្ឆាជាបឋមនោះថា តត្ថនិព្វានំព្រះនិព្វាននោះបុគ្គលឯណានីមួយនឹងបានគប់ប្រសព្វជាប់ឃើញរូបពណ៌សណ្ឋានថាប្រការដូចម្ដេចៗ នោះក៏ឥតអង្គមាន ពាក្យដែលថាព្រះនិព្វាននោះកាលបើពីគ្រោះទៅដូចកំណោះគ្រូវោហារ ដែលហៅថាស្មើនឹងខ្សាយពាក្យដែលលោកវោហារពោលថាស្មើនឹងខ្សាយៗ នោះ ជាពាក្យមិនពិតពាក្យនេះតើមានឧបមាដូចម្ដេច ពាក្យដែលថាព្រះនិព្វានមាននោះ យើង

គឺឃើញថាជាភាគរួមមិនពិតទេ មានឧបមេយ្យដូច្នោះឯង ឯអត្ថស្រើយ
យើងនេះពិចារណាឃើញថាព្រះនិព្វានគ្មាន ដូចស្នែងទន្សាយដែរ ៗ
វិសជ្ជនាថា ដែលអ្នកនឹងយកព្រះនិព្វានមកប្រៀបនឹងស្នែងទន្សាយនេះ
មិនសមគួរសោះ នឹងយកអធិប្បាយថា ស្នែងទន្សាយមិនមានយ៉ាងណា
ព្រះនិព្វានមិនមានយ៉ាងនោះ អ្នកនឹងប្រកាន់យកអធិប្បាយយ៉ាងនេះពេញ
ជាខុសណាស់ ព្រោះព្រះនិព្វាននោះបុគ្គលអ្នកជាកល្យាណបុថុជ្ជនគប្បី
ដឹងដោយឧបាយពិត ៗ កល្យាណបុថុជ្ជនទាំងឡាយដែលបានស្តាប់ត្រាប់
ត្រងត្រសេព្រះធម្មទេសនាចូលចិត្តហើយគំនិតថា ព្រះនិព្វានមានជាពិត
ដោយន័យព្រះពុទ្ធដីកាដែលព្រះអង្គទ្រង់ត្រាស់ប្រទានព្រះធម្មទេសនា
ហើយមានសេចក្តីស្រឡាញ់ប្រតិបត្តិគុណ សីលគុណ សមាធិគុណ បញ្ញាគុណ
ដោយសមគួរដល់ពុទ្ធដីកានោះ គឺមុខគួរជាទីនឹងបានឃើញនឹងបានសម្រេច
នូវព្រះនិព្វានដោយជាក់ច្បាស់ក្នុងសន្តាន ដោយកាលកំណត់ជាប់ប៉ុយូរ
តាមសមគួរដល់កសាងបារមីនៃខ្លួនដែលបានសាងសន្សំអប់រំមក តែថា
បើនឹងបានសម្រេចនូវព្រះនិព្វាននោះ បានតែបុគ្គលដែលប្រកបដោយ
ឧបាយ គោលគឺសេចក្តីស្រឡាញ់ប្រតិបត្តិដោយសមគួរតាមពុទ្ធដីកានោះ
ដែរ ឯបុគ្គលជាពាលបុថុជ្ជនដែលមិនបានប្រតិបត្តិតាមពុទ្ធដីកានោះ គឺនឹង
គន្លងដឹងគន្លងឃើញទៅបាន ព្រះនិព្វាននេះចំពោះឃើញជាក់ច្បាស់ក្នុង
សន្តាននៃព្រះអរិយបុគ្គលនោះ ពាលបុថុជ្ជននឹងគន្លងដឹង គន្លងឃើញ
ទៅបាន នឹងដឹងឃើញបានតែលោកដែលជាព្រះអរិយបុគ្គលដែលបាន
សម្រេចចេតោបរិញ្ញាដូចគ្នា ទុកជាលោកដែលបានសម្រេចចេតោបរិញ្ញា

ដូចគ្នាក៏មែន តែថាខ្លួនបានសម្រេចមគ្គផលយ៉ាងទាប គឺមិនអាចនឹងដឹង
នឹងឃើញនូវលោកុត្តរចិត្ត នៃលោកដែលបានសម្រេចមគ្គផលយ៉ាងខ្ពស់
ស្រេចតែថាដឹងពីរចិត្តគ្នានោះតាមជាន់តាមថ្នាក់ជាលំដាប់ ៗ គ្នា នឹងបាន
ដូចទៅសព្វតែកល់គ្នានោះក៏ឥតអគ្គិមាន លោកដែលជាព្រះសោតាបន្នបាន
ចេតោបរិញ្ញានោះ គឺចំពោះដឹងបានតែចិត្តនៃបុថុជ្ជន នឹងចិត្តនៃលោកដែល
សម្រេចសោតាបត្តិផលដូចគ្នាមិនអាចនឹងដឹងរម្លងឡើងទៅដល់ចិត្តនៃព្រះ
សកិទាគាមិ ឯព្រះសកិទាគាមិដែលបានសម្រេចចេតោបរិញ្ញានោះ ក៏ដឹង
ចំពោះតែចិត្តនៃបុថុជ្ជននឹងចិត្តនៃព្រះសោតាបន្ន នឹងចិត្តនៃព្រះសកិទាគាមិ
ដូចគ្នា មិនអាចនឹងដឹងរម្លងឡើងទៅដល់ចិត្តនៃព្រះអនាគាមិ ព្រះអរហន្ត
បានតែព្រះអរហន្តដែលបានសម្រេចចេតោបរិញ្ញានោះឯង ទើបនឹងដឹង
ច្បាស់នូវលោកុត្តរចិត្ត ព្រះអរិយបុគ្គលទាំងអស់ឥតមានសេសសល់ នេះ
ឯងហើយបណ្ឌិតគប្បីសន្និដ្ឋានចូលចិត្តថា សូម្បីតែព្រះអរិយបុគ្គលនឹងព្រះ
អរិយបុគ្គលដូចគ្នា គង់ដឹងពីរចិត្តគ្នាដោយជាន់ដោយថ្នាក់ដូច្នេះ នឹងបាច់
និយាយទៅថ្វីដល់កាលបុថុជ្ជនដែលមានបញ្ញាខ្សោយទៅដោយកិលេស
ក្រាស់ បុថុជ្ជនណាអាចនឹងដឹងនូវលោកុត្តរចិត្ត ១ៈនោះដឹងចំពោះតែព្រះ
អរិយបុគ្គលដែលបានសម្រេចចេតោបរិញ្ញាដូចគ្នានេះ ម្តេចក៏ស្មើតែនឹង
មិនដឹង ព្រះនិព្វានធម៌នោះ គឺដឹងចំពោះតែក្នុងចិត្តសន្តាននៃព្រះអរិយ-
បុគ្គលប៉ុណ្ណោះ ដែលមិនបានដូចច្នេះមិនបានដឹងមិនបានយល់ព្រះនិព្វាន
នោះ តែកាលបុថុជ្ជនដែលក្រាស់ទៅដោយកិលេសនោះឯង កល្យាណ-
បុថុជ្ជនដែលប្រតិបត្តិសមគួរតាមក្បួនខ្នាតហើយ គឺអាចនឹងបានសម្រេច

នូវព្រះនិព្វានដោយពិត តាមកំសាងបារមីរបស់ខ្លួន អាស្រ័យហេតុដូច្នេះ ដែលអ្នកទីពីរប្រកាន់អធិប្បាយថា ពាលបុថុជ្ជនមិនបានព្រះនិព្វានទេ ទីពីរប្រកាន់យ៉ាងនេះមិនត្រូវឡើយ ទុតិយវាទី ម្នាលអាចារ្យ អ្នកកុំគប្បីពោលថាព្រះនិព្វានមិនមាន បើអ្នកយល់តែតាមអធ្យាស្រ័យរបស់អ្នកថា ពាលបុថុជ្ជនមិនបានព្រះនិព្វានសោះ ព្រះនិព្វានគ្មានសោះ អ្នកឃើញយ៉ាងនេះពេញជាខុសទំនងព្រះពុទ្ធដីកាសម្ដេចព្រះមហាសាស្ដាចារ្យទ្រង់សម្ដែងសរសើរសម្មាប្រតិបត្តិថាជាអនវជ្ជធម៌ សម្មាប្រតិបត្តិទាំង ៨ ប្រការនោះតាំងអំពីសម្មាទិដ្ឋិជាដើម ដរាបដល់សម្មាសមាធិជាទីបំផុត សម្ដេចព្រះសុគតទ្រង់ទេសនាសង្គ្រោះចូលក្នុងខន្ធ ៣ គឺ សីលក្ខន្ធ សមាធិក្ខន្ធ បញ្ញាក្ខន្ធ សម្មាទិដ្ឋិនឹងសម្មាសង្កប្បរាប់ចូលក្នុងបញ្ញាក្ខន្ធ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវៈរាប់ចូលក្នុងសីលក្ខន្ធ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិរាប់ចូលក្នុង សមាធិក្ខន្ធ សម្មាប្រតិបត្តិទាំង៨ប្រការនេះ សម្ដេចព្រះសាស្ដាចារ្យទ្រង់សរសើរថាជាអនវជ្ជធម៌ ដោយអំណាចកាត់កិលេសឲ្យសោះសូន្យឲ្យដល់នូវព្រះអមតនិព្វាន បើព្រះនិព្វានមិនមានមែនដូចពាក្យអ្នកថា សម្មាប្រតិបត្តិទាំង៨ប្រការ ក៏មិនបានជាអនវជ្ជធម៌ មិនអាចនឹងកំចាត់បង់នូវកិលេសឲ្យសោះសូន្យបាត់សន្តានបានឯសម្មាប្រតិបត្តិជាអនវជ្ជធម៌នោះដោយអំណាចដែលបានឈានទៅកាន់យកព្រះនិព្វានមកជាអារម្មណ៍ សម្លាប់កិលេសបានហើយទើបថាអនវជ្ជធម៌បាន ព្រោះតែសម្លាប់នូវកិលេសនោះឯង បើព្រះនិព្វានមិនមាន សម្មាប្រតិបត្តិឥតអ្វីជាទីឈានប្រកាន់សម្លាប់កិលេសបាន

ទៀត ពាក្យដែលថាសម្មាប្បដិបត្តិជាអនុវត្តធម៌នោះ គឺខុសទៅហើយ ឬអាចារ្យជាអ្នកពោល បើអ្នកនឹងពោលថាសម្មាប្បដិបត្តិទាំង ៨ ប្រការជាអនុវត្តធម៌ ដោយអំណាចជាឧបាយឲ្យផ្តាច់បង់នូវកិលេសហើយឲ្យដល់នូវកិរិយារលត់ទុក្ខមិនឲ្យមានទុក្ខបញ្ចុកតទៅ អាស្រ័យហេតុដែលឲ្យដល់នូវសេចក្តីរលត់ទុក្ខនេះឯងហើយ ទើបបានយើងយល់ថាសម្មាប្បដិបត្តិជាអនុ-វត្តធម៌នៅដោយពិត សម្មាប្បដិបត្តិនឹងបានជាអនុវត្តធម៌ ដោយអំណាចដែលឲ្យដល់នូវព្រះនិព្វានគឺសភាវដ្ឋានឡើយ បើអ្នកថាដូច្នេះ ពាក្យអ្នកដែលពោលថាឲ្យដល់ព្រះនិព្វានមិនទាន់នោះ ទើបពាក្យក្រោយដែលអ្នកទទួលមកថាសម្មាប្បដិបត្តិជាអនុវត្តធម៌ ដោយអំណាចជាឧបាយឲ្យរលត់កិលេសហើយសម្រេចកិរិយារលត់ទុក្ខនោះ ពាក្យទាំងពីរនេះគឺល្អបលាស់តែគ្នាឯង ពាក្យដែលថាសម្មាប្បដិបត្តិជាអនុវត្តធម៌ដោយអំណាចជាឧបាយឲ្យផ្តាច់បង់នូវកិលេសឲ្យសម្រេចនូវកិច្ចរលត់ទុក្ខ នេះឯងជាពាក្យបដិញ្ញាណាថាព្រះនិព្វានមានគុណអធិប្បាយរបស់អ្នកបដិញ្ញាណថា សភាវមិនមានទុក-បញ្ចុក ១ មិនមាននោះជាព្រះនិព្វាន ពាក្យបដិញ្ញាណរបស់អ្នកនេះមិនទាន់ត្រូវនៅឡើយទេ ហេតុអ្វី ហេតុថាអតីតក្ខន្ធអនាគតក្ខន្ធមិនមានគួរបច្ចុប្បន្ននេះ ដែលនឹងបាត់យកជាព្រះនិព្វាននឹងបានឈ្មោះថាដល់នូវព្រះនិព្វាននោះក៏ទេ ម្នាលអាចារ្យជាអ្នកពោល កាលបើពិគ្រោះមើលទៅតាមន័យរបស់អ្នកដែលថាទុក្ខបញ្ចុកមិនមាននោះ ទើបថាជាខន្ធអតីត ឬខន្ធអនាគត ឬខន្ធបច្ចុប្បន្ន បើជាខន្ធបច្ចុប្បន្នហើយគឺនឹងថាមិនមានដូចម្តេចទៅ ព្រោះឈ្មោះបច្ចុប្បន្នហើយក៏គង់មាននៅជាពិត ទើបបានឈ្មោះថាបច្ចុប្បន្ន ខន្ធ

ឯណា មានទៅជាពិតហើយ ខន្ធនោះក៏បានឈ្មោះថាបច្ចុប្បន្នក្ខន្ធ ឯពាក្យ អ្នកដែលថាខន្ធមិនមាននោះ ចំនឹងជាខន្ធអតីតជាខន្ធអនាគត ហេតុអ្វី ហេតុដូច្នោះទើបបានជាខន្ធជាអតីតខន្ធជាអនាគតឈ្មោះខន្ធមិនមាន ។ អធិប្បាយតាមពាក្យដីកាចារ្យថា ខន្ធដែលជាអតីតអនាគតខន្ធមិនមាននោះ ព្រោះហេតុថា មិនមានទៅក្នុងបច្ចុប្បន្នពិត ខន្ធដែលជាអតីតនោះបានឈ្មោះថាមិនមាន ព្រោះហេតុថារលត់ក្នុងដំហួសទៅហើយក្នុងអតីត មិនមានទៅក្នុងបច្ចុប្បន្ន ខន្ធដែលជាអនាគតនោះសោតក៏បានឈ្មោះថាមិនមាន ព្រោះថាមិនទាន់មកកើត សភាពមិនមានយ៉ាងនេះ បើនឹងឃើញថាជាព្រះនិ-ព្វានហើយ ព្រះនិព្វានក៏នឹងបានទូទៅក្នុងសន្តាននៃសត្វទាំងឡាយ ដែលជាអតីតក្ខន្ធអនាគតក្ខន្ធនោះ ទំនងហានទៅក្នុងបច្ចុប្បន្ននេះក៏ឥតអង្គមានឡើយ ហេតុនេះបណ្ឌិតគប្បីសន្និដ្ឋានចូលចិត្តចុះថា ខន្ធដែលជាអតីតអនាគត ទុកជាគ្មានក្នុងបច្ចុប្បន្នទំនងចាត់ថាជាព្រះនិព្វាន ថាដល់នូវព្រះនិព្វាននោះ ថាមិនបានទេ អាការដែលមិនមានឃើញប្រាកដយ៉ាងនេះមិនបានឈ្មោះថាដល់នូវព្រះនិព្វាន លុះតែកាលណាខន្ធដែលតាំងនៅក្នុងខន្ធទាំង ៣ គឺអតីត អនាគត បច្ចុប្បន្ន មិនមានព្រមទាំង ៣ ស្ថានហើយទើបចាត់ថាជាព្រះនិព្វានបាន ដែលមិនមានខន្ធគ្រាន់តែជាឯកទេសមិនមាន នោះនឹងហៅថាព្រះនិព្វានមិនសមគួរទេ ក្នុងទីនេះពិចារណាឃើញដោយអត្ថនោមតិថា ចំណែកអ្នកចោទ្យនោះ កាលបើឃើញគួរតាមពាក្យចម្លើយ ដោយស្រេចក្នុងទីដែលឃើញថាព្រះនិព្វានមានពិតមែន អ្នកចោទ្យប្រកាន់លទ្ធិថា ខន្ធដែលរលត់ហើយក្នុងទីទៅ ៗ នោះ ទុកជារលត់

មិនបានជាអនុប្បត្តិនិរោធលោកមិនបានដាច់កំគង់នៅជាកំញើមកំទេចពូជឲ្យ
បង្កើតខន្ធដទៃតទៅទៀតក្ដី អាការដែលលោកគ្រាន់តែជាខណៈៗ គ្រាន់តែ
ជាឯកទេសក្ដី គឺចាត់ឈ្មោះថាជាព្រះនិព្វានបាន ចំណែកអាចារ្យអ្នក
ឆ្លើយក៏ដោះថា ខន្ធដែលលោកហើយនៅគង់កំញើមកំទេចពូជឲ្យបង្កើតខន្ធ
ដទៃជាដំណទៅ លោកមិនបានជាអនុប្បត្តិនិរោធលោកមិនបានដាច់ផ្ដោះ
បើនឹងចាត់យកជាព្រះនិព្វានហើយព្រះនិព្វានក៏នឹងសម្រេចខ្លួនទៅផ្ដល់សត្វ
ទាំងពួងដោយហោចសូម្បីតែសត្វតិរច្ឆានក៏នឹងបានឈ្មោះថាសម្រេចព្រះ
និព្វានដែរ ហេតុថាទាត់យកកិរិយាដែលលោកមិនដាច់ផ្ដោះ អាការដែល
លោកខន្ធគ្រាន់តែជាខណៈៗ ជាឯកទេសលោកមិនដាច់ផ្ដោះ បើនឹងចាត់
យកជាព្រះនិព្វានហើយ ចិត្តដែលកើតរលំជាខណៈៗ ហើយលោកគង់
ទៅក្នុងសន្តានៃសត្វទាំងឡាយនេះក្តី ខណៈចិត្តដែលនៅមិនទាន់បង្កើត
ក្នុងខាងមុខនោះក្ដី គឺនឹងបាននាមបញ្ញត្តិៈឈ្មោះថាព្រះនិព្វានទាំងអស់នោះ
ព្រោះខណៈចិត្តដែលលោកក្នុងទៅជាអតីតខណៈនោះ នឹងបានមាននៅក្នុង
បច្ចុប្បន្នក្ខណៈនោះក៏ទេ ខណៈចិត្តដែលនៅមិនទាន់បង្កើតក្នុងខាងមុខនោះ
សោតនឹងបានមាននៅក្នុងបច្ចុប្បន្នខណៈនេះក៏ទេដែរ នេះឯងទើបបានឃើញ
ឃើញថាកិរិយាដែលលោកមិនបានជាអនុប្បត្តិនិរោធលោកមិនដាច់ លោក
ហើយនៅមានកំញើមពូជឲ្យកើតខន្ធដទៃតទៅទៀតនោះ នឹងបានឈ្មោះ
ថាដល់នូវព្រះនិព្វានក៏ទេ ពិចារណាឃើញដោយអត្តនោមតិនៃខ្លួនដោយ
ប្រការដូច្នេះៗ លុះដាច់នោះអ្នកឆ្លើយពោលដោះថា ម្នាលអាចារ្យអ្នកចោទ
បើអ្នកនឹងមានពាក្យឡើងទៀតថា សភាវលោកខន្ធដែលជាបច្ចុប្បន្ន មិនមានខន្ធ

ជាបច្ចុប្បន្ននោះឯង៏ឈ្មោះព្រះនិព្វាន បើអ្នកនឹងមានពាក្យថាយ៉ាងនេះ ទៀតក៏មិនគួរ ហេតុអ្វី ហេតុថាព្រះនិព្វានកើតអំពីខន្ធជាបច្ចុប្បន្ននោះ បើថាខន្ធជាបច្ចុប្បន្នគ្មានហើយព្រះនិព្វានក៏គ្មានដែរ ម្យ៉ាងវិញទៀតថា ខន្ធឯណាមិនមាន ខន្ធនោះក៏មិនបានឈ្មោះថាបច្ចុប្បន្នក្ខន្ធ ស្រេចតែថាខន្ធ ឯណាជាបច្ចុប្បន្ន ខន្ធនោះបាននៅកើត ឯខន្ធមិនទាន់ហើយ ខន្ធនោះក៏ មិនបានជាបច្ចុប្បន្ន តើដំណើរដែលអ្នកថាមិនបានមានខន្ធជាបច្ចុប្បន្នបាន ឈ្មោះថាព្រះនិព្វាននោះ ពាក្យអ្នកឯងក៏ខុសពាក្យឯង កាលបើខន្ធជា បច្ចុប្បន្នមាននៅហើយ ដូចម្ដេចក៏យកមកពោលថាគ្មានវិញ តែបើជា បច្ចុប្បន្នហើយក៏មាននៅជាពិត ទើបនឹងហៅថាជាបច្ចុប្បន្នក្ខន្ធ នេះឯង អ្នកគប្បីចូលចិត្តចុះ ថាពាក្យដែលអ្នកបដិសេធថាបច្ចុប្បន្នក្ខន្ធនោះបដិ-សេធខុសទេ បើការមានបច្ចុប្បន្នក្ខន្ធនៅនេះទើបឲ្យសម្រេចព្រះនិព្វាន បាន ដែលបើនឹងត្រាស់ដឹងនូវព្រះនិព្វាននោះក៏អាស្រ័យនឹងបច្ចុប្បន្ន ក្ខន្ធ បើមិនមានបច្ចុប្បន្នក្ខន្ធជាទីអាស្រ័យហើយ ក៏មិនបានសម្រេចព្រះ និព្វានឡើយ ព្រោះថាព្រះនិព្វាននេះជាអារម្មណ៍នៃព្រះអរិយមគ្គអរិយ-ផល ព្រះអរិយមគ្គដែលធ្វើព្រះនិព្វានជាអារម្មណ៍មកបង្កើតបាននោះ ក៏អាស្រ័យនៅខន្ធទាំង ៤ ដ៏ជាបច្ចុប្បន្ន ទុកជាបុគ្គលដែលកើតក្នុងអរូប-ភពគ្មានរូបក្ខន្ធ ក៏នៅមានវេទនាក្ខន្ធ សញ្ញាក្ខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ខន្ធដែលជាបច្ចុប្បន្ននោះជាទីអាស្រ័យ ជាទីទទួលនៃព្រះអរិយមគ្គធ្វើព្រះ និព្វានជាអារម្មណ៍នោះ ទើបព្រះអរិយមគ្គនឹងមកកើតបាន អ្នកប្រាជ្ញគប្បី សន្និដ្ឋានចូលចិត្តថា ឧបចារដែននឹងអនុលោមដែនគោត្រភូដែនកើតមាន

ក្នុងមគ្គវិថីនោះ សុទ្ធតែតាំងជាបច្ចុប្បន្ន វិញ្ញាណក្ខន្ធទាំងអស់ ទុកជាមគ្គចិត្ត ដែលធ្វើព្រះនិព្វានជាអារម្មណ៍នោះសោតក៏តាំងឈ្មោះថាវិញ្ញាណក្ខន្ធជាបច្ចុប្បន្ន ហេតុដូច្នេះទើបយើងឃើញថាព្រះនិព្វាននឹងប្រព្រឹត្តទៅបានសម្រេចទៅបាននោះ អាស្រ័យនឹងបច្ចុប្បន្នក្ខន្ធ បើគ្មានបច្ចុប្បន្នក្ខន្ធជាទីអាស្រ័យហើយក៏មិនអាចនឹងបានសម្រេចព្រះនិព្វានបានឡើយ ម្នាលអាចារ្យ ដែលអ្នកនឹងយល់ថាគ្មានបច្ចុប្បន្នក្ខន្ធនៅក្នុងនិព្វាននេះមិនគួរ បើអ្នកនៅតែចចេសយល់ដូច្នោះ ពាក្យដែលអ្នកថាព្រះអរិយបុគ្គលដែលបានសម្រេចឧបាទិសេសនិព្វានពាក្យ ពោលតែកិលេស បញ្ចក្ខន្ធមិនទាន់លត់ ពាក្យនេះក៏នឹងទៅជាខុស សឧបាទិសេសនិព្វានអាស្រ័យនឹងមិនមាន នេះបើដូច្នោះ សឧបាទិសេសនិព្វានមាននៅ ព្រះអរិយមគ្គដែលធ្វើព្រះនិព្វានជាអារម្មណ៍ អាស្រ័យនូវបច្ចុប្បន្នក្ខន្ធ ហើយកើតឡើងនោះមាននៅដោយពិត ព្រះអរិយបុគ្គលដែលនឹងសម្រេចសឧបាទិសេសនិព្វានពោលគឺលត់តែកិលេស បញ្ចក្ខន្ធជាបច្ចុប្បន្នមិនទាន់លត់ទៅឡើយ គង់ប្រព្រឹត្តនៅប្រាសសត្តទាំងក្នុងនៅឡើយ នេះឯងហើយទើបយើងឃើញច្បាស់ថាដំ-ណើរដែលអ្នកកាន់យកអធិប្បាយថា សភាវមិនមានបច្ចុប្បន្នក្ខន្ធជាព្រះនិព្វាននោះមិនគួរសោះ ម្នាលអាចារ្យជាអ្នកចេះ បើអ្នកនឹងមានពាក្យសិកចូលមកទៀតថា ដំណើរដែលថាគ្មានបច្ចុប្បន្នក្ខន្ធជាព្រះនិព្វាននោះពាក្យយើងមិនខុសទេ ហេតុអ្វីហេតុដែលថាបច្ចុប្បន្នក្ខន្ធនោះយើងពោលដោយក្នុងកិលេសទេតើ រូបក្ខន្ធ..វេទនាក្ខន្ធ សញ្ញាក្ខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ យើងមិនបានហៅបច្ចុប្បន្នក្ខន្ធទេ ក្នុងវេលាព្រះអរិយមគ្គធ្វើព្រះនិព្វានជា

អារម្មណ៍ហើយកើតឡើងក្នុងលំដាប់នៃគោត្រភូវិថីនោះ ព្រះអរិយមគ្គនឹងបានកំចាត់បង់នូវកិលេសខន្ធដោយខ្លួនឯងក៏ឥតអង្គីមាន លុះតែកិលេសខន្ធនោះអស់ទៅដោយអំណាចអនុលោម ដ៏កើតព្រមដោយអនុលោមទាំង ៣ នោះហើយ អាស្រ័យនូវកិលេសខន្ធដែលអស់ទៅមុន មិនមានកង្វល់ណា : ដែលព្រះអរិយមគ្គកើតនេះឯងបានជាលោកយល់អធិប្បាយថា សភាវមិនមានបច្ចុប្បន្នក្ខន្ធនោះឯងជាព្រះនិព្វាន បើអ្នកឯងនឹងមានពាក្យសួរទៀតចូលមកទៀត ដូច្នេះថា ន យុត្តំ ពាក្យអ្នកក៏ទៅមិនទាន់គួរនៅឡើយ ហេតុអ្វីហេតុប្រកាន់អធិប្បាយយ៉ាងនេះហើយ ព្រះអរិយមគ្គក៏ផល់នូវការឥតប្រយោជន៍ ឯព្រះអរិយមគ្គនេះប្រកបដោយប្រយោជន៍ជាច្រើនណាស់ កាត់ឬសកាត់គល់នៃកិលេសធម៌ទាំងភ្លឺបាន កិលេសដែលអស់ទៅដោយអំណាចអនុលោមញាណក្នុងខណៈអនុលោមវិថីទាំង ៣ នោះ អស់ទាំងកិលេសយ៉ាងគ្រោតគ្រាត យ៉ាងកណ្ដាល យ៉ាងល្អិត បណ្ដាដែលធ្វើឲ្យល្អក់ឲ្យសៅហ្មងក្នុងសន្តានព្រះអរិយមគ្គ កិលេសដែលជាមន្ទិលបិទបាំងមិនឲ្យឃើញនូវព្រះនិព្វាននោះសោត អនុលោមវិថីក៏កំចាត់បង់បានអស់ជាស្រេច នឹងនៅសល់ក៏តែអនុសយាជាឫសកែវយ៉ាងចុះចាក់ស្រែះមាំ អនុលោមវិថីមិនអាចនឹងដកឡើងបាន អនុលោមវិថីកំចាត់បង់បានតែកិលេសដែលយ៉ាងគ្រោតគ្រាតនិងយ៉ាងកណ្ដាល យ៉ាងល្អិតនេះមានឧបមាដូចជាបុគ្គល ៣ ពួកទៅរើសផ្លែស្វាយ ពួកមួយជាដំបូង រើសយកតែផ្លែធំ ១ នាំយកទៅ ពួកបន្ទាប់ជាគំរប់ពីរនោះ រើសយកតែយ៉ាងកណ្ដាល ១ នាំយកទៅ ពួកខាងក្រោយជាគំរប់បីនោះ រើសយកផ្លែតូចៗទាល់តែអស់លើដើមឥតមានសេសសល់សោះ ឯដើមស្វាយនោះឥតមានអ្នក

ឯណានឹងកាប់រំលំដើមឫសគល់ ដល់ឆ្នាំក្រោយទៀតដល់កំណត់ទេសកាល គឺលាស់ត្រួយបញ្ចេញផ្កាផ្លែមកទៀត នឹងបានដាច់អស់ផុតគ្មានផ្កាគ្មានផ្លែគឺឥតអត្ថិមានឡើយ នេះគឺមានឧបមាដូចម្ដេចមិញ ផ្លែស្វាយយ៉ាងធំយ៉ាងកណ្ដាល យ៉ាងល្អិតនោះមានឧបមេយ្យដូចកិលេសយ៉ាងគ្រោតគ្រាតយ៉ាងធំៗ យ៉ាងកណ្ដាលយ៉ាងល្អិត បុគ្គល ៣ ពួកដែលរើសផ្លែស្វាយនោះ មានឧបមាដូចអនុលោមជវនទាំង ៣ ដ៏កំចាត់បង់នូវកិលេសយ៉ាងថ្លោសគ្រោតគ្រាតយ៉ាងកណ្ដាល យ៉ាងល្អិតឯកិលេសដែលភ្លាត់ចេញចាកសន្តានដោយអំណាចអនុលោមទាំង ៣ នោះ បើមិនមានព្រះអរិយ-មគ្គកាត់ផ្ដាច់ឫសគល់មូលហេតុគឺអនុសយធម៌ចេញបានទេ អនុសយមាននៅដរាបណា កិលេសក៏នឹងត្រឡប់មកបង្កើតតទៅបានក្នុងសន្តានបុគ្គលមិនបានដាច់សោះ ដរាបនៅដរាបនោះ មានឧបមាដូចផ្លែស្វាយអស់ទៅហើយតែដើមសល់នៅ គង់នឹងត្រឡប់មានផ្កាផ្លែកើតឡើងទៀតមិនខាន អនុ-លោមញាណ ដែលកើតព្រមជាមួយនឹងអនុលោមជវនៈនោះមានសង្ខតធម៌ជាអារម្មណ៍ដូចវិបស្សនាញាណទាំងពួង មិនអាចនឹងលះបង់កិលេសឲ្យដាច់សមុច្ឆេទប្បហានបាន ដែលថាកិលេសនឹងដាច់ស្រឡះមិនត្រឡប់កើតឡើងវិញបាននោះ ដោយអំណាចព្រះអរិយមគ្គ ៗ ជាអ្នកកាត់ផ្ដាច់ឫសផ្ដាច់គល់មានសភាពយ៉ាងនេះ ឯអ្នកនឹងឃើញថាព្រះអរិយមគ្គមិនបានកំចាត់បង់នូវកិលេសទាំងអស់នេះមិនគួរទេ ម្នាលអាចារ្យជាអ្នកចោទ ក៏ពាក្យអ្នកពោលតាំងពីដើមមកថា ពាលបុថុជ្ជនមិនអាចនឹងបានព្រះនិព្វានទេ នឹងពាក្យ

ដែលថាមិនមានព្រះនិព្វាននោះក្តី ពាក្យដែលថាសម្មាបដិបត្តិជាអនវជ្ជធម៌
ដោយអំណាចកាត់កិលេស ហើយឲ្យដល់នូវលោកុត្តរ ទើបបានជាអនវជ្ជធម៌
ដោយអំណាចឲ្យដល់នូវព្រះនិព្វាននោះក្តី ពាក្យដែលអ្នកថាអតីតក្ខន្ធ អ-
នាគតក្ខន្ធជាព្រះនិព្វាននោះក្តី ពាក្យដែលថាគ្មានបច្ចុប្បន្នក្ខន្ធជាព្រះនិព្វាន
នោះក្តី ពាក្យទាំងអស់នេះអគ្គីហេតុអគ្គីបច្ច័យអគ្គីទីអគ្គីស្ថាន ដែលគួរនឹង
ជឿស្តាប់យកជាផ្ទាប់ត្រាប់តាម ជាបែបជាផែនជាប្រមាណបានឡើយ
នឹងពោលទៅថ្វីផលពាក្យដែលថាកិលេសគ្មានក្នុងខណព្រះអរិយមគ្គកើត
ហើយជាព្រះនិព្វាននោះ ពាក្យដែលថាកិលេសគ្មានក្នុងខណដែលព្រះ
អរិយមគ្គកើត ពាក្យនេះជាលទ្ធិខុស អគ្គីហេតុអគ្គីបច្ច័យ ម្នាលអាចារ្យ
ជាអ្នកហោង បើថាអ្នកនឹងមានពាក្យប្រៀតឡើងទៀតថា ដែលអស់រាគ
ទោស មោហៈនោះឯងជាព្រះនិព្វាន ព្រោះមានបាលីក្នុងជម្ពុខាទកសូត្រ
ព្រះធម្មសេនាបតីសារីបុត្តត្ថេរសម្តែងនឹងព្រះសង្ឃទាំងឡាយថា ម្នាលអាវុ-
សោទាំងឡាយ សភាវអស់រាគ អស់ទោស អស់មោហៈនេះឯងឈ្មោះ
ជាព្រះនិព្វាន ម្យ៉ាងទៀត មានព្រះបាលីព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់
ទេសនាក្នុងធម្មាយតនវិភង្គថា· កតមា អសំខតធាតុ អសំខតធាតុ
ពោលគឺព្រះនិព្វាននោះតើដូចម្តេច ទើបព្រះអង្គទ្រង់វិសជ្ជនាព្រះអង្គឯង
ថា រាគក្ខយោ ទោសក្ខយោ មោហក្ខយោ អស់រាគ
អស់ទោស អស់មោហៈនោះឯងឈ្មោះថាអសំខតធាតុពោលគឺព្រះនិព្វាន
អាស្រ័យហេតុបាលីក្នុងជម្ពុខាទកសូត្រ នឹងបាលីក្នុងធម្មាយតនវិភង្គ

សម្ដែងទុកជាប្រធានដូច្នេះ រួចហើយទើបឃើញថាអស់រាគ ទោស មោហ នោះឯងជាព្រះនិព្វាន ម្នាលអាចារ្យជាអ្នកទោង បើអ្នកនឹងមានពាក្យពោលទៀតយ៉ាងនេះក៏មិនគួរ ហេតុការនៃព្រះអរហត្តផលនឹងនាមបញ្ញត្តិឈ្មោះថាអស់ទុក្ខនោះមានដែរ ម្នាលអាចារ្យជាអ្នកទោង ពាក្យដែលអ្នកអាងថ្លែងទៅតេបាលីថា រាគក្ខយោ ទោសក្ខយោ មោហក្ខយោ នោះហើយប្រកាន់យកតែតាមបាលីថាអស់រាគ អស់ទោស អស់មោហជាព្រះនិព្វាននោះមិនគួរទេ ព្រោះថាបាលីក្នុងព្រះសូត្រនេះ លោកសម្ដែងជាឈ្មោះនៃអរហត្តផល មិនបានសម្ដែងជាឈ្មោះនៃព្រះនិព្វានតែមួយក៏ទេ ការព្រោះបាលីក្នុង [illegible] សាវ័កបុគ្គលសម្ដែងនោះក្តី ការព្រោះបាលីដែលព្រះសម្មាសម្ពុទ្ធទេសនាក្នុងធម្មយគនវគ្គនោះក្តី ព្រះបាលីទាំង ៦ អន្លើនេះ បណ្ឌិតគប្បីសន្និដ្ឋានថាជានយត្ថៈ គឺប្រកបដោយន័យដ៏គប្បីនឹងពិស្ដារដោះស្រាយកចេញទៅជាច្រើន ហេតុដូច្នេះព្រះអដ្ឋកថាចារ្យអ្នកដឹងនូវពុទ្ធាធិប្បាយៈទើបពិស្ដារថា ពាក្យដែលថាមានព្រះបាលីថា រាគក្ខយោ ទោសក្ខយោ មោហក្ខយោនោះ គប្បីចូលចិត្តចុះ ថារាគទោសមោហដែលនឹងអស់ទៅនោះអាស្រ័យនឹងព្រះនិព្វាន ព្រះអរិយមគ្គទាំង៤ប្រការនោះបានព្រះនិព្វានជាទីអាស្រ័យ ឈានដោតយកព្រះនិព្វានហើយ ទើបកំចាត់រាគទោសមោហឲ្យអស់ចេញបាត់អំពីសន្តាន ទើបមានពាក្យដីកាចារ្យវិសជ្ជនាទៀតថា កាលបើគោត្រ

ភូញាណក្រឡប់ចិត្តដែលជាបុថុជ្ជនឲ្យដល់នូវគោត្រជាអរិយគោត្រ ហើយ ឲ្យបង្អោនទៅកាន់ព្រះនិព្វាន ទៀយណាយចាកសង្ខារធម៌ទាំងពួង ឈានតោនយកព្រះនិព្វានជាអារម្មណ៍បានហើយ លំដាប់នោះ ព្រះអរិយមគ្គក៏អាស្រ័យយកព្រះនិព្វានដែលគោត្រភូញាណធ្វើឲ្យជាក់ច្បាស់នោះ យកប្រគោនយកជាអារម្មណ៍នៃខ្លួន សំឡឹងយកព្រះនិព្វានដែលប្រាសចាកសង្ខារនោះ ជាវីឈប់សម្រាកព័ទ្ធព័ទ្ធយកជាគតិដ៏ឧត្តម ក្រែកអរក្នុងព្រះនិព្វាន ដ៏ប្រសើតជាអធិបតិបច្ច័យ ហើយក្នុងកាលឯណា ព្រះអរិយមគ្គនោះ ក៏ញុំាងរាគៈទោសៈមោហៈឲ្យអស់ទៅអំពីសន្ដានជាសមុច្ឆេទ ឲ្យលែងជាអនុប្បត្តិធម៌កើតបានក្នុងកាលនោះ ស្រេចតែជាអស់រាគៈទោសៈមោហៈនោះ ក៏អាស្រ័យនឹងព្រះនិព្វានទើបអស់ជាសមុច្ឆេទ ហេតុដូច្នោះព្រះបាឡី រាគ-ក្ខយោ ទោសក្ខយោ មោហក្ខយោនោះ ទើបលោកសម្ដែងថាជាឈ្មោះនៃព្រះនិព្វាន បណ្ឌិតមានប្រាជ្ញាគប្បីពិចារណា ឲ្យឃើញអធិប្បាយក្នុងធម្មទានសូត្រ ទឹងធម្មាយតនវគ្គដូចអធិប្បាយដែលព្រះអដ្ឋកថាដ៏-កាចារ្យសែដ្ឋទុកដូច្នេះ ទឹងឃើញសេចក្ដីថា អស់រាគ ទោស មោហ ជាព្រះនិព្វាននោះយល់ទាល់ណាស់ គប្បីចូលចិត្តថា ធម្មទានសូត្រក្ដី ធម្មាយតនវគ្គក្ដី ដូចជាសូត្រតែមួយ កាលបើពិចារណាមើលសេចក្ដីតាមអាព្រះបាឡីក្នុងធម្មទានសូត្រនោះ ឃើញដូចជាថាលក្ខណៈដែលអស់រាគៈទោសៈមោហៈនោះឯងជាអរហត្តផល តែជាកុំប្រកាន់អធិប្បាយដូច្នោះឡើយ គប្បីឃើញអធិប្បាយដូច្នេះវិញថា ព្រះអរហត្តមគ្គញាណនោះធ្វើព្រះនិព្វានជាអារម្មណ៍ ក៏ចាត់បង់នូវអនុសយដែលជាឫសជាគល់នៃ

កិលេសឲ្យអស់សូន្យសោះជាសមុច្ឆេទ មិនឲ្យសេសសល់នៅបានក្នុងកាល
ឯណាហើយ ព្រះអរហត្តផលដែលធ្វើព្រះនិព្វានជាអារម្មណ៍នោះ ទើប
កើតឡើងក្នុងកាលនោះ ស្រេចតែថាព្រះអរហត្តផលនោះកើតក្នុងទីបំផុត
នៃកាលដែលអស់កិលេស ហេតុដូច្នេះឯងបានជាព្រះធម្មសេនាបតីសារីបុត្ត
លើកយកបាឡីថា ខតក្ខយោ ជាដើមនោះមកសម្តែងថាឈ្មោះនៃអរហត្ត-
ផល បណ្ឌិតគប្បីពិចារណាឲ្យយល់អធិប្បាយនេះចុះ ទើបនឹងគួរ ដែល
នឹងប្រកាន់យកតាមព្រះបាឡីដែលថាអស់រាគទោសមោហជាព្រះអរហត្ត-
ផលជាព្រះនិព្វាននោះមិនគួរទេ ព្រះអរហត្តផលនោះសំដៅយកខន្ធទាំង៥
គឺវេទនាក្ខន្ធ សញ្ញាក្ខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធដែលជាដើមជាប្រធាននោះ
ទេតើ ការដែលអស់រាគ ទោស មោហនោះនឹងបានជាព្រះអរហត្តផល
គឺទេ ហេតុដូច្នេះបណ្ឌិតអ្នកដែលនឹងអធិប្បាយសេចក្តីក្នុងធម្មវាទកសូត្រ
នឹងធម្មាយតនវិភង្គនោះ គប្បីអធិប្បាយតាមន័យនៃព្រះអដ្ឋកថាពាក្យដែល
លោកសម្តែងមកនេះចុះ នឹងអធិប្បាយយកតាមព្រះបាឡីថា អស់រាគ
ទោស មោហជាព្រះនិព្វាននោះខុសនឹងពុទ្ធាធិប្បាយ អ្នកប្រាជ្ញទាំងឡាយ
គួរពិចារណាមើលឲ្យឃើញតែជាក់ ៗ ដោយអត្ថនោមតិទៅចុះថា រាគាទិកិ-
លេសប្រៀបដូចគំនរភ្លើង ព្រះនិព្វាននោះប្រៀបដូចទឹកសម្រាប់លត់ភ្លើង
ព្រះអរិយមគ្គនោះដូចជាបុរសជាអ្នកនាំយកទឹកមកលត់ភ្លើង កាលបើគំនរ
ភ្លើងនោះរលត់ដោយព្យាយាមនៃបុរសដែលយកទឹកមកស្រោចរលត់ភ្លើង
នោះយ៉ាងនេះហើយ កាលបើកិលេសរលត់ទៅដោយអំណាចព្រះអរិយមគ្គ

ដ៏ធ្វើឲ្យព្រះនិព្វានជាអារម្មណ៍ផ្លូវនោះហើយ ទើបប្រកាន់លទ្ធិថាធម៌ជាអា-
រម្មណ៍នៃព្រះអរិយមគ្គ ដែលជាឧបនិស្ស័យឲ្យលះកិលេសជាសមុច្ឆេទ
នោះ ទើបបានឈ្មោះថាព្រះនិព្វានក៏ទេ សភាវដែលអស់រាគ ទោស មោហ
នេះវិញបានឈ្មោះថានិព្វាន ទើបប្រកាន់លទ្ធិយ៉ាងនេះហៅថាប្រកាន់ខុស
មិនគួរទេ ប្រការមួយទៀតគួរនឹងថា ខយោ និព្វានំ នេះពិតណា
ឃើញដោយអត្តនោមតិអធិប្បាយថា ចំណែកខាងអាចារ្យអ្នកខ្លះនោះ
ប្រកាន់លទ្ធិថា អាការដែលអស់នៃរាគាទិកិលេស មិនមែនអស់ជាឯកទេស
អស់តែមួយខណៈៗ អស់មិនបានជាសមុច្ឆេទ គឺអាចនឹងហៅថាព្រះនិព្វាន
បានដោយអត្តនោមតិ ឃើញថាអ្នកខ្លះប្រកាន់លទ្ធិយ៉ាងនេះ ហេតុដូ-
ច្នោះបានជាមានបទព្រះបាឡីថា តំ កិញ្ចិ យេហិ និព្វានំ សច្ចំ ឥតរេ កោ
ក ធិ ខោ ស ខោ ម្នាលអាចារ្យជាអ្នកខ្លះ បើអ្នកប្រកាន់យកអធិប្បាយ
ដូចពាក្យអ្នកថាមកនេះ ព្រះនិព្វានក៏នឹងដល់នូវអាការជាកាមាវចរហើយ
ជាសង្ខតលក្ខណៈផង ព្រោះថាអាការដែលអស់កិលេសគ្រាន់តែជាខណៈៗ
យ៉ាងដូច្នោះសម្រេចដោយកាមាវចរចិត្ត សម្រេចដោយហេតុបច្ច័យប្រជុំ
តាក់តែង ន័យមួយវិញទៀតមានពាក្យដីកាចារ្យវិសជ្ជនាថា បើនឹងប្រកាន់
អធិប្បាយថាអស់រាគទោសមោហតែខណៈៗ នោះជានិព្វានហើយ បុគ្គល
ដែលមិនលះលោភមិនទាន់នឹងមិនធ្វើនូវមានសន្តានរម្ងាប់ស្ងប់ស្ងាត់មួយស្របគ្នាមួយ
សំគាល់នោះ គឺនឹងបានឈ្មោះថាសម្រេចព្រះនិព្វានដោយកិច្ចធម្មតាខ្លួនឯង
មិនបាច់ខ្វល់ខ្វាយចំព្យាយាមប្រព្រឹត្តនូវសម្មាប្រតិបត្តិទៅទេ ព្រោះហេតុ

ដែលថាបានសម្រេចព្រះនិព្វានដោយធម្មតាចិត្តខ្លួនឯង ហើយលះយ៉ាងនេះ ហើយ បុគ្គលទាំងពួងគឺនឹងបានព្រះនិព្វានទាំងអស់គ្នា ពាក្យដែលថាព្រះនិព្វានជាទីរលត់ទុក្ខនោះគឺនឹងខុស ពាក្យដែលថាព្រះនិព្វានស្ថិតជាអារម្មណ៍នៃគោត្រភូញាណ និងមគ្គញាណនោះគឺនឹងខុស ព្រោះហេតុដូច្នោះបើឃើញថាអាការដែលអស់រាគាទិកិលេសក្ខន្ធ ១ណៈ ៗ នេះនឹងបានឈ្មោះថាព្រះនិព្វានគឺទេ មួយទៀតមានក្នុងព្រះបាឡីដីកាចារ្យបញ្ជាក់ថា អាការដែលអស់រាគៈទោសមោហៈនោះផ្សេង ៗ គ្នាដែរ នឹងបានដូចគ្នាគឺទេ កាលណាបើអស់រាគនោះ នឹងហៅថាអស់ទោសមោហក៏ហៅមិនបាន កាលបើអស់ទោសនោះវិញនឹងហៅថា អស់រាគមោហក៏ថាមិនបាន កាលបើអស់មោហៈនោះហៅថា អស់រាគទោសក៏ថាមិនបាន អាការដែលអស់រាគ ទោសមោហៈនោះផ្សេងគ្នាយ៉ាងនេះ បើប្រកាន់អធិប្បាយថា អស់រាគទោសមោហៈថាព្រះនិព្វាន ប្រកាន់យកអធិប្បាយយ៉ាងនោះហើយ ព្រះនិព្វានគឺនឹងបែកញែកចេញទៅម្យ៉ាង ៗ ដោយខ្លួនពីគ្នា អាការដែលអស់រាគគឺនឹងទៅជានិព្វាន ១ អាការដែលអស់ទោសគឺនឹងទៅជានិព្វាន ១ អាការដែលអស់មោហគឺនឹងទៅជានិព្វាន ១ បែកញែកចេញទៅទីទៃ ៗ ពីគ្នាដូច្នេះ ព្រោះអាការដែលអស់រាគ អស់ទោស អស់មោហៈនោះផ្សេង ៗ គ្នា មិនបានដូចគ្នា កាលបើជាព្រះនិព្វានបែកគ្នាមួយ ៗ ដោយអស់កិលេសនោះ ៗ ដូច្នេះហើយ ព្រះនិព្វានគឺនឹងបែកញែកទៅដោយប្រភេទច្រើនជាងរយជាងពាន់ គឺចំណែកអស់ឧបាទាន ៤ ព្រះនិព្វានគឺនឹងទៅជា ៤ អស់នីវរណ ៥

ព្រះនិព្វានក៏នឹងទៅជា ៥ អស់តណ្ហាភាពគម្ពី ៦ ព្រះនិព្វានក៏នឹងទៅជា ៦ អស់អនុស័យ ៧. ព្រះនិព្វានក៏នឹងទៅជា ៧ អស់មិច្ឆត្តនិយមទាំង ៨ អស់តណ្ហាមូលទាំង ៩ អស់សំយោជនទាំង ១០ ព្រះនិព្វានក៏នឹងទៅជា ៨ យ៉ាង ជា ៩ យ៉ាង ជា ១០ យ៉ាង តាមលំដាប់កិលេសដែលអស់ទៅដោយកំណត់ ច្រើនឡើងតិច ខណៈដែលកាត់កិលេសទាំង ១៥០០ ព្រះនិព្វានក៏នឹងបែកចេញទៅជា ១៥០០ នឹងទៅជាផ្សេង ៗ ដោយប្រភេទជាច្រើនយ៉ាង នេះព្រោះឃើញសេចក្ដីយកតែតាមបាឡីថា អស់រាគ អស់ទោស អស់មោហៈនោះជាព្រះនិព្វាន ហេតុដូច្នេះអ្នកមានប្រាជ្ញាគប្បីយល់អធិប្បាយក្នុងបទថា រាគ ទោស មោហៈនឹងអស់ទៅណាសម្រេចនោះ កេ-ស្រ័យនឹងព្រះនិព្វាន ១ នោះនឹងបែកញែកចេញទៅដោយប្រភេទផ្សេង ៗ ជាយ៉ាង ៗ ច្រើនជាអនេកជាពាន់ដូច្នោះនោះក៏ឥតអត្ថិមានឡើយ ព្រះនិព្វានក៏មានតែ ១ ប៉ុណ្ណោះ តែថាជាហេតុរំលត់កិលេសទាំងពួងមានរាគទោសមោហៈជាដើម អាស្រ័យនឹងព្រះនិព្វានហើយទើបបានអស់ទៅ បានជាលោកសម្ដែងថា រាគក្ខយ ទោសក្ខយ មោហក្ខយ នោះជាឈ្មោះនៃព្រះនិព្វាន គប្បីឃើញអធិប្បាយយ៉ាងនេះ កុំគប្បីឃើញអធិប្បាយថាអាការដែលអស់រាគ ទោស មោហៈជាព្រះនិព្វានឡើយមិនគួរទេ កិរិយាដែលអស់កិលេសទៅជាតទង្គប្បហានក៏នឹងទៅជាព្រះនិព្វានតែទាំងអស់គ្នា កាលបើបានយកកិរិយាដែលអស់កិលេសទៅជាតទង្គប្បហាននោះជាព្រះនិព្វានហើយ ព្រះនិព្វានក៏នឹងបាននៅលើសត្វគ្រប់សន្តានសត្វទាំងពួងមិនរើសមុខ សម្បីតែថា

មនុស្សអន្ធពាលកាប់ឥតប្រាជ្ញ គឺភាពនឹងបានព្រះនិព្វាន ក្នុងកាលខ្លះ ម្ដង ៗ ដែរ ហេតុសន្តាននៃមនុស្សអន្ធពាលនោះមិនតឹជាទឹងមានចិត្តក្រោក លោមកល្អក់សៅហ្មងទៅដោយកតោភសៈមោហាតែកាលកល់វេលាជា និច្ចទៅគឺទេ ជួនកាលគឺអស់រាគ ជួនកាលគឺអស់ទោស ជួនកាលគឺអស់ មោហ ជាឯកទេសម្ដង ៗ ដោយហេតុសព្វសត្វតិរច្ឆានមានដើមជាង ម្រឹគពានរក៏មានកាលកំណត់អស់រាគ ទោស មោហមួយស្របក់ មួយ សម័យខ្លះម្ដង ៗ ដែរ បុគ្គលគប្បីសង្កេតមើលបានដោយន័យនេះ បើអស់រាគ ទោស មោហ មួយខណៈៗ នោះ នឹងជាព្រះនិព្វានបានម្ដង ៗ ហើយ ព្រះនិព្វានគឺនឹងនៅផល់សត្វតិរច្ឆានដ៏ជាអហេតុកបដិសន្ធិ ព្រោះជាអា-ការដែលអស់កិលេសយ៉ាងដូច្នោះ នឹងបានជាអារម្មណ៍នៃព្រះអរិយមគ្គ ព្រះអរិយផលក៏ទេ ធម៌ឯណាមាននាមបញ្ញត្តិឈ្មោះថាព្រះនិព្វាននោះ សំដៅយកធម៌ដែលជាអារម្មណ៍នៃព្រះអរិយមគ្គអរិយផលៈផ្សេង អាការៈ ដែលអស់កិលេសយ៉ាងដូច្នោះ មិនបានជាអារម្មណ៍នៃព្រះអរិយមគ្គ អរិយផលបានទេ អាស្រ័យហេតុយ៉ាងនេះនឹងហៅឈ្មោះថាព្រះនិព្វាននោះមិន សមគួរទេ ម្នាលភារទ្វាជអ្នកទេទ្យ ពិតណាស់ កុលបុត្តដែលមានបញ្ញា-កិសម្ភារដ៏ចំរើនក្លៀវក្លា ពិចារណាឃើញទោសនៃកាមគុណហើយ លះបង់ យកភេទសេចញបួសជាបព្វជិតចំរើនឈានសមាបត្តិជាលោកិយសង្កត់សង្កិ-នទូវកតកិលេសដោយអំណាចឈាន មិនបានសាបសូន្យអំពីឈាន លុះ ទម្លាយបញ្ចក្ខន្ធកបានឡើងទៅឧបត្តិកើតក្នុងព្រហ្មលោក ស្ថិតនៅក្នុង

ព្រហ្មលោកនោះ ទាល់តែផុតអស់កាលកំណត់នៃអាយុហើយ ចុតិត្រ-
ឡប់ចុះមកកើតក្នុងមនុស្សលោកវិញ ក៏ជាសត្វបរិសុទ្ធមិនបានត្រេកអរក្នុង
កិលេសកាមនិងវត្ថុកាម លះបង់យកកាសចេញបព្វជ្ជាក្នុងព្រះពុទ្ធសាសនា
បានលុះព្រះអរហត្ត ត្រាស់ដឹងនូវព្រះនិព្វានក្នុងបច្ឆិមជាតិ ដូចជាបិង្គលិ-
មាណពគឺព្រះមហាកស្សបនិងនាងភទ្ទាកាបិលានីមហាថេរីដូច្នោះ ផ្តាក់តែ
អស់កិលេសមានរាគជាដើម ដោយអំណាចឈានជាវិក្ខម្ភនប្បហានមកអំពី
មុន នៅមិនទាន់បានសម្រេចព្រះនិព្វានទៅដល់ពីរបីជាតិទៀត យ៉ាងនេះ
កិលេសដែលអស់ទៅដោយអំណាចឈាននោះអស់មិនបានដាច់ ប្រសិន
បើទៅជួបប្រះពាល់ពាន់ទៅលើអារម្មណ៍ឯណាមួយ ដែលគួរនឹងត្រេកអរ
ប្រព្រឹត្តទៅក្នុងកាមគុណ កិលេសនោះក៏នាំមកកើតវិញទៀតគង់បាន
ហេតុអ្វី ហេតុថាប្រាជ្ញាដឹងសម្បយុត្តដោយឈានមានបឋមជ្ឈានជាដើម
នោះមានសម្មតិសត្វជាអារម្មណ៍ មិនអាចនឹងលះកិលេសឲ្យជាសមុច្ឆេទប្ប-
ហានបាន ហេតុដូច្នោះទើបឃើញថាសភាពអស់កិលេសដោយឈាននោះ
បើនឹងពាក់ថាជាព្រះនិព្វានហើយ ព្រះនិព្វានក៏នឹងពាក់ថាជាកាមាវចរ
ហើយជាសំខតលក្ខណ៍ ប្រកបទៅដោយទោសផ្សេងៗផង បណ្ឌិតគប្បី
សន្និដ្ឋានចុះថា សូម្បីតែបានព្រះអរិយមគ្គហើយនឹងត្រឡប់យកឡើងថាជា
ព្រះនិព្វានក៏នៅថាខុស ចំណង់បើថាគ្រាន់តែអស់រាគទោសមោហប៉ុណ្ណោះ
មកថាជាព្រះនិព្វានដូចម្តេចបាន ពាក្យដែលថាអស់រាគទោសមោហជា
ព្រះនិព្វាននោះជាលទ្ធិខុស ប្រៀបដូចបុគ្គលជារោគដោយថ្នាំ ត្រឡប់ជា
ឃើញថាគ្រាន់ជារោគនោះជាថ្នាំទៅវិញ ហេតុដូច្នេះបណ្ឌិតគប្បីពិចារណា

ឲ្យឃើញច្បាស់ថា រាគាទិកិលេសដែលអស់ទៅជាសមុច្ឆេទ ជាអនុប្បត្តិ-
កធម្មៈនោះ ទំនងជាអស់ដោយអរិយមគ្គតែម្យ៉ាងក៏ថាមិនបាន ទំនងថា
អស់ទៅដោយព្រះនិព្វានតែម្យ៉ាងក៏ថាមិនបាន ស្រេចតែថាព្រះនិព្វានជា
ទីអារម្មណ៍នៃព្រះអរិយមគ្គ ពេជ្រដ៏វិសេសពោលគឺព្រះអរិយមគ្គនោះ
កាលបើបានខ្ទុសថ្នាំដ៏វិសេសពោលគឺព្រះនិព្វាន ឈោងតោងយ៉ាងយក
ព្រះនិព្វានជាអារម្មណ៍បានហើយ ក៏ញ៉ាំងរោគាព្យាធិអាពាធទាំងពួងគឺលោ-
ភៈទោសមោហកិលេសធម៌ទាំងពួង ឲ្យវិនាសសាបសូន្យទៅជាអនុប្បត្តិ-
កធម្មៈ ។ តើក៏កាលព្រះអរិយមគ្គនិងព្រះនិព្វានធ្វើឲ្យកិលេសសូន្យទៅ
ជាអនុប្បត្តិកធម្មយ៉ាងនេះហើយ ចុះហើយក៏មិនបានឃើញថាធម៌ដែល
ជាអារម្មណបច្ច័យនៃព្រះអរិយមគ្គនោះជាព្រះនិព្វាន ឯអាការដែលអស់
រាគទោសមោហដែលមិនបានជាអារម្មណ៍នៃព្រះអរិយមគ្គ ដែលមិនមែន
ជាព្រះនិព្វាននោះ ត្រឡប់ឃើញថាជាព្រះនិព្វានវិញ ឃើញយ៉ាងនេះ
ពេញជាខុសមិនគួរទេ ឯព្រះបាលីថា រាគក្ខយោ ទោសក្ខយោ មោហក្ខយោ
នោះ លោកក៏សំដែងថាជាឈ្មោះនៃព្រះអរហត្ត ក្នុងសូត្រខ្លះសំដែងថា
ឈ្មោះនៃព្រះនិព្វាន ក្នុងសូត្រខ្លះសំដែងថាជាឈ្មោះនៃព្រះអរិយមគ្គ
សំដែងខុស ៗ គ្នាដូច្នេះ បើជាមានពាក្យពោលមកទៀតថា ហេតុអ្វីបាន
ជាអង្គព្រះសព្វញ្ញូសម្មាសម្ពុទ្ធ កាលត្រាស់ទេសនាសំដែងព្រះនិព្វាននោះ
ក៏មិនបានសំដែងដោយសរុប ឯចិត្តនិងចេតសិកនិងរូបនោះព្រះអង្គសំដែង
ដោយសរុបរួបរួមគ្នាបន្ទុកជាចំណែកជាចង្កោម ៗ តែត្រង់ព្រះនិព្វានមួយ

នេះ ឬក៏ព្រះអង្គមិនសម្តែងដោយសរុបប្រមូលភ្ជាប់នឹងកជាចំណុចផ្តើមផុត ជាចិត្តចេតសិករូបធម៌ទាំងផង តែស្រាយហេតុផលប្រែការផ្តួចផ្តើម ?

ពាក្យវិសជ្ជនាដោះថា អតិ សុខុម តាដំណើរដែលព្រះអង្គមិនបានសម្តែងព្រះនិព្វានដោយសរុបនោះ ព្រោះព្រះនិព្វានល្អិតសុខុមក្រៃលែងល្អិតសុខុមណាស់ ទីងទៀតអ្នកប្រៀបធៀបផឹមស្មើពុំបាន ព្រះនិព្វាននេះជាធម៌វិសេសក្រៃលធម៌ទាំងពួងជាអារម្មណ៍នៃព្រះអរិយមគ្គអរិយផលដ៏ល្អិតក្រៃលែងល្អិតផុតវិស័យបុថុជ្ជនទើងគ្មានដឹងគ្មានឃើញ ចំពោះដឹងឃើញបានតែប្រាជ្ញព្រះអរិយបុគ្គល បើទុកជាទ្រង់សម្តែងដោយសរុបបំព្រួញទៅ ក៏ផុតវិស័យបុថុជ្ជនទើងចេះដឹងដោយប្រាជ្ញា លុះតែ[illegible]បន្តផលហើយ ក៏គាប់ទឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានបានដោយបញ្ញា-ចក្ខុ ហេតុដូច្នេះបានជាព្រះអង្គមិនទ្រង់វាយទឹងសម្តែងព្រះនិព្វានដោយសរុបដូចអាបគធម៌ទាំងពួង ក្នុងរឿងនេះមានពាក្យអដ្ឋកថាប្រាប់សេដ្ឋាថា មានពាក្យព្រះអដ្ឋកថាចារ្យសម្តែងថា ព្រះនិព្វាននោះល្អិតក្រៃលែងល្អិតណាស់ផុតវិស័យបុគ្គលជាបុថុជ្ជនទើងងាកងដឹងយល់ឃើញបាន ចំពោះតែប្រាជ្ញព្រះអរិយបុគ្គលនោះ ទើបទឹងដឹងយល់ឃើញបាន ពាក្យនេះត្រូវណាស់សមនឹងព្រះពុទ្ធភាសិតដែលព្រះមហាករុណាទ្រង់សម្តែងនឹងមាគន្ទិយ-ព្រាហ្មណ៍ថា .មាគន្ទិយ អរិយចក្ខុំ នត្ថិ យេន ត្វំ អារោគ្យំ ជានេយ្យាសិ និព្វានំ បស្សេយ្យាសិ ថាម្នាលមាគន្ទិយព្រាហ្មណ៍ ខ្លួនអ្នកនេះគ្មានអរិយចក្ខុមិនទាន់បាន ១ ជាអ្នកនៅ

មិនទាន់ឃើញនូវព្រះនិព្វាន មិនទាន់ស្គាល់នូវធម៌ដ៏កើតក្នុងពេលគឺ ព្រះនិព្វានបើអ្នកបានសម្រេចនូវអរិយមគ្គពេលគឺបាននូវបញ្ញាញាណរបស់នៃ ព្រះអរិយបុគ្គលដាក់ចម្រាស់ក្នុងសន្តានហើយ អ្នកក៏នឹងបានឃើញនូវព្រះនិព្វាន នឹងស្គាល់នូវធម៌ដ៏កើតក្នុងពេលគឺព្រះនិព្វានក្នុងកាលនោះ ព្រះពុទ្ធភាសិតព្រះអង្គទ្រង់ត្រាស់ទេសនានឹងមាគណ្ឌិយព្រាហ្មណ៍ដូច្នេះ គួរនឹងពោលថា ព្រះនិព្វានល្អិតក្រៃលែងល្អិត ចំពោះការឃើញបានតែប្រាជ្ញ នៃព្រះអរិយបុគ្គល ។

មួយទៀតសោត មានពាក្យដីកាចារ្យវិសជ្ជនាថា ព្រះអដ្ឋកថាចារ្យ អ្នកដឹងពុទ្ធាធិប្បាយៈលោកឃើញថា អ្នកដែលមានសំនួរនេះនឹងលើក សួរចូលមកថា ព្រះនិព្វាននោះជាសភាវធម៌មិនកប់ចូលក្នុងសន្តានសត្វទេ គឺថាមិនបានជាប់ក្នុងកន្លែងរូបធម៌ នាមធម៌ឯណាមួយសោះ អាការនៃ ព្រះនិព្វាននោះឃើញជាក់ថានឹងជាសព្វសាធារណ៍ គួរនាដូចៈកើន ជាទីប្រជុំទីចំណតអាស្រ័យដ៏មាននៅដូចបំបែក ៤ ហេតុនោះជាសព្វសាធារណ៍តាមតែចិត្តមហាជន អ្នកណាចង់អង្គុយក៏អង្គុយ អ្នកណាចង់ដេកក៏ដេក អ្នកណាចង់ឈរក៏ឈរ តាមអធ្យាស្រ័យ ហេតុជាទីប្រជុំនោះជាសាធារណ៍ទួទៅដល់មហាជនទាំងពួងដូចម្ដេចមិញ ព្រះនិព្វានក៏ឃើញជាក់ថានឹងទួទៅដល់ជនទាំងពួងដូច្នោះដែរ ព្រះអដ្ឋកថាចារ្យលោកពិចារណាឃើញថា នឹងមានពាក្យប្រៀបសួរសេកយ៉ាងនេះ បានជាលោកពោលបាឡីវិសជ្ជនាដោះថា មគ្គសមង្គិជាធាបត្តព្វតោ សាធា-

រណាំ ក ពាក្យដែលថាព្រះនិព្វានមិនបានទូទៅដល់ជនទាំងពួងនោះព្រោះ ថាព្រះនិព្វាននោះបុគ្គលអ្នកព្រមព្រៀងដោយព្រះអរិយមគ្គគប្បីដល់ បុគ្គលដែលជាបុថុជ្ជនមិនទាន់ព្រមព្រៀងដោយព្រះអរិយមគ្គអរិយផល នោះ ទឹងបានដល់ព្រះនិព្វានក៏ទេ ស្រេចតែថាឃើញចំពោះជាក់ច្បាស់ ព្រះនិព្វាននោះបានតែព្រះអរិយបុគ្គលមានកំណត់ដូច្នេះ បានជាព្រះនិព្វា-នជាអសាធារណធម៌ មិនបានទូទៅដល់ជនទាំងពួង ន័យមួយវិញទៀតថា ព្រះនិព្វាននោះរកដើមកំណើតគ្មាន ព្រោះថាទីបំផុតខាងដើមមិនមាន ទឹង មានកំណត់ថាព្រះនិព្វានមានមកតាំងអំពីព្រះសាសនាព្រះសម្ពុទ្ធណា ទឹង កំណត់ដូច្នេះមិនមាន ឯពាក្យបុច្ឆាសៀតសិកបួលមកទៀតថា ព្រះនិព្វាន នោះមានដើមកំណើតដែរ ចុះព្រះអរិយមគ្គនោះមិនមែនជាដើមកំណើត ព្រះនិព្វានទេឬ វិសជ្ជនាដោះថា ព្រះអរិយមគ្គនោះទឹងបានជាដើមកំណើត នៃព្រះនិព្វានក៏ទេ ព្រោះថាព្រះនិព្វានជាអារម្មណ៍នៃព្រះអរិយមគ្គទេតើ ដែលថាអរិយមគ្គជាដើមកំណើតនៃព្រះអរិយនោះមិនគួរទេ ព្រះនិព្វានទឹង បានកើតដោយអំណាចព្រះអរិយមគ្គក៏ទេ ឯព្រះអរិយមគ្គនោះទឹងបានជា បច្ច័យឲ្យកើតព្រះនិព្វានក៏ទេ ហេតុដូច្នេះបានជាព្រះនិព្វានបានឈ្មោះថា ធម៌រកដើមកំណើតរកទីកើតមិនបាន ព្រះនិព្វាននោះរកដើមកំណើតគ្មាន ហើយ បានជារកជរានិងមរណចាស់ស្លាប់មិនមានក្នុងព្រះនិព្វាននោះ ព្រះ និព្វាននោះរកទីកើតគ្មាន រកសេចក្តីចាស់ជរាគ្មាន រកសេចក្តីមរណគ្មាន ប្រាកដដូច្នោះ ស្ថិតនៅក្នុងនិច្ចធម៌ជាធម៌ទៀងពិត មិនចេះប្រែប្រួល ឡើយ ។

ទើបមានពាក្យបុច្ឆាថា ដំណើរដែលថាព្រះនិព្វានទៀងនោះទៀងដូចជាអ្វី ទឹងថាទៀងដូចជាធូលីដីល្អិតជា បរមាណូ នៅក្នុងអាកាសនោះឬ ទឹងថាទៀងដូចប្រក្រតីនៃលោក ឬថាទៀងដូចកាលជាអតីតអនាគតបច្ចុប្បន្ន ឬថាទៀងដូចគេចស្រែគេចប្រុសជាដើម ឬយ៉ាងដូចម្ដេច គឺធូលីដីល្អិតដែលហុយនៅក្នុងអាកាសឃើញច្បាស់ក្នុងរស្មីនៃព្រះអាទិត្យដែលធ្លុះចូលតាមប្រហោងផ្ទាំងជាដើម ដែលមាននាមបញ្ញត្តិឈ្មោះថាអណូ នោះឃើងឃើញថាទៀង ព្រោះហុយទៅជានិច្ច ឯប្រក្រតីនៃលោកគឺផែនប្រថពី ទឹងមហាសមុទ្រ ភ្នំព្រះសុមេរុកដសត្តបរិភណ្ឌគីរី ទឹងភ្នំកណ្ដាប់ចក្រវាឡជាដើម នោះឃើងឃើញថាទៀង ព្រោះថាមានកំណត់ធំតូចប៉ុន្មានក៏នៅជាប្រក្រតីប៉ុណ្ណោះតាមប្រវេណីលោកសណ្ឋាន ទឹងបានប្រែប្រួលត្រឡប់ក្លាយទៅជាអ្វីក៏ឥតអន្លឺមានឡើយ ឯកាលជាអតីតអនាគតបច្ចុប្បន្នដែលកំណត់ជាថ្ងៃ ជាយប់ ជាខែ ជាឆ្នាំ តាមប្រវេណីលោកវិស័យនោះសោត ឃើងក៏ឃើញថាទៀង ព្រោះថាមានជាសម្រាប់លោកតាំងតែអំពីដើមមក ទឹងបានវិបរិតប្រែប្រួលទៅក៏ឥតអន្លឺមាន ស្ថិតស្ថេរនៅជាធម្មតា ប្រការមួយវិញទៀតគេចស្រែគេចប្រុសជាដើមនោះសោត ឃើងក៏ឃើញថាទៀង ព្រោះស្រែទាំងប្រុសនេះមានមកតាំងអំពីដើម ទឹងបានអស់បាត់ហើយផុតទៅនោះក៏ទេ មាននៅទៀងជានិច្ចតាមប្រវេណីលោកវិស័យ គឺឯអណូបរមាណូជាដើម ដែលឃើញថាទៀងដោយន័យដូចពោលមកហើយដូច្នេះ បើទឹងយកមកប្រៀបនឹងព្រះនិព្វាន ទឹងឃើញថាទៀងដូចព្រះនិព្វានដែរឬដូចម្ដេច ។

វិសជ្ជនាដោះថា ដំណើរដែលអ្នកថាអណូបរមាណូជាដើមទៀង
ដូចព្រះនិព្វាននោះ មិនគួរទេ ហេតុអ្វី ហេតុសភាវនៃព្រះនិព្វាននោះ
មានឧប្បត្តិសាធារណហេតុ អធិប្បាយថា កុសលអកុសលធម៌ឯណា
នីមួយ ដែលនឹងជាហេតុជាបច្ច័យឲ្យសំរេចឧប្បត្តិកិច្ចឲ្យកើតព្រះនិព្វាន
នោះគ្មានសោះឡើយ កុំគប្បីចូលចិត្តថាកុសលអកុសលធម៌នេះឯង ហើយ
តាក់តែងព្រះនិព្វានធ្វើឲ្យព្រះនិព្វានកើត កុសលនេះគ្រាន់តែជាអ្នកដឹក
នាំ គ្រាន់តែជាអ្នកឧបត្ថម្ភគាំពារជួយឲ្យដល់នូវព្រះនិព្វានទេតើ នឹងបាន
ជាបច្ច័យតាក់តែងឲ្យកើតព្រះនិព្វានក៏ទេ ឯព្រះនិព្វាននេះជាធម៌មិនចេះ
កើត រកធម៌ឯណានីមួយនឹងជាឧប្បត្តិហេតុឲ្យកើតព្រះនិព្វានឥតអត្ថិមាន
ឡើយ គឺចំណែកឯអណូបរមាណូទំងអាកាសលោកទំងកាលថ្ងៃយប់ខែឆ្នាំ
ទំងភេទស្រីភេទប្រុសនោះរមែងតែងមានឧប្បត្តិសាធារណហេតុនៅឡើយ
ធម្មជាតិដែលជាបច្ច័យឲ្យសំរេចឧប្បត្តិកិច្ចបង្កើតអណូបរមាណូជាដើម
នោះមាននៅដូច្នេះ ដែលនឹងយកអណូបរមាណូជាដើម ដែលមានឧប្បត្តិ-
សាធារណហេតុនោះ មកប្រៀបផ្ទឹមនឹងព្រះនិព្វានដែរគេហេតុគ្មាន ថា
ទៀងដូចព្រះនិព្វានយ៉ាងនេះមិនសមគួរទេ ម្នាលអាចារ្យជាអ្នកពោធ្យ
បើជាអ្នកនឹងមានពាក្យប្រៀតសើកសួរមកទៀតថា អណូបរមាណូជា-
ដើមនោះ យើងឃើញថានៅមានជានិច្ចសម្រាប់លោក មិនចេះ
ដាច់ ។ ចំណែកខាងព្រះនិព្វាននោះ ក៏ឈ្មោះថាមាននៅជានិច្ចមិនដាច់ដូច
គ្នា ដែលនឹងមាននៅតែចំពោះទេសកាលដូចពីជគាមភូតគាម បញ្ចុញ

ផ្កាថ្កៃតែតាមផ្លូវនោះហើយ  បើបុគ្គលឯណាប្រកបដោយព្យាយាមប្រព្រឹត្ត សម្មាប្រតិបត្តិតាមពុទ្ធឱវាទ គឺសីលក្ខន្ធ សមាធិក្ខន្ធ បញ្ញាក្ខន្ធ ដំរុះក្រៀ-ក្លាក្នុងកាលឯណា បុគ្គលនោះក៏នឹងបានជួបបានប្រទះឃើញយល់ដល់ព្រះនិព្វានដោយបច្ចក្ខសិទ្ធិញាណជាក់ច្បាស់ក្នុងអត្តភាពក្នុងកាលនោះ ដែលនឹងបានព្រះនិព្វានមានកំណត់ទេសកាលជួបប្រទះជាក់ពិតតាមក្នុងគាថានោះហើយ  ឯព្រះនិព្វានដែលមាននៅជានិច្ចយ៉ាងនេះអ្នកយល់ថាទៀងហើយ អណូបរមាណូជាដើម ដែលមាននៅជានិច្ចមិនដាច់នោះ យើងក៏ឃើញថាទៀងដូចព្រះនិព្វាននោះដែរ  បើអ្នកនឹងមានពាក្យសួរមកយ៉ាងនេះក៏មិនគួរដែរ ហេតុអ្វី ហេតុថាមិនមានហេតុលក្ខណ  គឺកកំណត់កត់សំគាល់នៃហេតុគ្មាន  ក៏ធម្មតាថានឹងសម្តែងឲ្យផុសនោះគប្បីឲ្យមានលក្ខណដែលកំណត់កត់សំគាល់សិន  បើកំណត់បានថាមានមូលហេតុដូច្នេះ ៗ អណូ-បរមាណូជាដើមដែលមាននៅជានិច្ចទើបបានឈ្មោះថាទៀង ព្រោះមូល-ហេតុដូច្នោះ ៗ  បើកំណត់បានដូច្នេះហើយក៏សមគួរនឹងជឿស្តាប់យកជាការបាន ដែលមិនកំណត់បាននូវមូលហេតុនឹងចាប់យកតែចុងហេតុមកថាអណូបរមាណូជាដើមមាននៅជានិច្ចហើយក៏បានឈ្មោះថាទៀង  នឹងថាយកតែចុងហេតុដូច្នេះមិនគួរនឹងជឿស្តាប់យកជាការបាន  ឯពាក្យដែលថាព្រះនិព្វានមាននៅជានិច្ចជាធម៌ទៀងនោះ មានលក្ខណមានកំណត់កត់សំ-គាល់នៃមូលហេតុជាសំគាល់  មានពាក្យដែលថាព្រះនិព្វានរកហេតុមិនមាននោះ ថាដោយមានឧប្បត្តិហេតុផ្សេងទេតើ  ឧប្បត្តិហេតុដែលនឹងឲ្យ

បង្កើតព្រះនិព្វាននោះគ្មានមូលហេតុដែលសម្តែងផលឲ្យឃើញថា ព្រះនិ-ព្វានទៀងនោះមាននៅជាពិត ឯពាក្យដែលថាព្រះនិព្វានទៀងនោះដោយគិច្ចដែលមិនចេះកើតមិនចេះស្លាប់ ទើងបានទៀងដោយធម្មតាក៏ទេ ហេតុអ្វីហេតុមានពាក្យដីកាតាវ្យវិសជ្ជនាថា លក្ខណដែលទើងកំណត់កត់សំគាល់ឲ្យហេតុឲ្យឃើញថា ព្រះនិព្វានទៀងនោះ ទើងបានកំណត់ដោយហេតុដែលជាបច្ចត្តលក្ខណធម្មតាជាដើមនោះមិនបាន អធិប្បាយថាហេតុឯណាមាននៅដោយធម្មតា សត្វមាននៅដោយធម្មតា លោកមាននៅទាំងពីរដូចគ្នា ទើងមានចំពោះតែប្រុសឬមានតែស្រីក៏ទេ ហេតុនោះឯងបានជាឈ្មោះបច្ចត្តលក្ខណធម្មតា ដូចយ៉ាងធូលីដែលជាអណូបរមាណូហុយនៅក្នុងអាកាសផ្ទៃប្រថពី ទំដែកលមិនមានកំណត់ធំប៉ុនគ្នាទើងយ៉ាងដូចមុន ទឹកក្នុងមហាសមុទ្រមានរសជាប្រៃ មនុស្សមានខ្លួនវែងដោយកំពស់ សត្វតិរច្ឆានមានខ្លួនវែងទៅដោយទទឹង ហេតុយ៉ាងនេះបានជាឈ្មោះថាបច្ចត្ត-ធម្មតាហេតុ ឯហេតុដែលសម្តែងផលឲ្យឃើញថាព្រះនិព្វានទៀងនោះទើងបានជាបច្ចត្តធម្មតាហេតុយ៉ាងនេះក៏ទេ ព្រះនិព្វានធម៌ទៀងនោះដោយគិច្ចដែលមិនចេះកើត មិនចេះស្លាប់ មិនចេះចាស់ជរ ឯអណូជាដើមនោះមានគិច្ច មិនចេះកើត មិនចេះស្លាប់ មិនចេះចាស់ជរ ដូចព្រះនិព្វានដែរឬដូចម្តេច បានជាអ្នកយកអណូជាដើមមកប្រៀបទើងព្រះនិព្វានថាទៀងដូចព្រះនិព្វាន ឯទើងសម្តែងផលថាអណូជាដើមទៀងនោះ ឲ្យសម្តែងមូលហេតុចេញមកឲ្យច្បាស់លាស់ ឯទើងថាចាប់យកតែគុណហេតុ

ថាអណូមាននៅជានិច្ចបានជាឈ្មោះថាទៀង  នឹងថាយ៉ាងនេះមិនគួរទេ បើអ្នកនឹងមានពាក្យប្រកែកសួរតទៅទៀតថា  ដំណើរដែលយើងយល់អធិប្បាយថាអណូបរមាណូជាដើមទៀងដូចព្រះនិព្វាន  ព្រោះថាអណូបរ-មាណូជាដើមនោះ  មិនមានឧប្បាទខណនឹងឋិតិខណៈ ភង្គខណៈ ដូចព្រះនិព្វាន ១ គេឧប្បាទខណៈ ឋិតិខណៈ ភង្គខណ គ្មានយ៉ាងណា  អណូបរ-មាណូជាដើមនោះគឺគេឧប្បាទខណៈ  ឋិតិខណ  ភង្គខណ  គ្មានដូច្នោះដែរ  ការស្រាយហេតុដូច្នោះឯង  បានជាយើងសំដែងនឹងថាអណូជាដើមនោះទៀងដូចព្រះនិព្វាន ។  បើអ្នកថាដូច្នោះមិនសមគួរដែរ  ព្រោះថាអណូជាដើមនោះ  មិនបានសម្រេចនូវការនោះទៀង  តាមពាក្យសំដីដែលអ្នកបដិញ្ញាណ  ពាក្យដែលអ្នកបដិញ្ញាណថា  អណូជាដើមទៀងនោះនឹងបានសម្រេចជាធម្មបដិញ្ញាណក៏ទេ  បើមិនសម្រេចជាធម្មបដិញ្ញាណហើយ  ក៏មិនអាចនឹងឲ្យសម្រេចផល  គឺការទៀងនោះបាន  ប្រការមួយវិញទៀត  ឧប្បាទខណនឹងឋិតិខណៈ  ភង្គខណៈនោះសោត  ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទេសនាចំពោះតែចិត្តនឹងចេតសិកប៉ុណ្ណោះ  ក្រៅអំពីចិត្តនឹងចេតសិក  នឹងបានមានឧប្បាទខណៈ ឋិតិខណៈ ភង្គខណៈក៏ទេ  ដែលអ្នកនឹងប្រកាន់យកអធិប្បាយថាអណូជាដើមទៀងដូចព្រះនិព្វាន  ព្រោះហេតុដែលគេឧប្បាទខណគ្មានដូច្នោះ  មិនឃើញមានវិសេសអ្វីទេ  មួយវិញទៀត  អណូជាដើមនោះ  តែងវិនាសដោយភ្លើងប្រល័យកល្ប  ខ្យល់ប្រល័យកល្បទឹកប្រល័យលោក ដល់នូវការជាអនិច្ចលក្ខណនឹងស្ថិតស្ថេរមាំមួនទៀង

នៅគឺទេ គឺចំណែកឯព្រះនិព្វាននោះ មិនចេះវិនាសដោយភ្លើងដោយខ្យល់ ដោយទឹកប្រល័យកល្បទេ មានលក្ខណៈរម្ងាប់ មានកិច្ចមិនបានកើត មិនបានស្លាប់ មិនបានចាស់ជក ហេតុដូច្នេះដែលអ្នកនឹងយកអណ្ដូជាដើមដែលជាធម្មជាតិតែងនឹងវិនាសប្រល័យមកប្រៀបធៀបនឹងព្រះនិព្វានដ៏ប្រសើរមិនចេះវិនាសប្រល័យមិនសមគួរទេ ធម្មជាតិទាំងឡាយមានអណ្ដូជាដើមដែលអ្នកពោលថាមានមកអំពីដើមនោះ នឹងបានជាធម្មជាតិដ៏ទៀងមែនពោះគឺទេ ព្រះនិព្វាននេះឯងនឹងថាជាធម៌ទៀងពិតឥតមានប្រែប្រួលឡើយ ពាក្យដែលថាព្រះនិព្វានទៀងនេះ គួរដោយសការសមគួរនឹងពាក្យដែលពោលមកមុន ៗ មានបញ្ហាជាដើមដែលពណ៌នាគុណនៃព្រះនិព្វានថា ព្រះនិព្វានគេដើមកំណើតគ្មាន ព្រះនិព្វានមិនចេះចាស់ជក ព្រះនិព្វានមិនចេះឈឺចាប់មិនចេះស្លាប់សោះ ពាក្យដែលសរសើរព្រះនិព្វានថាជាធម៌ទៀងអរូប ព្រះនិព្វាននេះឈ្មោះជាអរូបធម៌ដោយអត្ថថាគ្មាននូវរូប នឹងបានមានរូបសណ្ឋានពណ៌ប្រតិស្ឋានជាទីលំនៅ ៗ ក្នុងទិសឯណាមួយគឺឥតអត្ថិមានឡើយ ព្រះនិព្វាននោះឥតរូបពណ៌សណ្ឋានគឺពិតមែន តែថាមាននៅដោយបរមត្ថ ហេតុអ្វីបានជាឃើញថាមាននៅដោយបរមត្ថ អធិប្បាយថា ព្រះអរិយបុគ្គលមានសម្មប្បធានវីរិយ ដ៏មិនបានធូរថយបានសម្រេចញាណដ៏វិសេស ពោលគឺមគ្គញាណផលញាណក្នុងកាលឯណាហើយ គឺបានសម្រេចព្រះនិព្វានដោយបច្ចក្ខសិទ្ធិញាណក្នុងកាលនោះ ព្រះអរិយបុគ្គលទាំងឡាយដែលត្រាស់ដឹងជាក់ច្បាស់នូវព្រះនិព្វាននោះ លោក

ត្រាស់ដឹងជាក់ច្បាស់ដោយពិត មិនបានត្រាស់ដឹងដោយអំណាចជឿស្តាប់
ពាក្យអ្នកដទៃ ក្រៅអំពីព្រះអរិយបុគ្គល ដែលដឹងថាព្រះនិព្វានមាននោះ
ដឹងដោយអំណាចជឿស្តាប់យកតាមព្រះពុទ្ធភាសិតដែលសម្តេចព្រះសា-
ស្តាចារ្យទ្រង់ត្រាស់ទេសនាទុកដឹងដោយអនុមានបញ្ញាដែលនឹងដឹងច្បាស់
ឃើញច្បាស់ដូចព្រះអរិយបុគ្គលនោះគឺឥតអង្គីមាន អាស្រ័យហេតុដែល
ព្រះអរិយបុគ្គលនោះគឺឥតអង្គីមាន អាស្រ័យហេតុដែលព្រះអរិយបុគ្គល
ដឹងដោយបច្ចក្ខសវិញ្ញាណ បុគ្គលក្រៅអំពីព្រះអរិយបុគ្គលដឹងដោយអនុ-
មានសវិញ្ញាណ ឃើញដូចពណ៌នាមកដូច្នេះ នឹងបានឃើញច្បាស់ថា
ព្រះនិព្វាននោះមាននៅដោយបរមត្ថដោយប្រការដូច្នេះ ព្រះមហាករុណា
សម្មាសម្ពុទ្ធ មានព្រះពុទ្ធភាសិតប្រោសប្រទានធម្មទេសនាថា ម្នាលភិក្ខុ
ទាំងឡាយ ធម៌ដែលជាអារម្មណ៍នៃព្រះអរិយមគ្គអរិយផលនៃព្រះតថា-
គតហៅថាព្រះនិព្វាននោះមាននៅជាពិតព្រះនិព្វានធម៌នោះ អជាតំ មិន
បានកើតដោយហេតុបច្ច័យ អភូតំ មិនបានកើតដោយខ្លួនឯង អកតំ
បុគ្គលទាំងឡាយមានព្រះឥស្សរជាដើម មិនអាចធ្វើបានដោយកំលាំងឫទ្ធិ
កំលាំងកាយ ទុកជានឹងមានឫទ្ធានុភាពច្រើនប្រការដូចម្តេច ៗ គឺមិនអាច
នឹងតាក់តែងមិនអាចនឹងនិម្មិតនូវព្រះនិព្វាននោះបាន អសង្ខតំ ព្រះនិ-
ព្វាននោះនឹងមានកុសលាកុសលធម៌ប្រជុំតាក់តែងដូចយ៉ាងរូបធម៌នាមធម៌
ទាំងពួងនោះគឺទេ ព្រះនិព្វាននោះព្រះអង្គទ្រង់ទេសនាថាជាឧបនិស្ស័យឲ្យ
រម្ងាប់បង់នូវសង្ខារធម៌ទាំងពួង ឲ្យលះបង់នូវកិលេសទាំងពួង ពុទ្ធភ

ព្រះនិព្វាននោះជាធម៌ដ៏សុខុមគម្ភីរភាព ទុទ្ទសោ កម្របុគ្គលនឹងត្រាស់ ដឹងឃើញឲ្យជាក់ច្បាស់ ទុរនុពោធោ ក្រណាស់បើផែលនឹងត្រាស់ ដឹងឲ្យច្បាស់នូវព្រះនិព្វាន សន្តោ បណីតោ ព្រះនិព្វាននោះល្អិតក្រៃ លែងល្អិតប្រណីតបញ្ចនៃក្រៃពេក អតក្កាវចរោ បុគ្គលនឹងគិតមិនគប្បី ដឹងដោយគំនិតតិតឃកដោយខ្លួនឯង និបុណោ ព្រះនិព្វាននោះបរិបូណ៌ ទៅដោយគុណដ៏លើសលុប បណ្ឌិតវេទនិយោ បណ្ឌិតមានប្រាជ្ញាគប្បី ប្រតិបត្តិតាមព្រះអដ្ឋង្គិកមគ្គទាំង ៨ ប្រការនោះឯង ទើបប្រាកដនឹងទើបបាន ឃើញ ព្រះអង្គទ្រង់ទេសនាហៅថានិរោធសច្ចដោយអត្ថថារលត់បង់សង្ស័យ ឲ្យរលត់ទុក្ខដោយពិត ព្រះនិព្វាននេះជាសុខទៀតមិនបានប្រែទៅដោយ ទុក្ខសោកកេតភ័យឧបទ្រពចង្រៃទាំងពួងនោះ វាទៀយ សុខផែង ៗ ទទឹ សុខទៀត ដូចសុខក្នុងព្រះនិព្វាននេះមិនមានសោះ អាស្រ័យហេតុដូច្នេះ ទើបព្រះនិព្វានជាទីកើតអរជាទីប្រាថ្នានៃអរិយសប្បុរសទាំងឡាយ មាន ព្រះពុទ្ធអង្គជាប្រធាន ព្រះអរិយបុគ្គលដែលបានសម្រេចអនុបាទិសេស និព្វានធាតុ រំលត់កម្មវិបាកនិងវិបាកខន្ធអស់ស្រេចហើយនោះ ប្រាសចាក ជាតិជរាព្យាធិមរណៈ សេចក្ដីសោកក្រៀមក្រំលាល័យអស់ឥតមានសល់ ដល់នូវសេចក្ដីសុខក្សេម ដ៏លើសលុបជាងសម្បត្តិសុខទាំងពួងក្នុងមនុស្ស លោកនិងទេវលោក ហេតុដូច្នេះសុខក្នុងព្រះនិព្វាននោះសម្ដេចព្រះមហា- ករុណាទ្រង់មានព្រះពុទ្ធដីកាសរសើរថាជាឯកន្តបរមសុខពិត ៗ ជារបស់ នៃព្រះអរិយបុគ្គល ដូចន័យបានពណ៌នាមកនេះ ។

និរោធអរិយសច្ចនេះមានអត្ថ ៤ ប្រការដូចគ្នា គឺ និស្សរណដ្ឋោ មានអត្ថថារើខ្លួនចេញចាកភពប្រការ១ អបលិពោធដ្ឋោ មានអត្ថថាគេកង្វល់រវល់មិនមានប្រការ១ អសំខតដ្ឋោ មានអត្ថថាគេបច្ច័យប្រជុំតាក់តែងមិនមានប្រការ១ អមតដ្ឋោ មានអត្ថថាជាអម្រឹត្យធម៌ គឺសេចក្តីដែលមិនចេះស្លាប់ប្រការ១ ត្រូវជា ៤ ប្រការ សម្តែងអត្ថជាបឋមគឺនិស្ស-រណដ្ឋោ នោះជាលក្ខណៈនៃនិរោធសច្ចពិត ទំនងឲ្យឃើញសេចក្តីថា បុគ្គលឯណាបានសម្រេចព្រះនិព្វានហើយ បុគ្គលនោះគឺទំនងលើកខ្លួនចេញឲ្យផុតចាកវដ្តសង្សារ លែងកើតលែងស្លាប់លែងវិលយកកំណើតកើតក្នុងភពថ្មីទៅទៀត បញ្ជាក់ឈ្មោះថាបានសម្រេចព្រះនិព្វានហើយ ទៀតតែទំនងលើកខ្លួនចេញឲ្យផុតអំពីវដ្តសង្សារ សម្តេចព្រះសាស្តាហារប់ពោះទំនងឲ្យឃើញអធិប្បាយដូច្នេះ ទើបសម្តែងអត្ថជាបឋមគឺ និស្សរណដ្ឋោ ជាលក្ខណៈនៃនិរោធសច្ចដោយប្រការដូច្នេះ ឯអត្ថជាគំរប់ ២ គឺអបលិពោធដ្ឋោ នោះមានអធិប្បាយខ្ទះដល់សមុទយសច្ច ដើម្បីទំនងឲ្យឃើញសេចក្តីថាសត្វទាំងពួងដែលទំនងកង្វល់រវល់ដោយកិលេសកាមវត្ថុកាមនោះ កើតព្រោះសន្តានទៅប្រកបដោយតណ្ហា បើបានសម្រេចព្រះនិព្វានផ្តាច់តណ្ហាបង់បានដាច់ចេញពីសន្តានអស់ហើយក៏ទំនងអស់ធុរៈកង្វល់រវល់ទាំងពួងទំនងមិនបានរវល់កង្វល់ដោយកិលេសកាមវត្ថុកាមតទៅ ព្រោះអត្ថទ្រង់សំដៅទំនងឲ្យឃើញសេចក្តីហេតុដល់សមុទយសច្ចដូច្នេះ ហើយសម្តែងអត្ថគឺ អបលិពោធដ្ឋោ ជាអត្ថនៃនិរោធសច្ចជាគំរប់ ២ ឯអត្ថជាគំរប់ ៣ គឺអសំខតដ្ឋោ នោះមាន

អត្ថាធិប្បាយនុ៎ះហេតុផលមគ្គសច្ច ដើម្បីនឹងឲ្យឃើញសេចក្ដីថា ព្រះយោ-
គាវចរអ្នកមានប្រាជ្ញាពិចារណាឃើញថាជាងផ្ទះ គឺ តណ្ហានោះជាអ្នកតាក់
តែងគ្រឿងផ្ទះ គឺរូបកាយដល់សត្វទាំងពួងឲ្យសត្វដល់ទុក្ខលំបាកក្នុងផ្ទះ
របស់ខ្លួនដែលនឹងគិតរិះរកឧបាយគេចវៀររត់ចេញអំពីផ្ទះ ដែលតណ្ហាតាក់
តែងឲ្យនោះគង់អាស្រ័យសេចក្ដីប្រតិបត្តិតាមមគ្គសច្ចនោះៗ ទើបនឹងជា
ឧបាយរលាស់ខ្លួនឲ្យរួចចេញអំពីផ្ទះនៃតណ្ហានោះបាន នាយជាងផ្ទះគឺ
តណ្ហាក៏មិនអាចរចនាតាក់តែងផ្ទះ គឺរូបកាយនោះបានតទៅទៀត អាស្រ័យ
នឹងសេចក្ដីប្រតិបត្តិតាមមគ្គសច្ច សម្ដេចព្រះមុនីសរពេជ្ញ ទ្រង់ចំពោះនឹងឲ្យ
ឃើញសេចក្ដីនុ៎ះហេតុផលមគ្គសច្ចនុ៎ះ បានជាសម្ដែងអត្ថគឺអសំខតគ្គោ
ជាអត្ថនៃនិរោធសច្ចជាគំរប់ ៣ ឯអត្ថជាគំរប់ ៤ គឺអមតគ្គោ នោះមានអត្ថា-
ធិប្បាយនុ៎ះហេតុផលទុក្ខអរិយសច្ច គឺនឹងឲ្យឃើញថានិរោធសច្ចនោះជាទឹក
អម្រឹតស្រោចស្រប់រំងាប់រោគពោលគឺកងទុក្ខទាំងពួង បុគ្គលដែលកើតរោគ
១២ ប្រការ មានរោគវិលស្លាប់វិលកើតវិលយកកំណើតជាដើមជាប្រធាន
បើបានក្រេបផឹកនូវទឹកអម្រឹតពោលគឺនិរោធសច្ចហើយចាំជាវិសេស រោគ
១២ប្រការ មានរោគគឺជាតិទុក្ខជាដើមនោះ ក៏នឹងរម្ងាប់សាបសូន្យសោះ-
ទៅដោយពិត កងទុក្ខទាំងពួងនឹងរម្ងាប់សាបសូន្យទៅនោះ អាស្រ័យ
នឹងព្រះនិព្វាន សម្ដេចព្រះសាក្យមុនីគោតមបរមសម្ពុទ្ធជាគ្រូ លោក
ទ្រង់នុ៎ះពន្យល់សេចក្ដីបំភ្លឺដល់ទុក្ខអរិយសច្ចនុ៎ះ បានជាសម្ដែងអត្ថគឺ អ-
មតគ្គោ ជាអត្ថនិរោធអរិយសច្ចជាគំរប់ ៤ សរុបបញ្ចូលផងគ្នា ហើយទើប

ត្រូវជាមគ្គនិរោធអរិយសច្ច ៤ ប្រការ សម្ដែងមកក្នុងនិរោធអរិយសច្ចក៏ចប់តែប៉ុណ្ណេះ ។

ពីនេះនឹងវិសជ្ជនាក្នុងមគ្គអរិយសច្ចតទៅមានបទពាក់ព្រះបាឡីថា

កតមញ្ច ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចំ អយ-
មេវ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ
សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មា-
អាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ

ដំណើរសេចក្ដីថាសម្ដេចព្រះមហាករុណាអនន្តញាណកាលត្រាស់ប្រកាសព្រះធម៌ទេសនា ក្នុងទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ទ្រង់ត្រាស់ទេសនាជាគាថាក្នុងគម្ពីរបុព្វថា កតមញ្ច ទុក្ខនិរោធគាមិនីប-ដិបទាអរិយសច្ចំ ម្នាលភិក្ខុទាំងឡាយ ផ្លូវប្រតិបត្តិដើម្បីនឹងទៅដល់នូវកិរិយារលត់ទុក្ខឲ្យស្រេចព្រះនិព្វានសុខនោះ ជាសេចក្ដីពិតជាសេចក្ដីមែនរបស់ព្រះអរិយបុគ្គលនោះតើដូចម្ដេច ទើបទ្រង់វិសជ្ជនាដោយព្រះអង្គឯងថា អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ផ្លូវប្រតិបត្តិគឺអដ្ឋង្គិក-មគ្គប្រកបដោយអង្គ ៨ ប្រការនេះ អាចនឹងរំលត់ទុក្ខបានឲ្យស្រេចដល់ព្រះនិព្វាន ជាសេចក្ដីពិតរបស់ព្រះអរិយបុគ្គលដោយពិត ឥតមានឃ្លាតព្រះអរិយបុគ្គលទាំងឡាយមានព្រះពុទ្ធជាប្រធាននោះ លោកសឹងប្រតិ-បត្តិទ្រង់នឹងដំណើរតាមផ្លូវ គឺព្រះអដ្ឋង្គិកមគ្គនេះគ្រប់ព្រះអង្គ ព្រោះថាអដ្ឋ-

ង្គិកមគ្គនេះជាទីផុតបំផ្លាញរំលាស់បង់នូវកងកិលេស ហើយឱ្យសម្រេចនូវមគ្គញាណផលញាណនិងព្រះនិព្វានជាបរិយោសានទីបំផុត ។ ប្រការមួយវិញទៀត ព្រះអដ្ឋង្គិកមគ្គនេះឆ្ងាយអំពីសត្រូវគឺកិលេស ដូចជាស្ដេចចក្រពត្រាធិរាជដ៏ឆ្ងាយចាកអរិន្ទុកដបច្ចាមិត្តទាំងពួង ពុំនោះសោត ព្រះអដ្ឋង្គិកមគ្គនេះជាទីហូរមកជាទីប្រជុំនៃពោធិបក្ខិយធម៌ ៣៧ ប្រការ ដូចមហាសមុទ្រជាទីហូរមក ជាទីប្រជុំនៃស្ទឹងតូចធំទាំងពួង ឬថាដូចដួងកែវមណីកំពូលពេជយរត្នប្រាសាទ អគ្គិអមរិន្ទទេវរាជនាពិភពត្រៃត្រឹង្ស ព្រះអដ្ឋង្គិកមគ្គនេះ តែងឲ្យសម្រេចសេចក្ដីប្រាថ្នាដល់ទេវតានិងមនុស្សដែលជាពុទ្ធវេនេយ្យសត្វ ដូចជាដួងកែវមណីជាតិ ៨ ជ្រុងដ៏ធំ អាចឲ្យសម្រេចសេចក្ដីប្រាថ្នាដល់ស្ដេចមហាចក្រពត្តិរាជ ព្រះអដ្ឋង្គិកមគ្គទាំង៨ប្រការនេះ បើបុគ្គលឯណាប្រតិបត្តិតាមហើយ បុគ្គលនោះនឹងបានរុងរឿងជាងទេវតានិងមនុស្ស ដូចព្រះបាទកុសរាជដ៏មានរូបអាក្រក់ក្រៃលែង កាលបើបានកែវមកអំពីសម្ដេចអមរិន្ទ្រាធិរាជ ក៏ត្រឡប់ជាមានរូបឆោមល្អឆើតឆាយសោភាឡើងដោយអានុភាពនៃកែវនោះ មួយវិញទៀតវេជយន្តរថអគ្គិអមរិន្ទកោសីយនោះ ជារថដ៏ប្រសើរកើតដោយអំណាចផលនៃកុសល ដែលបានសាងសន្សំបន្ទុំមកអំពីបុព្វជាតិ ឯវេជយន្តរថនោះដ៏ទឹមដោយសេះសិន្ធពមួយពាន់ មានព្រះមាតលីទេវបុត្រជានាយទេពសារថី សម្ដេចព្រះសហស្សនេត្រអគ្គទេវរាជនោះ តែងគង់បរចេញទៅផ្ចាញ់ពួកអសុរនិកាយឲ្យបរាជ័យចាលចាញ់ដោយអានុភាពនេះបានដូចស្ដេច

មិញ ព្រះអដ្ឋង្គិកមគ្គនេះជារថដ៏ប្រសើរ ប្រដាប់ដោយពោធិបក្ខិយធម៌ ៣៧. ប្រការ ដោយសប្បុរសព្រះអរិយសប្បុរសទាំងពួងដែលជិះបរ ដ៏ប្រតិបត្តិតាម គឺតែងដឹកនាំព្រះអរិយសប្បុរសទាំងនោះ ឲ្យទៅផ្ចាញ់នូវពពួកមារ គឺតណ្ហាទិនិកាយកិលេសជាដើមឲ្យបរាជ័យចាលចាញ់នៅនាសង្គ្រាមកាលនោះហើយឲ្យឡើងកាន់ប្រាសាទគឺអមតមហានគរគឺព្រះនិព្វានដ៏ជាទីក្សេមក្សាន្ត ប្រាសចាកជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ ជាឯកន្តបរមសុខដោយពិតៗមែន ដូចជាពេជយន្តរថនោះមែន ៈបុគ្គលបានប្រាថ្នាទឹងទៅកាន់នគរនៃពោលគឺព្រះនិព្វាននោះ ១០០ នាក់ក្ដី ១០០០ នាក់ក្ដី ១០.០០០ នាក់ក្ដី ១០០.០០០ នាក់ក្ដី រថពោលគឺព្រះអដ្ឋង្គិកមគ្គទាំង ៨ ប្រការនេះ ក៏អាចនាំនូវវេនេយ្យបុគ្គលទាំងអម្បាលនោះទៅដាក់ឲ្យដល់នគរនិព្វាន មិនមានឲ្យសេសសល់ឯលម្នាក់ឡើយ ព្រះអដ្ឋង្គិកមគ្គនេះមានគុណូបការដ៏ប្រសើរលើសលប់ឥតអ្វីនឹងផ្ទឹមបាន បណ្ដាសាធុជនដែលមានកុសលសម្ភារបានកសាងសន្សំមកជាច្រើនហើយបានត្រាស់ដឹងព្រះចតុរ-រិយសច្ចទាំង ៤ រថពោលគឺព្រះអដ្ឋង្គិកមគ្គនេះ ក៏អាចនឹងដឹកនាំជញ្ជូនសា-ធុជនទាំងនោះទៅ ឲ្យដល់នគរនិព្វានមួយរំពេច តែមួយខណចិត្តក៏ដល់ ដូចជាលើកឡើងឲ្យផុតអំពីប្រថពី ហើយដាក់ឲ្យដល់កំពូលភ្នំសុមេរុរាជ ហើយដាក់លាទុកលើកំពូលសុមេរុរាជ ពុំនោះសោតព្រះអដ្ឋង្គិកមគ្គនេះមានឧបមាដូចសំពៅដ៏ធំបើកល្បឿនទៅក្នុងមហាសមុទ្រសាគរហើយ ញុំាងពួកពាណិជទាំងឡាយឲ្យដល់នូវទីកំពង់ចតឈ្មោះថាកុសាវតី ពួកពាណិជ

ទាំងឡាយក៏បាននូវសេចក្ដីក្សេមក្សាន្ត ប្រាសចាកភ័យអន្តរាយ នោះដូចម្ដេច សាធុជនទាំងឡាយកាលបើបានដល់នូវនិព្វានហើយ ក៏ប្រាសចាកកងទុក្ខទាំងពួងមានឧបមេយ្យដូច្នោះឯង ។

សម្ដេចព្រះសាស្ដាទ្រង់ត្រាស់បុច្ឆាព្រះអង្គឯងថា តើអរិយ-ផ្លូវធំ ព្រះអដ្ឋង្គិកមគ្គទាំង ៨ ប្រការនោះ គឺអ្វីខ្លះ ទើបទ្រង់វិសជ្ជនាថា ព្រះអដ្ឋង្គិកមគ្គ ៨ ប្រការនោះ គឺ សម្មាទិដ្ឋិ ១ សម្មាសង្កប្បោ ១ សម្មាវាចា ១ សម្មាកម្មន្តោ ១ សម្មាអាជីវោ ១ សម្មាវាយាមោ ១ សម្មា-សតិ ១ សម្មាសមាធិ ១ ត្រូវជា ៨ ប្រការដោយឧទ្ទេសករ ។

ក្នុងនិទ្ទេសករនោះទ្រង់សម្ដែងថា

តត្ថ កតមា សម្មាទិដ្ឋិ ទុក្ខេ ញាណំ ទុក្ខសមុទ-
យេ ញាណំ ទុក្ខនិរោធេ ញាណំ ទុក្ខនិរោធគា-
មិនិបដិបទាយ ញាណំ អយំ វុច្ចតិ សម្មាទិដ្ឋិ

អង្គនៃព្រះអរិយមគ្គឈ្មោះថាសម្មាទិដ្ឋិនោះដូចម្ដេច ទ្រង់វិសជ្ជនាថា សម្មាទិដ្ឋិនោះបាននឹងបញ្ញាចេតសិកដ៏ក្លាហាន តោងយកព្រះនិព្វានមក ជាអារម្មណ៍ ហើយដឹងច្បាស់ក្នុងទុក្ខសច្ច ដឹងច្បាស់ក្នុងទុក្ខសមុទយសច្ច ដឹងច្បាស់ក្នុងទុក្ខនិរោធសច្ច ដឹងច្បាស់ក្នុងទុក្ខនិរោធគាមិនីបដិបទាសច្ច ឬមគ្គសច្ច ហើយប្រតិបត្តិដកកំលើងបង់នូវអវិជ្ជានិងតណ្ហានោះ ឈ្មោះថា សម្មាទិដ្ឋិ ជាអង្គនៃព្រះអរិយមគ្គជាបឋម ។

អត្ថនៃព្រះអរិយមគ្គជាគំរប់២ ឈ្មោះថាសម្មាសង្កប្បៈនោះតើដូចម្ដេច ថាសម្មាសង្កប្បៈនោះបានខាងនឹងតែក្នុងចេតសិក ដែលជាសភាវសម្រាប់ដំរិះ ត្រិះរិះទៅក្នុងកិច្ចការដែលនឹងបំពេញខាងនេក្ខម្មៈ ល់ចំរើនភាវនាក្នុងអសុភកម្ម-ដ្ឋានក្ដី ដំរិះទៅក្នុងកិច្ចការដើម្បីមិនបានចងព្យាបាទ ការឃាតចង់បៀតបៀនគ្នាក្ដី ដំរិះទៅក្នុងកិច្ចដែលនឹងចំរើនចត្តព្រហ្មវិហារ មានមេត្តាជាដើមនោះក្ដី ដំរិះទៅក្នុងកិច្ចការដែលមិនបានបៀតបៀនសព្វសត្វទាំងពួងនោះក្ដី ព្រះតថាគតពោលថាសម្មាសង្កប្បៈ ជាអត្ថនៃព្រះអរិយមគ្គជាគំរប់ ២ ។

អត្ថនៃព្រះអរិយមគ្គជាគំរប់៣ គឺសម្មាវាចានោះតើដូចម្ដេច ព្រះអរិយមគ្គជាគំរប់ ៣ នោះ បានខាងនឹងវចីសុចរិត ៤ ប្រការ មុសាវាទាវេរ-ណី វៀរចាកមុសាវាទកុហកបញ្ឆោតលួងឲ្យខូចប្រយោជន៍អ្នកដទៃ ១ បេសុញ្ញាវាចាវេរមណី វៀរចាកពាក្យស៊កសៀតញុះញង់បំបែកអ្នកដទៃឲ្យគេបានសេចក្ដីក្ដៅក្រហាយ ១ ផរុសវាចាវេរមណី វៀរចាកពាក្យអាក្រក់ចាក់ដោតត្រចៀកអ្នកដទៃ មានជេរប្រទេចផ្ដាសាជាដើម ១ សម្ផប្ប-លាបវាចាវេរមណី វៀរចាកកំប្លែងគ្មានគតិពោលក្រមាច់តំរែងលេងពាក្យឥតប្រយោជន៍ ១ វចីសុចរិត ៤ ប្រការនេះ ព្រះតថាគតពោលថាសម្មាវាចាជាអត្ថនៃព្រះអរិយមគ្គជាគំរប់ ៣ ។

អត្ថនៃអរិយមគ្គជាគំរប់ ៤ គឺសម្មាកម្មន្តនោះ តើដូចម្ដេច សម្មា-កម្មន្តនោះ បានខាងនឹងកាយសុចរិត ៣ ប្រការ គឺបាណាតិបាតាវេរមណី

វៀរចាកសម្លាប់សត្វដែលមានជីវិតរស់នៅ ឲ្យផ្តាច់បង់ចាកជីវិត ១ អទិន្នា-
ទានាវេរមណី វៀរចាកលបលួចយកទ្រព្យអ្នកដទៃដែលគេមិនបាន
អនុញ្ញាតឲ្យដោយកាយវាចាដោយថេយ្យចិត្ត ១ កាមេសុមិច្ឆាចារាវេរមណី
វៀរចាកប្រព្រឹត្តការគន្លងប្រវេណី ដោយភរិយាអ្នកដទៃនិងស្រីដែលមិន
មែនជាភរិយាខ្លួន ១ កាយសុចរិតទាំង ៣ ប្រការនេះ ព្រះតថាគតពោល
ថាសម្មាកម្មន្ត ជាអង្គនៃព្រះអរិយមគ្គជាគំរប់ ៤ ។

អង្គនៃព្រះអរិយមគ្គជាគំរប់ ៥ គឺសម្មាអាជីវៈនោះតើដូចម្តេច ទ្រង់
សំដែងថា ព្រះអរិយសាវកក្នុងព្រះពុទ្ធសាសនានេះ ប្រតិបត្តិលះបង់នូវ
មិច្ឆាអាជីវៈ គឺចិញ្ចឹមជីវិតមិនប្រកបដោយធម៌ ប្រកបតែដោយអនេសនៈ
មានផ្សំប្រសបនិងវេជ្ជកម្មជាដើម ហើយដំកល់នៅក្នុងសម្មាអាជីវៈចិញ្ចឹម
ជីវិតប្រកបដោយធម៌ជាទីសរសើរនៃព្រះអរិយបុគ្គលទាំងឡាយ ព្រះតថា-
គតពោលថាសម្មាអាជីវៈ ជាអង្គនៃព្រះអរិយមគ្គជាគំរប់ ៥ ។

អង្គនៃព្រះអរិយមគ្គជាគំរប់៦ គឺសម្មាវាយាមៈ នោះតើដូចម្តេច ទ្រង់
សំដែងថា អង្គនៃព្រះអរិយមគ្គជាគំរប់ ៦ បាននាមនឹងសម្មប្បធាន ៤ ប្រការ
គឺព្រះអរិយសាវកក្នុងព្រះពុទ្ធសាសនាប្រកបព្យាយាមដើម្បីលះបង់នូវអំ-
ពើអកុសលដែលកើតឡើងហើយឲ្យដាច់ចេញស្រឡះអំពីសន្តានប្រការ១
គឺព្យាយាមដើម្បីកំចាត់បង់នូវអំពើអកុសល ដែលមិនទាន់បង្កើតឡើង
មិនឲ្យកើតឡើងបាន ១ ប្រឹងព្យាយាមកំចាត់បង់ឲ្យអស់អំពីសន្តានប្រ-
ការ ១ គឺព្យាយាមញុំាងកុសលធម៌បណ្តាដែលមិនទាន់កើតឡើង ឲ្យ

កើតឡើងក្នុងសន្តានឲ្យទាល់តែបានប្រការ ១ គឺព្យាយាមរក្សាកុ-
សលធម៌ បណ្តាដែលកើតមាននៅក្នុងសន្តានហើយមិនឲ្យត្រូវបាត់នាស
ទៅទៀតតែចំរើនឡើង ឲ្យជាថាវរណនាការឡើងក្នុងសន្តានឲ្យទាល់តែ
បានប្រការ ១ ព្យាយាមទាំង ៤ ប្រការនេះ ព្រះតថាគតពោលថា
សម្មាវាយាមោ ជាអង្គនៃព្រះអរិយមគ្គជាគំរប់ ៦ ។

អង្គនៃព្រះអរិយមគ្គជាគំរប់ ៧ គឺសម្មាសតិនោះតើដូចម្តេច ព្រះនិទ្ទេស-
នាថា អង្គព្រះអរិយមគ្គជាគំរប់ ៧ គឺសម្មាសតិនោះបានដល់សតិបដ្ឋាន ៤
ប្រការ គឺកាយានុបស្សនាសតិបដ្ឋាន ១ វេទនានុបស្សនាសតិបដ្ឋាន ១
ចិត្តានុបស្សនាសតិបដ្ឋាន ១ ធម្មានុបស្សនាសតិបដ្ឋាន ១ ត្រូវជា ៤ ប្រការ
អធិប្បាយថា សតិដំកល់នៅក្នុងរូបក្ខន្ធ យករូបជាអារម្មណ៍ ពិចារណា-
ជាអនិច្ចំ ទុក្ខំ អនត្តា នោះហើយបានឈ្មោះថា កាយានុបស្សនាសតិ-
បដ្ឋាន សតិដំកល់នៅក្នុងវេទនាក្ខន្ធ យកវេទនាជាអារម្មណ៍ ពិចារណា
វេទនាថា អនិច្ចំ ទុក្ខំ អនត្តា នោះហើយបានឈ្មោះថា វេទនានុបស្សនា-
សតិបដ្ឋាន សតិដែលដំកល់នៅក្នុងវិញ្ញាណក្ខន្ធ យកវិញ្ញាណជាអារម្ម-
ណ៍ ពិចារណាវិញ្ញាណថា អនិច្ចំ ទុក្ខំ អនត្តា នោះហើយបានឈ្មោះ
ថា ចិត្តានុបស្សនាសតិបដ្ឋាន សតិដែលដំកល់នៅក្នុងសញ្ញាក្ខន្ធ និង
សង្ខារក្ខន្ធយកសញ្ញានិងសង្ខារជាអារម្មណ៍ ពិចារណាសញ្ញានិងសង្ខារ
ថា អនិច្ចំ ទុក្ខំ អនត្តានោះហើយបានឈ្មោះថា ធម្មានុបស្សនាសតិបដ្ឋាន
រូបក្ខន្ធនោះជាទីដំកល់នៃកាយានុបស្សនាសតិបដ្ឋាន វិញ្ញាណក្ខន្ធជាទីដំ-

គល់នៃចិត្តានុបស្សនាសតិប្បដ្ឋាន សញ្ញាក្ខន្ធនឹងសំខារក្ខន្ធនោះជាទីដ៏គល់នៃធម្មានុបស្សនាសតិប្បដ្ឋានដូចប្រទេសទីជ័យភូមិដ៏ជាទីដ៏គល់នៃសេនាដំរីសេនាសេះសេនារថសេនាថ្មើរជើងទាំងពួង អធិប្បាយថាព្រះបរមក្សត្រិយ៍ទ្រង់ប្រាថ្នានឹងធ្វើការសង្គ្រាមដោយអរិន្ទកជនោះ កាលបើបានប្រទេសជ័យភូមិល្អ តាំងនៅគ្រប់សេនាទាំង ៤ ពួកក្នុងទីជ័យភូមិហើយក៏កេចទីនក្រុកនញាំញីនូវពពួកអរិន្ទកជ ឲ្យបរាល័យចាញ់គេជនះឥទ្ធានុភាពអប្បក្ខជ័យសេយ្យជាតិ នេះមានឧបមាដូចម្តេច ព្រះមហាក្សត្រិយ៍ពោលគឺព្រះយោគាវចរកុលបុត្រ ប្រាថ្នានឹងតតាំងច្បាំងនឹងកិលេសនោះគំនប្បីតាំងសេនាពលខ្លួនទាំង ៤ គឺកាយានុបស្សនាសតិប្បដ្ឋាន វេទនានុបស្សនាសតិ-ប្បដ្ឋាន ចិត្តានុបស្សនាសតិប្បដ្ឋាន ធម្មានុបស្សនាសតិប្បដ្ឋានក្នុងទីជ័យ-ភូមិពោលគឺរូបក្ខន្ធ វេទនាក្ខន្ធ សញ្ញាក្ខន្ធ សំខារក្ខន្ធ វិញ្ញាណក្ខន្ធ តតាំងច្បាំងផ្ចាញ់កិលេសមារបំបាក់បង់នូវសត្រូវពោលគឺកិលេសមារ ឲ្យអប្បក-ជ័យបរាល័យចាញ់វិនាសបាក់បែកខ្ចាត់ខ្ចាយស្ងាត់ទៅមិនបាន មានឧបមេយ្យដូ-ច្នោះឯង បណ្ឌិតគប្បីសន្និដ្ឋានចុះថាសតិតែមួយប៉ុណ្ណោះ តែចែកចេញទៅជាសតិប្បដ្ឋាន ៤ ប្រការ ដោយអំណាចកាន់យកនូវអារម្មណ៍ផ្សេង ៗ គ្នាជាផ្លូវដំណើរនៃព្រះអរិយបុគ្គល ហេតុដូច្នោះសម្តេចព្រះមហាករុណាទ្រង់ត្រាស់ទេសនាថា កិរិយាដែលព្រះយោគាវចរកុលបុត្រដំកល់សតិជា ៤ ស្ថាននេះហៅថា សម្មាសតិ ៗ

កត្តុក្រាតម្មោសមាធិ ព្រះអរិយមគ្គឈ្មោះថាសម្មាសមាធិនោះ

តើដូចម្តេច ទ្រង់វិសជ្ជនាថា ភិក្ខុក្នុងព្រះពុទ្ធសាសនានេះញុំាងចិត្តឲ្យស្ងាត់ចាកកិលេសកាមនិងវត្ថុកាម ហើយចូលបឋមជ្ឈាន ទុតិយជ្ឈាន តតិយ-ជ្ឈានចតុត្ថជ្ឈានដោយសមាធិចិត្តមានក្នុងឈានទាំង ៤ នោះ អធិប្បាយថា ២ យ៉ាងជាចតុក្កន័យម្យ៉ាង ជាបញ្ចកន័យម្យ៉ាង ក្នុងចតុក្កន័យនោះនិយាយដោយឈាន ៤ គឺបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ក្នុងបឋមជ្ឈានមានអង្គ ៥ គឺវិតក្ក១ វិចារ១ បីតិ១ សុខ១ ឯកគ្គតា ១ ក្នុងទុតិ-យជ្ឈានមានអង្គ ៣ គឺ បីតិ១ សុខ ១ ឯកគ្គតា ១ ក្នុងតតិយជ្ឈានមានអង្គ ២ គឺ សុខ ១ ឯកគ្គតា ១ ក្នុងចតុត្ថជ្ឈានមានអង្គ ២ គឺ ឯកគ្គតា ១ ឧបេក្ខា ១ នេះចាត់ដោយចតុក្កន័យ បើនឹងចាត់ដោយបញ្ចកន័យវិញ ក្នុងបឋមជ្ឈានមានអង្គ ៥ ដូចគ្នា ទុតិយជ្ឈានមានអង្គ ៤ គឺ វិចារ១ បីតិ១ សុខ១ ឯកគ្គតា ១ ក្នុងតតិយជ្ឈានមានអង្គ ៣ គឺ បីតិ ១ សុខ ១ ឯកគ្គតា ១ ក្នុងចតុត្ថជ្ឈានមានអង្គ ២ គឺ សុខ ១ ឯកគ្គតា ១ ក្នុងបញ្ចមជ្ឈានមានអង្គ ២ គឺ ឯកគ្គតា ១ ឧបេក្ខា ១ ពោលមកទាំងនេះដើម្បីនឹងឲ្យឃើញថា ឯកគ្គតា នឹងសមាធិចិត្តនោះមាននៅគ្រប់ឈាន ឯសមាធិចិត្តនោះ បើចែកដោយពិស្តារមាន ៣ ប្រការ គឺខណិកសមាធិ ១ ឧបចារសមាធិ ១ អប្បនាសមាធិ ១ ឯខណិកសមាធិនោះបានខាងឯចិត្តយើងកល់គ្នា ដំកល់មិនបានយូរប៉ុន្មាន បានតែខណចិត្ត ១ គឺមួយសំកាំងត្រៀកដ៏ប៉ុណ្ណោះ ក៏ឈ្មោះថាខណិក-សមាធិ ។

ឯឧបចារសមាធិនោះ បានខាងឯចិត្តដំកល់មាំចុះក្នុងខណធិគន្ធិ

បានបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន បញ្ចមជ្ឈាន នេះ ឈ្មោះថាឧបចារសមាធិ ។

ឯអប្បនាសមាធិនោះ បានខាងឯចិត្តដែលបានឈានហើយ មានបឋមជ្ឈានជាដើមជាប្រធាន ចិត្តដែលដល់មាំទៅក្នុងឈានទាំង ៤ នោះ ឈ្មោះថា អប្បនាសមាធិ អ្នកប្រាជ្ញគប្បីសន្និដ្ឋានចុះថា សមាធិនេះមានលក្ខណៈធ្វើឲ្យចិត្តតាំងទៅមាំមួនក្នុងអារម្មណ៍តែមួយ មិនឲ្យចិត្តនោះរាយមាយសោប់សែលវិលវល់ទៅក្នុងអារម្មណ៍ដទៃ ដឹងជាពាហិរហេតុ សមាធិនេះជាប្រធាននៃការកុសលទាំងពួង ។ នឹងសម្រេចក៏អាស្រ័យនឹងសមាធិចិត្តនេះឯង ជាទីប្រជុំនូវកុសលទាំងពួង ដូចជាកំពូលក្នុងការប្រាសាទ ជាទីប្រជុំនៃគ្រឿងទព្វសម្ភារទាំងពួង គ្រឿងទព្វសម្ភារទាំងនោះប្រជុំក្នុងកំពូលប្រាសាទនោះមានឧបមាដូចម្តេច ក្នុងការកុសលទាំងពួងក៏ប្រជុំចុះក្នុងសមាធិមានឧបមេយ្យដូច្នោះឯង គប្បីចូលចិត្តថា ក្នុងការកុសលទាំងអស់ដែលនឹងមានផលច្រើននោះ ក៏អាស្រ័យនឹងសមាធិចិត្ត មួយវិញទៀត កិច្ចក្នុងព្រះបវរពុទ្ធសាសនានេះនឹងសម្រេចបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន បញ្ចមជ្ឈាន ក៏តែងសម្រេចដោយសមាធិចិត្ត មួយវិញទៀត ព្រះអរិយបុគ្គលទាំងឡាយនឹងសម្រេចមគ្គញាណផលញាណ ព្រះនិព្វាន ក៏អាស្រ័យនឹងសមាធិចិត្ត នេះជាទីសរសើរនៃព្រះអរិយបុគ្គលទាំងឡាយទាំងពួង ហេតុដូច្នោះព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងថាសម្មាសមាធិនេះ ជាអង្គនៃព្រះអរិយមគ្គជាគំរប់ ៨ ដូច្នេះ បណ្ឌិតគប្បីពិចារណា

មើលចុះថា ព្រះអដ្ឋង្គិកមគ្គទាំង ៨ ប្រការនេះ តែងកើតក្នុងភូមិទាំង ៤ គឺកា-
មាវចរភូមិ រូបាវចរភូមិ អរូបាវចរភូមិ លោកុត្តរភូមិ កាលបើកើតក្នុងលោ-
កុត្តរភូមិ គឺបានឈ្មោះថាលោកុត្តរមគ្គ ដូចបានពណ៌នាមកហើយ កាលបើ
កើតក្នុងកាមាវចរភូមិ គឺបានឈ្មោះថាលោកិយមគ្គ ឯមគ្គជាលោកិយមាន
ក្នុងកាមាវចរនោះ ព្រះយោគាវចរសប្បុរសអ្នកមានសទ្ធា ធ្វើការកុសល
ប្រតិបត្តិបំពេញទានរក្សាសីលចំរើនមេត្តាភាវនាស្តាប់ព្រះធម៌ទេសនាជា
ប្រធាន អធិប្បាយថាព្រះយោគាវចរបំពេញក្នុងកាលឯណា • គឺឈ្មោះ
ថាប្រតិបត្តិតាមអដ្ឋង្គិកមគ្គក្នុងកាលនោះ បើបានរក្សាសីលក្នុងកាលឯណា
គឺបានឈ្មោះថាប្រតិបត្តិតាមព្រះអដ្ឋង្គិកមគ្គក្នុងកាលនោះ បើបានចំរើន
ភាវនាស្តាប់ព្រះធម៌ទេសនាក្នុងកាលឯណា គឺបានឈ្មោះថាប្រតិបត្តិតាម
ព្រះអដ្ឋង្គិកមគ្គក្នុងកាលនោះ ព្រោះហេតុថាព្រះអដ្ឋង្គិកមគ្គ ៨ ប្រការនេះ
កើតព្រមដោយទានសីលភាវនាការកុសលទាំងពួងនោះសព្វៗ គ្រាបណ្ឌិត
គប្បីពិចារណាមើលផលានិសង្សសីលទានជាដើម ថាក្នុងការកុសលទាំង
នេះអាចឲ្យសម្រេចនៃត្រៃពិធសម្បត្តិ ៣ ប្រការ កាលបើបញ្ញាចាក់ធ្លុះដឹង
យល់ឃើញដូច្នោះគឺចាត់ឈ្មោះថាសម្មាទិដ្ឋិកើតឡើងក្នុងសន្តាន តក្ក-
ចេតសិកដែលត្រិះរិះក្នុងកុសលមានទានសីលជាដើមនោះគឺចាត់ឈ្មោះ
ថា សម្មាសង្កប្បោ កើតឡើងក្នុងសន្តានវិរតិត្រ័យចេតសិកដែលវៀរចាក
វចីទុច្ចរិតវៀរចាកកាយទុច្ចរិត វៀរចាកមិច្ឆាជីវចិញ្ចឹមជីវិតខុសធម៌ក្នុងខណ
ដែលបំពេញទានរក្សាសីលចំរើនភាវនានោះគឺចាត់ឈ្មោះថា សម្មាវាចា

សម្មាកម្មន្តោ សម្មាអាជីវោកើតឡើងក្នុងសន្តាន វិរិយចេតសិកព្យាយាមក្នុង
កងការកុសលមានទានសីលជាដើមក៏បានឈ្មោះថា សម្មាវាយាមោកើត
ឡើងក្នុងសន្តាន សតិចេតសិកដែលរឭកក្នុងកងការកុសលជានិច្ចនោះក៏
បានឈ្មោះថាសម្មាសតិកើតឡើងក្នុងសន្តាន ឯកគ្គតាចេតសិកដែលញ៉ាំង
ចិត្តឲ្យដំកល់នឹងមាំមួនមិនបានបលាបលក្នុងកងការកុសល មានទានសីល
ជាដើមក៏បានឈ្មោះថា សម្មាសមាធិកើតឡើងក្នុងសន្តាន សំដែងមកទាំង
នេះដោយសំណាកព្រោះអដ្ឋង្គិកមគ្គ កើតក្នុងកាមាវចរជាលោកិយមគ្គប្រ-
ការ១ ព្រោះយោគាវចរចំរើនសមថកម្មដ្ឋានគរនោ លុះបានសម្រេចបឋម-
ជ្ឈានហើយ ចេតសិកទាំង៥ គឺបញ្ញា១ វិរិយ១ សតិ១ វិតក្ក១ ឯកគ្គតា១
ចេតសិកទាំង៥នេះកើតដោយបឋមជ្ឈានចិត្តនោះ បានឈ្មោះថាមគ្គប្រកប
ដោយអង្គ៥ប្រការ ព្រោះថាចេតសិកទាំង៣នេះ គឺ សម្មាវាចា សម្មា-
កម្មន្តោ សម្មាអាជីវោទាំង៣នេះមិនបានកើតដោយរូបាវចរចិត្តទេ ព្រោះ
កាលចូលឈាននោះគេកាយកម្មវចីកម្មនាន មានតែមនោទ្វារចិត្តតែ ១-
បញ្ញាដែលពិចារណាឲ្យឈាននោះឈ្មោះថាសម្មាទិដ្ឋិ វិតក្កដែលលើកចិត្ត
ឡើងកាន់អារម្មណ៍នោះឈ្មោះថាសម្មាសង្កប្បោ វិរិយចេតសិកដែលជាអ្នក
ជួយឧបត្ថម្ភឈានចិត្តនោះឈ្មោះថា សម្មាវាយាមោ សតិចេតសិកដែល
ដំរង់ឈានចិត្តឲ្យដំកល់នឹងនៅមិនឲ្យភ្លេចនោះឈ្មោះថា សម្មាសតិ ឯ-
កគ្គតាចេតសិក ដែលញ៉ាំងឈានចិត្តឲ្យដំកល់មាំ មិនបានឲ្យរំភើបនោះ
ឈ្មោះថា សម្មាសមាធិ ចេតសិកទាំង៥ នេះបានឈ្មោះថាអរិយមគ្គទាំង៥

កើតដោយរូបាវចរចិត្ត បណ្ឌិតគប្បីដឹងដោយប្រការដូច្នេះ មួយវិញទៀត កាលបើព្រះយោគាវចរតាំងចិត្តចំរើនសមថភាវនាបានអរូបាវចរឈាន ៤ ប្រការ គឺអាកាសានញ្ចាយតនឈាន វិញ្ញាណញ្ចាយតនឈាន អាកិញ្ច-ញ្ញាយតនឈាននិងនេវសញ្ញានាសញ្ញាយតនឈានទាំងនោះ ចេតសិក ៤ គឺ បញ្ញា១ វិរិយ១ សតិ១ ឯកគ្គតា១ ចេតសិកទាំងនេះកើតដោយអរូបាវចរឈានចិត្តទាំង ៤ នោះ បញ្ញាគឺពិចារណាដឹងច្បាស់អង្គឈានទាំងនោះ ឈ្មោះថាសម្មាទិដ្ឋិ វិរិយជួយគាំទ្រ ទំនុកបំរុងឈានចិត្តនោះ ឈ្មោះថាសម្មាវាយាមោ សតិដឹងរឭកឈានចិត្តនោះឈ្មោះថាសម្មាសតិ ឯកគ្គតាចេតសិកញុំាងឈានចិត្តឲ្យដំកល់មាំនៅមិនបានកំរើកញាប់ញ័រនោះឈ្មោះថាសម្មាសមាធិ គឺជាព្រះអដ្ឋង្គិកមគ្គ ៨ ដូច្នេះ ព្រោះថាអរូបាវចរឈានទាំងនោះ ជាបញ្ចម-ជ្ឈានរកតែឯកគ្គតា អង្គមគ្គទាំង ៤ កើតដោយអរូបាវចរចិត្ត បណ្ឌិតគប្បីដឹងដោយប្រការដូច្នេះចុះ ព្រះអដ្ឋង្គិកមគ្គទាំង ៨ នេះ កាលបើកើតក៏កើតព្រមគ្នាទាំង ៨ ដូចព្រះអញ្ញាកោណ្ឌញ្ញត្ថេរ បានស្ដាប់ព្រះធម៌ទេសនាធម្មចក្កប្បវត្តនសូត្រ បានលុះព្រះសោតាបត្តិផលនោះ ព្រះអដ្ឋង្គិកមគ្គទាំង៨នោះ កើតដោយសោតាបត្តិផលចិត្តព្រមគ្នាទាំង ៨ សម្មាទិដ្ឋិ គឺ បញ្ញានោះ ត្រាស់ដឹងព្រះអរិយសច្ចទាំង ៤ ជាក់ច្បាស់ដូច្នេះថា ឧបាទានក្ខន្ធទាំង ៥ នោះឈ្មោះទុក្ខអរិយសច្ច ព្រោះជាទីកើតនៃទុក្ខទាំងពួង តណ្ហាដែលប្រាថ្នាឲ្យកើតឧបាទានក្ខន្ធឈ្មោះសមុទយអរិយសច្ច គឺការដែលរលត់តណ្ហាដាច់ស្រឡះមិនបានកើតឡើងទៀត

ឈ្មោះទុក្ខនិរោធអរិយសច្ច ព្រះអដ្ឋង្គិកមគ្គទាំង ៨ នោះឈ្មោះទុក្ខនិរោធ-គាមិនីបដិបទាអរិយសច្ច សម្មាសង្កប្បោ គឺវិតក្កនោះគឺលះបង់នូវមិច្ឆាវិតក្កទាំង ៣ គឺកាមវិតក្ក ព្យាបាទវិតក្ក វិហឹសាវិតក្ក ឯវិតក្កទាំង ៣ នេះលះបង់ជាស្រេច សម្មាវាចានោះគឺលះបង់នូវមិច្ឆាវាចា ៤ ប្រការដូច្នេះ គឺមុសាវាទ ១ បេសុញ្ញវាចា ១ ផរុសវាចា ១ សម្ផប្បលាបវាចា ១ សម្មា-កម្មន្តោនោះគឺលះបង់នូវមិច្ឆាកម្មន្ត ៣ ប្រការ គឺ បាណាតិបាត ១ អទិន្នាទាន ១ កាមេសុមិច្ឆាចារ ១ សម្មាវាយាមោ គឺវីរិយនោះគឺលះបង់នូវមិច្ឆាវាយាមោ ៤ ប្រការ សម្មាសតិដ៏ប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំង ៤ ប្រការ គឺពិចារណារូបក្ខន្ធ គឺសរីរកាយថាជាអសុភ ពិចារណាឃើញថាវេទនា-ក្ខន្ធទាំង ៣ នោះ ថាជាទុក្ខ ពិចារណាឃើញវិញ្ញាណក្ខន្ធនោះថាជាអនិច្ចំមិនទៀង ពិចារណាឃើញសញ្ញាក្ខន្ធ សង្ខារក្ខន្ធនោះថាជាអនត្តាគេខ្ទំមកាគ្មាន សម្មាសមាធិនោះ ញុំាងអង្គព្រះអរិយមគ្គទាំង ៧ មានសម្មា-ទិដ្ឋិជាដើម ដ៏កើតដោយសម្មាសមាធិនោះឲ្យដល់នូវក្នុងអារម្មណ៍ គឺព្រះនិព្វានជាមាំ ព្រះអដ្ឋង្គិកមគ្គទាំង ៨ នេះកើតព្រមគ្នាតែមួយក្នុងសោតាបត្តិ-មគ្គចិត្ត ហើយធ្វើនូវកិច្ចផ្សេង ៗ គ្នាដូច្នេះ សម្មាសង្កប្បោនោះជាបច្ច័យដល់សម្មាទិដ្ឋិ មានឧបមាដូចដៃជាបច្ច័យដល់ចក្ខុវិញ្ញាណ កាលបើបុគ្គលឧនឹងរើសមើលប្រាក់មាសនោះ គេនឹងចាប់យកប្រាក់មាសដោយដៃក្រឡាស់ប្រែប្រួលមើល ចក្ខុក្រឡេកមើលក៏ស្គាល់ជាល្អ អាក្រក់ នេះមានឧបមាដូចម្តេច សម្មាសង្កប្បោនោះជាបច្ច័យដល់សម្មាទិដ្ឋិ ត្រិះរិះអារម្មណ៍រឿយ ៗ សម្មាទិដ្ឋិនោះក៏ពិចារណាដឹងនូវអារម្មណ៍នោះថា ធម៌ពួកនេះជាកាមាវចរ-

ធម៌ពួកនេះជាប្បាវៃ ហើយគឺនាំទៅកាន់អនិច្ចំទុក្ខំអនត្តា សម្មាសង្កប្ប
នោះជាភ្នាក់ងារតែខាងដំរិះនូវអារម្មណ៍ឲ្យផលសម្មាទិដ្ឋិ ដូចជាដៃចាប់យក
ប្រាក់មាសក្រឡាស់ទៅមកឲ្យផលចក្ខុនោះ ឯសម្មាវាចា សម្មាកម្មន្តនោះ
សោត គឺជាបច្ច័យផលសម្មាអាជីវ ព្រោះជាកាយកម្មវចីកម្មជាសុចរិត
ហើយ ចិញ្ចឹមជីវិតគឺជាសុចរិតដែរ ឯសម្មាវាយាមសម្មាសតិនោះសោត
គឺជាបច្ច័យផលសម្មាសមាធិ មានឧបមាដូចជាបុរស ៣ នាក់នាំសំឡាញ់
គ្នា ទាំងទៅលេងឯណា ៗ គឺបបួលគ្នាទៅជាមួយគ្នា ថ្ងៃមួយៈវារលេងឧ-
ទ្យានឃើញផ្កាចម្បាក៏ប្រាថ្នានឹងបេះ ដើមចម្បានោះខ្ពស់ណាស់ដៃមិនដល់
សំឡាញ់ជាគំរប់ ២ ក៏បង្អោនខ្នងទៅឲ្យបុរសនោះជាន់ សំឡាញ់ជាគំរប់ ៣
ក៏បន្ទន់កាយទៅឲ្យចាប់ បុរសនោះក៏ជាន់ខ្នងសំឡាញ់គំរប់ ២ ចាប់ស្មាសំ-
ឡាញ់ជាគំរប់ ៣ ទើបបេះយកផ្កាចម្បានោះបាន នេះមានឧបមាដូចម្តេច
សម្មាវាយាមនោះដូចជាបុរសដែលបង្អោនខ្នងទៅឲ្យជាន់ សម្មាសតិនោះ
ដូចជាបុរសដែលបន្ទន់កាយទៅឲ្យចាប់ សម្មាសមាធិនោះដូចជាបុរសដែល
ជាន់ខ្នងហើយបេះផ្កានោះបាន ក៏យាថាសម្មាវាយាមនឹងសម្មាសតិនោះ
ជាបច្ច័យផលសម្មាសមាធិ ដែលយកព្រះនិព្វានជាអារម្មណ៍ មាន
ឧបមេយ្យដូចជាបុរស ៣ នាក់ដែលជាសំឡាញ់គ្នានោះ ៗ មួយវិញទៀត
អដ្ឋង្គិកមគ្គទាំង ៨ នេះបើនឹងចាត់ជាខន្ធ សម្មាទិដ្ឋិនឹងសម្មាសង្កប្ប
ទាំង ២ នេះចាត់ជាបញ្ញាខន្ធ សម្មាវាចា សម្មាកម្មន្ត សម្មាអាជីវទាំង ៣
នេះចាត់ជាសីលខន្ធ សម្មាវាយាម សម្មាសតិ សម្មាសមាធិទាំង ៣ នេះក៏

ចាត់ជាសម្មាធិក្ខន្ធ  អធិប្បាយថាបុគ្គលឯណាជាអរិយសាវកគឺគប្បីកំចាត់
បង់នូវអវិជ្ជាគឺមោហ ដ៏មានលក្ខណៈឲ្យវង្វេងនោះដោយបញ្ញាក្ខន្ធ កំចាត់បង់
នូវរាគៈ គឺព្យាបាទ ដោយសីលក្ខន្ធ កំចាត់បង់នូវលោភនោះដោយសមា-
ធិក្ខន្ធ មួយវិញទៀតអដ្ឋង្គិកមគ្គទាំង៨នេះ បើនឹងចាត់ដោយវិជ្ជានឹងចរណៈនោះ
សម្មាទិដ្ឋិនឹងសម្មាសង្កប្បៈទាំង ២ នោះចាត់ឈ្មោះជាវិជ្ជា សម្មាវាចា សម្មា
កម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិទាំង ៦ នេះ
ចាត់ឈ្មោះជាចរណៈ វិជ្ជានោះដូចជាចក្ខុទាំង២ខាង ចរណៈនោះដូចជាជើង
ទាំង ២ ខាង អធិប្បាយថាបុគ្គលដើរផ្លូវនោះបើមានភ្នែកទាំងពីរបរិសុទ្ធល្អ
ក្រឡេកមើលទៅឃើញផ្លូវប្រកបដោយភ័យនឹងគ្មានភ័យ មានជើងទាំង២គឺ
បរិបូណ៌ទើបនឹងដើរទៅតាមផ្លូវប្រាសចាកភ័យបាន នេះមានឧបមាដូចម្តេច
បើបុគ្គលឯណាបានចំរើនព្រះអដ្ឋង្គិកមគ្គទាំង ៨ នេះហើយដំកល់នៅក្នុង
ជាអរិយសាវកនោះ  គឺនឹងក្រឡេកឃើញនូវហេតុផល  ថាប្រតិបត្តិផ្លូវខុស
នឹងជាហេតុនឹងឲ្យកើតទុក្ខឥតផលឥតប្រយោជន៍គ្មាន ប្រតិបត្តិផ្លូវខុសជាហេតុ
នឹងឲ្យកើតសុខ  ជាផលជាប្រយោជន៍  សំឡឹងឃើញផ្លូវខុសដោយប្រាជ្ញា
គឺសម្មាទិដ្ឋិ សម្មាសង្កប្បៈនោះ  ព្រះអរិយសាវកប្រតិបត្តិតាមចរណៈទាំង
៦ នោះ គឺ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មា-
សតិ សម្មាសមាធិផ្លូវខុស ជាផ្លូវប្រាសចាកភ័យអន្តរាយទាំងពួង គឺនឹងដល់
នូវនគរកែវគឺអមតមហាបុរីនោះជាដាច់ព្រាកដ ដូចជាបុគ្គលដើរផ្លូវមានចក្ខុ
ទាំង ២ ដ៏បរិបូណ៌ ជើងទាំង ២ មិនបានវិកលវិការ គឺនឹងដល់ទីប្រទេស

ដែលខ្លួនប្រាថ្នានោះឆាប់ដូចបំណង ហេតុដូច្នោះសម្ដេចព្រះអង្គ ទ្រង់ត្រាស់សរសើរព្រះអដ្ឋង្គិកមគ្គទាំង ៨ ប្រការ ដោយព្រះគាថាដូច្នេះថា ឧជុកោ នាមសោមគ្គោ ។ ល ។ និព្វានស្សបត្តិយា អធិប្បាយថា ព្រះអដ្ឋង្គិកមគ្គនេះជាផ្លូវត្រង់ទៅកាន់ទិស គឺព្រះនិព្វានដ៏ប្រាសចាកផ្លូវអន្លក់រណ្ដៅតូចធំ រថគឺព្រះអដ្ឋង្គិកមគ្គនេះមិនបានឮសំឡេងដូចរថយើងធម្មតា រថគឺព្រះអដ្ឋង្គិកមគ្គនេះស្ងប់ស្ងៀមល្អស្អាត ដែលអស់ទេវតាមនុស្សទាំងឡាយជិះព្រមគ្នាដែលមិនក៏អាចដឹកនាំទៅកាន់នគរគឺព្រះអមតមហានិព្វានបាន គឺមិនធ្វើឲ្យរបស់ឡើងដូចរថទាំងតូច រថគឺព្រះអដ្ឋង្គិកមគ្គប្រកបដោយកង់ គឺការយល់ឃើញត្រូវទៅកង់កាយនិងប្រព្រឹត្តត្រូវទៅកង់ចិត្តមានហិរិឱត្តប្បៈជាកន្ត្រាក់នឹងដឹកនាំទៀត រថគឺព្រះអដ្ឋង្គិកមគ្គនេះ មានលោកុត្តរមគ្គចិត្តជានាយសារថី មានរបស់ក្រាលសម្ភារៈជាបញ្ញាកុសល នឹងព្រះត្រៃលក្ខណ៍ គឺអនិច្ចំ ទុក្ខំ អនត្តា នោះជាបែកទាំងមុខ ព្រះអដ្ឋង្គិកមគ្គនេះស្ថិតនៅក្នុងសន្តានរបស់បុគ្គលឯណា បុគ្គលនោះក៏ស្ថិតនៅជិតព្រះនិព្វាន ហេតុឯណាហេតុដូច្នោះ អង្គសម្ដេចព្រះសព្វញ្ញូព្រះបរមគ្រូ ទ្រង់ត្រាស់ទេសនាដល់ភិក្ខុសង្ឃទាំងឡាយថា ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ ស្ទឹងបញ្ចមហានទីទាំង ៥ គឺគង្គា ១ យមុនា ១ អចិរវតី ១ សរភូ ១ មហី ១ ស្ទឹងធំទាំង ៥ នេះតែងហូរទៅកាន់មហាសមុទ្រ នេះគឺមានឧបមាដូចម្ដេច ភិក្ខុឯណាបានចំរើនព្រះអដ្ឋង្គិកមគ្គ ធ្វើព្រះអដ្ឋង្គិកមគ្គឲ្យកើតក្នុងសន្តាន ភិក្ខុនោះបានឈ្មោះថាឱនទៅកាន់ព្រះនិព្វាន ផ្អៀងទៅកាន់ព្រះនិព្វាន គឺ

មានឧបមេយ្យផ្លូវមហានទីទាំង ៤ ដែលហូរទៅកាន់មហាសមុទ្រនោះ ។ សម្តែងមកក្នុងព្រះអដ្ឋកថាមគ្គជាលោកិយនិងលោកុត្តរ តាមអដ្ឋកថាវិភង្គ និងគម្ពីរព្រះវិសុទ្ធិមគ្គតែប៉ុណ្ណោះ ។

អត្ថនៃមគ្គសច្ច ក៏មានប្រការដូចគ្នា គឺ និយ្យានដ្ឋោ មានអធិប្បាយថានាំខ្លួនចេញចាកភពប្រការ ១ ហេតុដ្ឋោ អធិប្បាយថាជាហេតុប្រការ ១ និងទស្សនដ្ឋោ អធិប្បាយថាសម្តែងចេញប្រការ ១ អធិបតេយ្យដ្ឋោ អធិប្បាយថាជាធំប្រការ ១ ត្រូវជា ៤ ប្រការ អត្ថជាបឋមគឺ និយ្យានដ្ឋោ នោះជាលក្ខណៈនៃមគ្គសច្ចពិត ព្រោះអង្គប្រាជ្ញទាំងឡាយឃើញសេចក្តីថាបុគ្គលដែលជាសប្បុរស ប្រាថ្នានឹងឆ្លងមហាសមុទ្រគោលគឺវដ្ត- សង្សារនោះគោងអាស្រ័យនឹងមគ្គសច្ចនេះ យកមគ្គសច្ចជាសំពៅធម៌ ដ៏ធំលើសលប់មិនចេះប្រេះមិនចេះឃ្លាង មិនចេះពៀបមិនចេះបែកធ្លុះធ្លាយលិចលង់ក្នុងសមុទ្រសំសារហើយ នឹងរកសំពៅឯណាឲ្យមាំមួនដូចសំពៅគឺមគ្គសច្ចនេះមិនមានសោះ សំពៅដទៃមិនអាចនឹងឆ្លងលោកិយសមុទ្របាន ដែលនឹងឆ្លងលោកិយសមុទ្រនេះ មានតែសំពៅគឺមគ្គសច្ចតែមួយទើបអាចឆ្លងបាន លោកិយសមុទ្រនេះមានទឹកគោលគឺបរិទេវទុក្ខ និងទោមនស្សទុក្ខ ឧបាយាសទុក្ខ លក្ខណៈដែលខ្ញាញ់ខ្សឹកខ្សួលចង្អៀតចង្អល់ក្នុងចិត្ត សោកអាលោះអាល័យទាំងនោះ ចាត់ជាទឹកក្នុងលោកិយ- សមុទ្រ ។ ប្រកបដោយរលកដ៏ធំគគ្រឹក គោលគឺជាតិ និងជរា ព្យាធិ មរណៈ ដេរដាសដោយខ្មោចទឹកនិងក្រពើសាហាវ គោលគឺ លោភ ទោស

មោហ នឹងមច្ឆរិយធម៌ លោកិយសមុទ្រនេះជ្រាលជ្រៅតម្កើកោតក្រៃលែង សំពៅដទៃ ក្រៅអំពីសំពៅគឺមគ្គសច្ចហើយមិនអាចនឹងឆ្លងបាន សម្តេចព្រះអនាវរញ្ញាណ ទ្រង់ប្រាថ្នានឹងឲ្យឃើញសេចក្ដីដូច្នេះ ទើបសម្ដែងអគ្គតិ និយ្យានដ្ឋោ ជាអត្ថនៃមគ្គសច្ច ជាបឋមជាលក្ខណៈនៃមគ្គសច្ចពិត ឯអត្ថនៃមគ្គសច្ចជាគំរប់ ២ គឺ ហេតុដ្ឋោ នោះមានអធិប្បាយធ្ងុះហួសផលសមុទយសច្ច ដើម្បីនឹងឲ្យឃើញសេចក្ដីថា បុគ្គលដែលនឹងឆ្លងទៅឲ្យផុតចាកសមុទ្រពោលគឺវដ្ដសង្សារនេះមិនបាន ព្រោះមានសន្តានអាស្រ័យដោយមូលហេតុគឺ តណ្ហា ១ នោះ មានកំឡាំងក្លាហានណាស់ញាំញីសន្តានពិតសត្វនៅជានិច្ច គេបញ្ញាដែលនឹងពិចារណាទោសនៃតណ្ហានោះមិនបាន ថែមទាំងនឹងបាកាន ចូលជួយទំនុកបំរុងឲ្យកំឡាំងដល់តណ្ហា ម្ល៉ោះហើយតណ្ហាបានគ្នាជាកំឡាំងរឹតរឹតតែសង្កត់សង្កិនសត្វឲ្យលិចលង់ចុះ គេអគ្គិបញ្ញានឹងបំបាត់បំផ្លាញតណ្ហានោះមិនមាន លុះតែគេសំពៅគឺមគ្គសច្ចនេះទើបនឹងឆ្លងគេផុតអំពីលោកិយសមុទ្រផុតអំពីដៃតណ្ហាបាន បើមានអគ្គិបញ្ញាដ៏ជាសម្មាទិដ្ឋិគង់សន្តានពិចារណាឃើញថា តណ្ហានេះជាហេតុឲ្យកើតទុក្ខកើតភ័យ។ បង្វិលក្នុងទាំងគតិផ្សេង ៗ ឃើញទោសនៃតណ្ហានេះហើយ។ ស្វាហាប់ប្រតិបត្តិតាមផ្លូវគឺមគ្គសច្ច មូលហេតុគឺតណ្ហានឹងសង្កត់សង្កិនញាំញីមិនបាន សម្ដេចព្រះសយម្ភូញាណមានប្រាថ្នានឹងឲ្យឃើញសេចក្ដីច្បាស់ធ្ងុះហួសផលសមុទយសច្ចដូច្នេះ ទើបទ្រង់សម្ដែងអគ្គតិ ហេតុ-ដ្ឋោជាអត្ថគំរប់ ២ ឯអត្ថជាគំរប់ ៣ គឺទស្សនដ្ឋោនោះ មានអធិប្បាយធ្ងុះ

រហូតដល់និរោធសច្ច  ដើម្បីនឹងបង្កឲ្យឃើញសេចក្ដីច្បាស់ថាមគ្គសច្ចនេះជាឧបាយឲ្យឃើញជាក់ច្បាស់នូវនិរោធសច្ច  កាលបើប្រតិបត្តិតាមមគ្គសច្ចហើយក៏អាចនឹងកប់ប្រសប់ជួបប្រទះឃើញនិរោធសច្ច  គឺព្រះនិព្វានទៀងប្រាកដណាស់  ព្រះអង្គប្រាថ្នានឹងឲ្យឃើញសេចក្ដីក៏ដូច្នេះរហូតដល់និរោធ-សច្ចដូច្នេះ  ទើបសម្ដែងអត្ថគឺនិទស្សនត្ថោ  ជាអត្ថនៃមគ្គសច្ចជាគំរប់ ៣ ឯអត្ថគំរប់ ៤ គឺអធិបតេយ្យត្ថោ នោះ  មានអធិប្បាយក៏ដូច្នេះរហូតដល់ទុក្ខអរិយសច្ចប្រាថ្នានឹងឲ្យឃើញច្បាស់សេចក្ដីថាមគ្គសច្ចនេះជាធំក្នុងកិច្ចដែលនឹងរម្ងាប់ទុក្ខទាំងពួងគឺទុក្ខទាំងពួងដែលនឹងរលត់នឹងសូន្យនោះក៏អាស្រ័យនឹងប្រតិ-បត្តិតាមមគ្គសច្ច ។  នេះមានគួរនោះដូចជាឱសថនឹងមន្តវិសេសសម្រាប់នឹងរម្ងាប់ពិសទាំងពួង  បើពុំនោះសោតដូចជាទឹកភ្លៀងដែលធ្លាក់ចុះស្រួលល្អ  ញាំងពូជស្រូវសំណាបឲ្យមានផលបរិបូណ៌  មគ្គសច្ចនេះជាធំក្នុងកិច្ចដែលនឹងរំងាប់ទុក្ខមានជាតិទុក្ខជាដើមជាប្រធាន  សម្ដេចព្រះទ្រង់ញាណប្រាថ្នានឹងឲ្យឃើញសេចក្ដីក៏ដូច្នេះរហូតដល់ទុក្ខអរិយសច្ចដូច្នេះ  ទើបទ្រង់សម្ដែងអត្ថគឺ  អធិបតេយ្យត្ថោ  ជាអត្ថនៃមគ្គសច្ចជាគំរប់ ៤  សម្ដែងអត្ថនៃមគ្គសច្ចចប់តែប៉ុណ្ណោះ ។

ពីនេះនឹងបែរទៅសម្ដែងអានិសង្សព្រះអដ្ឋង្គិកមគ្គជាលោកិយតាមដែលមានក្នុងនិទានជាតកសុត្តន្តបរិយាយ  ឲ្យឃើញច្បាស់ក្នុងមគ្គមួយ ៗ  នោះអ្នកប្រាជ្ញគប្បីដឹងដូចជានឹងពោលទៅខាងមុខនេះចុះ  សម្មាទិដ្ឋិជាលោកិយនោះ  គឺប្រាជ្ញាដឹងជាក់ច្បាស់នូវគុណព្រះរតនត្រ័យ  ដូចជានិទានមានមក

ក្នុងព្រះធម្មបទថា ក្នុងក្រុងរាជគ្រឹះ មានកុមារពីរនាក់នៅក្នុងនគរនោះ គឺកុមារម្នាក់ជាកូនអ្នកសម្មាទិដ្ឋិ កុមារម្នាក់ជាកូនអ្នកមិច្ឆាទិដ្ឋិ កុមារទាំងពីរនាក់តែងលេងល្បែងជាមួយគ្នា មានកាលមួយថ្ងៃកុមារទាំងពីរនាក់ទៅលេងអង្គុញជាមួយគ្នា កុមារជាកូនអ្នកសម្មាទិដ្ឋិនោះ កាលបើនឹងបោះអង្គុញទៅនោះ រឭកដល់ពុទ្ធគុណថា ឥតិបិ សោ ភគវា ជាដើមដូច្នេះហើយពោលថា នមោ ពុទ្ធស្ស ហើយក៏បោះអង្គុញទៅ ឯកុមារជាកូនអ្នកមិច្ឆាទិដ្ឋិនោះ កាលបើបោះអង្គុញទៅក៏រឭកគុណពួកតិរ្ថិយហើយពោលថា នមោ អរិហន្តានំ ដូច្នេះហើយក៏បោះអង្គុញទៅ កុមារជាកូនអ្នកសម្មាទិដ្ឋិនោះក៏ឈ្នះជាប់តែរាល់គ្រា មានអធិប្បាយថា បុគ្គលជាសម្មាទិដ្ឋិនោះតែងឈ្នះអ្នកប្រកាន់មិច្ឆាទិដ្ឋិ ម្យ៉ាងទៀត អ្នកដែលស្ថិតនៅក្នុងសម្មាទិដ្ឋិនោះរមែងតែងផុតចាកអន្តរាយទាំងពួង ដូចមាននិទានថា ឯគ្រាពីរសំ មានកាលថ្ងៃមួយ បិតាកុមារជាសម្មាទិដ្ឋិនោះក៏នាំកុមារជាកូនដាក់លើរទេះបរចេញទៅព្រៃ រកកាប់ឧស កាប់បានឧសហើយក៏ផ្ទុកលើរទេះហើយបរត្រឡប់មកវិញ ដល់ព្រៃសំសានមួយជាខាងក្រៅព្រះនគរ ក៏ដាក់រទេះដោះគោលែងទៅឲ្យស៊ីស្មៅ គោនោះក៏រត់ចូលទៅក្នុងព្រះនគរ បុរសជាបិតាក៏ឲ្យកូននៅចាំរទេះ ខ្លួនក៏រត់ប្រដិតតាមគោចូលទៅក្នុងនគរ លុះចាប់គោបានហើយក៏ត្រឡប់ទៅវិញ ដល់ទ្វារព្រះនគរ ជួនវេលាក៏ព្រលប់ល្មមអ្នករក្សាទ្វារព្រះនគរក៏បិទទ្វារព្រះនគរ បុរសនោះនឹងចេញទៅមិនបានឈប់នៅក្នុងនគរអស់មួយរាត្រី កុមារនោះនៅម្នាក់ឯងមើលផ្លូវបិតាបាត់ក៏ដេក

លក់នៅលើរទេះនោះតែម្នាក់ឯង មានអមនុស្ស ២ នាក់ ម្នាក់ជាសម្មាទិដ្ឋិ ម្នាក់ជាមិច្ឆាទិដ្ឋិ ជាសំឡាញ់គ្នា អមនុស្សទាំង ២ នាក់នាំគ្នាដើរស្វែងរកអាហារក្នុងវេលាព្រឹកនោះ លុះឃើញកុមារដេកលក់នៅលើរទេះ អមនុស្សជាមិច្ឆាទិដ្ឋិ ក៏និយាយទៅនឹងអមនុស្សជាសម្មាទិដ្ឋិថា នែសំឡាញ់ យើងចាប់កុមារនេះបរិភោគជាអាហារចុះ អមនុស្សជាសម្មាទិដ្ឋិឃាត់ថាកុំធ្វើដូច្នេះមិនគួរទេ អមនុស្សជាមិច្ឆាទិដ្ឋិមិនស្ដាប់ សុះចូលទៅចាប់កើបជើងកុមារនោះភ្ញាក់ឡើងស្រែកថា នមោពុទ្ធស្សៗ ញាប់មាត់រេញ អមនុស្សនោះភ្ញាក់ភ្ញាក់ស្មារតីបូកជើងពីដៃ សុះរត់ថយចេញទៅឈរឆ្ងាយនិយាយថាអីដូច្នេះ អមនុស្សជាសម្មាទិដ្ឋិនិយាយថាអញឃាត់ថាកុំៗ មិនជឿអញមានះមុខរឹង បើដូច្នេះគួរធ្វើណាកម្មអែកឯង ស្បៀងក្នុងនេះមិនទាន់បរិភោគអាហារ ត្រូវអ្នកឯងទៅស្វែងរកអាហារមកឲ្យក្មេងនេះបរិភោគជាហើយ អមនុស្សជាសម្មាទិដ្ឋិក៏នៅចាំរក្សាកុមារនោះ អមនុស្សមិច្ឆាទិដ្ឋិក៏ចូលទៅក្នុងព្រះរាជវាំង យកគ្រឿងសុធាភោជនក្រយាស្ងោយដាក់ក្នុងភាជនមាសនាំយកមក អមនុស្សទាំង ២ ធ្វើខ្លួនដូចជាមាតាបិតានៃកុមារនោះ ហើយឲ្យកុមារនោះបរិភោគអាហារ ទើបចារឹកអក្សរដាក់ក្នុងភាជន ហើយអធិប្បាយដោយយក្ខានុភាពថាឲ្យតែព្រះមហាក្សត្រឃើញតែមួយព្រះអង្គ បុគ្គលដទៃកុំឲ្យឃើញឡើយ អធិដ្ឋានដូច្នេះហើយក៏ចៀសចេញទៅ លុះព្រឹកឡើងមហាជនក៏ផ្អើលនាំឡើងថា ចោរលួចព្រះសុវណ្ណភាជនយកទៅបាត់ ចាត់រាជបុរសឲ្យដើររកសព្វទីលំនៅ

មនុស្សក្នុងនគរ ចេញទៅខាងក្រៅព្រះនគរទៀត ក៏ឃើញព្រះសុវណ្ណ-ភាជនទៅលើទេះនៃកុមារនោះ ក៏នាំយកព្រះសុវណ្ណភាជនទាំងខ្លួនកុមារនោះចូលទៅថ្វាយដល់ព្រះបរមក្សត្រ ស្តេចទតទៅឃើញអក្សរក៏ជ្រាបច្បាស់ ត្រាស់សួរកុមារៗ ក៏ទូលថា មាតាបិតានាំយកមកបោះទៅឲ្យបរិ-ភោគ ព្រះមហាក្សត្រក៏នាំកុមារទាំងបិតាទៅកាន់សម្នាក់ព្រះដ៏មានបុណ្យហើយទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន អ្នកចំរើនតែពុទ្ធានុស្សតិមួយអាចរក្សាការពារសត្វឲ្យផុតចាកសេចក្តីអន្តរាយបានឬ ។ ចាំធម្មានុស្សតិអាចរក្សាសត្វឲ្យផុតចាកសេចក្តីអន្តរាយបានដែរ ឬ

សម្តេចព្រះមហាករុណា ទ្រង់មានព្រះពុទ្ធដីកាថា ម្នាលមហារាជបពិត្រព្រះរាជសម្ភារដ៏ប្រសើរ ចិត្តដែលបុគ្គលចំរើនដោយអនុស្សតិ ៦ ប្រការ ក៏អាចរក្សាបុគ្គលនោះ ឲ្យផុតចាកសេចក្តីអន្តរាយបានខ្លះ ហើយទ្រង់សំដែងនូវបទគាថា ដូច្នេះថា

សុប្បពុទ្ធំបពុជ្ឈន្តិ សទាគោតមសាវកា
យេសំទិវាចរត្តោច និច្ចំពុទ្ធគតាសតិ ។
សុប្បពុទ្ធំបពុជ្ឈន្តិ សទាគោតមសាវកា
យេសំទិវាចរត្តោច និច្ចំធម្មគតាសតិ ។

អធិប្បាយក្នុងបទគាថានេះថា សតិដ៏រឭកនូវព្រះតថាគតថា ឥតិបិ សោ ភគវា ដូច្នេះជាដើមក្តី សតិដ៏រឭកដល់ព្រះធម្មគុណថា ស្វាក្ខា-

តោ ភគវតា ធម្មោ ដូច្នេះជាដើមក្តី សតិដ៏ទៀតដល់ព្រះសង្ឃគុណថា សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ដូច្នេះជាដើមក្តី សតិទៀតដល់កាយថា កេសា លោមា ដូច្នេះជាដើមក្តី សតិដ៏ទៀតដល់ករុណាភាវនាថា សព្វេ សត្តា ទុក្ខា បមុច្ចន្តុ ដូច្នេះជាដើមក្តី សតិដ៏ទៀតដល់មេត្តាភាវនាថា សព្វេ សត្តា អវេរា ហោន្តុ ដូច្នេះជាដើមក្តី អនុស្សតិទាំង ៦ ប្រការនេះសូម្បីតែមួយ ៗ ឯណាក្តី ជាប់មាំនៅក្នុងសន្តាននៃបុគ្គលឯណាហើយថ្ងៃក្តី យប់ក្តី គ្រប់កាលទាំងពួងក្តី សូម្បី ១ ថ្ងៃតែ ៣ ដងមុំតែម្តងក្តី បុគ្គលនោះឈ្មោះថាជាសាវកនៃព្រះតថាគត មួយទៀតបុគ្គលទាំងឡាយដែលលក់ក្តី ភ្ញាក់ក្តី ក៏គួរឈ្មោះថាភ្ញាក់ដោយប្រពៃជានិច្ចកាល យ៉ាងនេះក៏គាប់ចិត្តរួចផុតអំពីអន្តរាយ ភ័យទាំងឡាយទាំងពួងនោះមិនខាននេះសម្តែងអត្ថថា បុគ្គលអ្នកប្រកបដោយបញ្ញា ស្គាល់គុណព្រះរតនត្រ័យ ហើយចម្រើនអនុស្សតិភាវនា ៦ ប្រការដូច្នេះ ឈ្មោះថាមិនធ្លាក់ទៅក្នុងសម្មាទិដ្ឋិជាលោកិយ មួយវិញទៀត បញ្ញាដែលលះបង់នូវមិច្ឆាទិដ្ឋិក៏ឈ្មោះថាសម្មាទិដ្ឋិដែរ ឯមិច្ឆាទិដ្ឋិនោះគឺប្រកាន់ខុសថាទានគាប់ ប្រកាន់ថាឲ្យទានគ្មានផល បូជាសក្ការគ្មានផល ប្រកាន់ថាផលនៃកម្មទាំងឡាយដែលបុគ្គលធ្វើល្អធ្វើអាក្រក់គ្មានផល ប្រកាន់ថាលោកនេះក៏គ្មាន បរលោកក៏គ្មាន ប្រតិបត្តិមាតាបិតាក៏គ្មានផលប្រយោជន៍ សមណព្រាហ្មណ៍ដែលរម្ងាប់បាបដោយប្រតិបត្តិល្អ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងបរលោកដោយបញ្ញា ហើយញុំាងអ្នកដទៃឲ្យដឹងផងនោះ ក៏ឥតផលឥតប្រយោជន៍

សោះទទេ ធម៌ឲ្យទានផលរបស់សមណព្រាហ្មណ៍ ទាំងនេះក៏គេជាប់គេប្រយោ-
ជន៍គ្មាន បុគ្គលទៅលក្ខ័ក្ត បុគ្គលមានប្រាជ្ញាក្រោកច្រានក្ដី រីតស្លាប់ហើយ
ក៏សូន្យទៅជារៀតម្ដង ធម៌បាននិងកើតទីណាទៀតក៏គ្មាន ម្ដាយក៏គ្មាន ឪពុក
ក៏គ្មាន បុគ្គលដែលប្រកាន់យ៉ាងនេះឈ្មោះថាមិច្ឆាទិដ្ឋិ ឯបុគ្គលដែលជឿ
ផលទានផលបូជាសក្ការ ផលប្រតិបត្តិមាតាបិតា និងសមណព្រាហ្មណ៍
ផលសីល ផលភាវនា ឈ្មោះថាតាំងនៅក្នុងសម្មាទិដ្ឋិ ដែលត្រូវនាំមកក្នុង
បានសម្មាទិដ្ឋិនៃបុណ្ណៈ ៕

ព្រះពោធិសត្វបំពេញនូវគុណធម៌ក្នុងបន្ទាប់ ២ គឺ សម្មាសង្កប្បៈជា
ធម៌ប្រៀបដូចជាបាលកចិត្តនៃសម្មាទិដ្ឋិ បុគ្គលដែលមាន ហើយយក
សម្ដែងឲ្យយល់ក្នុងចោទសម្មាសង្កប្បៈ ២ នេះ គឺសេចក្ដីត្រិះរិះល្អតាមប្រពៃ
ក្នុងអារម្មណ៍ទាំង ៣ ប្រការ គឺ នេក្ខម្មសង្កប្បៈ សេចក្ដីត្រិះរិះក្នុងអារម្មណ៍
ដែលនឹងចេញចាកកាមគុណនោះ១ អព្យាបាទសង្កប្បៈ សេចក្ដីត្រិះរិះក្នុង
អារម្មណ៍ដែលប្រាសចាកចំណងព្យាបាទអាឃាតក្នុងសត្វទាំងឡាយ ១ អវិហិំ-
សាសង្កប្បៈ សេចក្ដីត្រិះរិះក្នុងអារម្មណ៍ដែលប្រាសចាកបៀតបៀនសត្វ
ដទៃទាំងពួងនោះ១ វិតក្កក្នុងអារម្មណ៍ទាំង ៣ ប្រការនេះ ឈ្មោះថាសម្មា-
សង្កប្បៈ អ្នកប្រាជ្ញគប្បីដឹងក្នុងមហាជនកជាតកថា កាលព្រះបរមពោធិ-
សត្វជាម្ចាស់នៃយើង កើតជាស្ដេចទ្រង់ព្រះនាមមហាជនក សោយរាជ
សម្បត្តិជាមហាក្សត្រក្នុងនគរមហាមិថិលា មានព្រះជន្មាយុបានមួយម៉ឺនឆ្នាំ

ទ្រង់បំពេញទានបារមី សីលបារមីនៅក្នុងរាជសម្បត្តិនោះអស់មួយពាន់ឆ្នាំ ហើយមានព្រះរាជហឫទ័យនឿយណាយ ប្រាថ្នានឹងចង់លះបង់រាជសម្បត្តិ ចេញទ្រង់បព្វជ្ជាបំពេញនេក្ខមបារមី ទើបព្រះអង្គប្រារព្ធរាជសម្បត្តិនឹងមាន ក្នុងនគរមិថិលា ទ្រង់ព្រះបរិវិតក្កថាកាលណា អាត្មានឹងលះបង់នូវមិថិលា មហានគរដ៏រុងរឿងដោយប្រាសាទរាជស្ថានពិមានកែវនឹងចតុរង្គអង្គសេនា ប្រដាប់ដោយទាំងពួងនេះបាន តែទ្រង់ព្រះដំរិះដូច្នេះអស់កាលជាយូរដល់ ៤ ខែ យ៉ាងនេះឈ្មោះថានេក្ខមសង្កប្បោ កាលព្រះអង្គចេញទៅទ្រង់ផ្នួសស្ដេច ទៅគង់នៅក្នុងព្រៃតាំងចំរើនកសិណបរិកម្មការនា បានបញ្ចាភិញ្ញាសមាបត្តិ កាលណា អព្យាបាទសង្កប្បោនឹងអវិហឹសាសង្កប្បោក៏បរិបូណ៌ក្នុងកាល នោះ សម្មាសង្កប្បោក៏មានដល់ព្រះមហាជនកដូច្នេះ មួយទៀតវិតក្កចេត-សិកនេះមាននៅក្នុងពួកបកិណ្ណកចេតសិក វិតក្កដែលកើតដោយអកុសល-ចិត្តក្តី វិតក្កដែលកើតដោយកុសលចិត្តក្តី វិតក្កដែលកើតដោយអកុសល ចិត្តនោះ គឺត្រិះរិះក្នុងអារម្មណ៍ជាអកុសល ចង់ធ្វើនូវកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិតទាំង ៣ នេះឈ្មោះថា មិច្ឆាសង្កប្បោ វិតក្កដែលកើតដោយ កុសលចិត្ត ត្រិះរិះក្នុងអារម្មណ៍ជាកុសល នឹងបំពេញកាយសុចរិតវចីសុចរិត មនោសុចរិតទាំង៣នេះឈ្មោះថាសម្មាសង្កប្បោ ដូចព្រះបាទធម្មាសោក-រាជសោយរាជសម្បត្តិក្នុងនគរបាតលីបុត្រនោះ មានព្រះអាជ្ញាផ្សាយទៅ ឮដល់អាកាស ១ យោជន៍ ផ្សាយទៅក្នុងផែនដី ១ យោជន៍ដូចគ្នា ទេវតាទាំងឡាយតែងនាំយកផលាផលនឹងគ្រឿងបរិភោគទាំងពួងមកអំពីហិមវន្ត ។

ប្រទេសថ្វាយជានិច្ច ទេវតាអង្គ១រះគឹងធីទឹកអំពីស្រះអនោតត្តមកថ្វាយ
ក្នុង១ថ្ងៃ៧អង្រែក មានសត្វបក្សីសេកនាំយកក្រស្រូវសាលីអំពីព្រៃទន្ធ
មកដាក់ឃ្លាំងថ្វាយក្នុង ១ ថ្ងៃ ៩ ពាន់រទេះ ស្តេចមានបុណ្យជាអស្ចារ្យ
ដូច្នេះ តាំងដើមអំពីកាលនោះមកព្រះបាទធម្មាសោករាជក៏ទ្រង់ព្រះរាជដំរិះ
ក្នុងកិច្ចដែលនឹងបំពេញទាន ទើបអារាធនាព្រះសង្ឃចូលទៅទទួលចង្ហាន់
ក្នុងព្រះរាជវាំង ៦ ម៉ឺនអង្គ សព្វ ៗ ថ្ងៃជានិច្ច ហើយទ្រង់ព្រះរាជដំរិះ
នឹងចង់ឃើញព្រះរូបអង្គព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដើម្បីនឹងបូជា ទើបស្តេច
ឲ្យយកខ្លួនស្តេចកាលនាគរាជឡើងមក ហើយក៏ឲ្យនិម្មិតកាយា ឲ្យដូចអង្គ
ព្រះសម្មាសម្ពុទ្ធ ហើយទ្រង់ធ្វើសក្ការបូជាអស់ ៧ ថ្ងៃ ទ្រង់ព្រះរាជដំរិះចង់ផ្សាយ
ព្រះសទ្ធម្មដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទេសនាចំនួន ៨ ម៉ឺន ៤ ពាន់ព្រះ
ធម្មខន្ធ ឲ្យសាងព្រះចេតិយ ៨ ម៉ឺន ៤ ពាន់ បញ្ចុះព្រះសារីរិកធាតុ សាង
ព្រះវិហារ ៨ ម៉ឺន ៤ ពាន់ក្នុងនគរដែល ១ ៗ ផង លុះសាងព្រះចេតិយនិងព្រះ
វិហារក្នុងអសោការាមស្រេចហើយ ទ្រង់ព្រះដំរិះតែងការធ្វើព្រះចេតិយ
និងព្រះវិហារចំនួន ៨ ម៉ឺន ៤ ពាន់ព្រមគ្នាតែមួយក្នុងវិហារមួយ ហើយទ្រង់
ព្រះរាជដំរិះចង់ជួបព្រះអង្គជាញាតិក្នុងព្រះពុទ្ធសាសនា ឈ្មោះថា ធម្មទាយាទ
ទើបបំបួសព្រះមហិន្ទកុមារជាព្រះរាជឱរស និងនាងសង្ឃមិត្តារាជធីតា
ឲ្យជាភិក្ខុនិងភិក្ខុនី ទ្រង់ឧបត្ថម្ភទំនុកបំរុងព្រះពុទ្ធសាសនា ឲ្យព្រះសង្ឃ
ធ្វើតតិយសង្គាយនាព្រះត្រៃបិដក ហើយទ្រង់ព្រះរាជដំរិះនឹងថ្វាយព្រះអង្គ
ជាទាសបាសកក្នុងព្រះពុទ្ធសាសនា៖ ព្រះអង្គក៏ទ្រង់ស្រាហ៍ផែនដីនៅក្នុង

ព្រះត្រៃសរណគមន៍ តែងព្រះរាជសាសន៍ទៅដល់ព្រះបាទទេវានំបិយ-តិស្សក្នុងលង្កាទ្វីប ឱ្យដំកល់នៅក្នុងព្រះត្រៃសរណគមន៍ ហើយឱ្យព្រះមហិន្ទថេរៈ នាំយកព្រះពុទ្ធសាសនាទៅប្រតិស្ឋានក្នុងលង្កាទ្វីប ឱ្យនិមន្តដើមមហាពោធិទៅដាំក្នុងលង្កាទ្វីប ឱ្យនិមន្តព្រះសារីរិកធាតុទៅបញ្ចុះក្នុងលង្កាទ្វីប នោះទ្រង់ព្រះរាជការកុសលជាច្រើនប្រការណាស់ គឺសុទ្ធកើតអំពីកាមាវចរកុសលចិត្ត ឈ្មោះថាសម្មាសង្កប្បទាំងអស់នោះ ដែលជាលោកិយមគ្គកើតមានដល់ព្រះបាទធម្មាសោករាជនេះ អ្នកប្រាជ្ញគប្បីពិចារណាមើលតាមដែលពណ៌នាមកនេះចុះ ។

ពីនេះទឹងពណ៌នាក្នុងបទសម្មាកម្មន្តទៅ សម្មាកម្មន្តដែលកើតដោយកាមាវចរកុសលចិត្តជាលោកិយក៏មាន ដូចជានាងសុជាតាដែលជាប្អូននៃនាងវិសាខាមហាឧបាសិកា នាងសុជាតានោះជាសុណិសានៃអនាថបិណ្ឌិកមហា-សេដ្ឋី នាងសុជាតានោះប្រកបដោយមានះ ថាខ្លួនជាធីតាមហាត្រកូលមានសម្បត្តិច្រើនមិនស្តាប់គោរពក្រែងអ្នកក្នុងត្រកូលស្វាមី រមែងពោលពាក្យរឹងរូសប្រមាថបង្អាប់ស្រកចាប្រកបដោយទុច្ចរិត ក្រៅធម៌ក្រៅគន្លង ជនទាំងពួងក្នុងផ្ទះក៏កើតទៅជាវិវាទ ឈ្លោះទាស់ទែងគ្នាទឹងនាងសុ-ជាតាជាកោលាហលរាល់ថ្ងៃ ឯកំ ទិវសំ គឺវេលាថ្ងៃមួយ អនាថ-បិណ្ឌិកសេដ្ឋី និមន្តព្រះសម្ពុទ្ធព្រមទាំងព្រះភិក្ខុសង្ឃទៅធ្វើភត្តកិច្ចឆាន់ក្នុងផ្ទះនោះ ព្រះបរមលោកនាថសាស្តាចារ្យ ទ្រង់ឮសូរសន្ធឹកគឹកកងជម្លោះដូច្នោះ គឺមានព្រះពុទ្ធដីកាសួរអនាថបិណ្ឌិកសេដ្ឋីថា ហេតុអ្វីជនទាំង-

ឡាយពោលពាក្យទុច្ចរិតគឹកកងរំពងដូច្នេះ អនាថបិណ្ឌិកសេដ្ឋីក្រាបទូលថា ករុណា បពិត្រព្រះអង្គដ៏ចំរើន នាងសុជាតាជាសុណិសារបស់ខ្ញុំព្រះករុណានេះ នាងនោះមានមានះរឹងរូសក្រៃពេកណាស់ ព្រោះអាងថាខ្លួនជាធិតាមហាត្រកូលមានសម្បត្តិច្រើន ពោលពាក្យជាផរុសវាចាមិនមានញញើតកោតក្រែងអ្នកឯណាឡើយ បានជាឮសូរសន្ធឹកគឹកកងដូច្នេះ ព្រះអង្គបានទ្រង់ព្រះសណ្ដាប់ដូច្នោះ ក៏មានព្រះពុទ្ធដីកាឲ្យហៅកេនាងសុជាតាមកហើយត្រាស់សួរថា ម្នាលនាងសុជាតា ចូរនាងស្ដាប់ធម៌ តថាគតនឹងសម្ដែងប្រាប់ថា ភរិយាក្នុងលោកនេះមាន ៧ ពួក គឺវធកាសមាភរិយា ១ ចោរីសមាភរិយា ១ អយ្យាសមាភរិយា ១ មាតាសមាភរិយា ១ ភគិនីស-មាភរិយា ១ សហាយាសមាភរិយា ១ ទាសីសមាភរិយា ១ ត្រូវជា ៧ ពួក នាងគឺជាភរិយាដូចម្ដេច នាងសុជាតាទូលថា ករុណា បពិត្រព្រះអង្គដ៏ចំរើន ដែលព្រះអង្គទ្រង់មានព្រះពុទ្ធដីកាថា ភរិយាមាន ៧ ពួកនោះ សូមឲ្យព្រះអង្គទ្រង់សម្ដែងដោយពិស្ដារ ជាសណ្ដាប់ក្នុងកាលឥឡូវនេះ ។

ព្រះអង្គទ្រង់មានព្រះពុទ្ធភាសិតថា ហៃនាងសុជាតា ភរិយាណាមានចិត្តប្រទុស្តនឹងស្វាមីអាត្មាឥតមានសេចក្ដីករុណាក្នុងស្វាមី តែងធ្វើខ្លួនអំពើឥតប្រយោជន៍ដល់ស្វាមី មានតែត្រេកត្រអាលដោយបុរសដទៃមើលងាយស្វាមីអាត្មា ខ្វល់ខ្វាយរកវេលាគិតតែឲ្យស្វាមីស្លាប់ ភរិយាមានសភាពយ៉ាងនេះឈ្មោះថា វធកាសមាភរិយា ។

ប្រការ ១ ទៀត ភរិយាឯណា ប្រកបដោយលោភចេតនា ប្រាថ្នានឹង បែចិត្តចេញក្រៅចិត្តស្វាមី បានទ្រព្យអ្វីៗ លបលាក់មិនឲ្យស្វាមីដឹង ពុំ ទោះបើស្វាមីរកទ្រព្យបានមកដោយកសិកម្មពាណិជ្ជកម្ម ដោយសិប្បកម្ម ក្តី គឺលបលួចលាក់មិនឲ្យស្វាមីដឹង ទុកជាប្រយោជន៍អាត្មា ភរិយាមាន សភាពដូច្នេះឈ្មោះថា ចោរីសមាភរិយា ។

មួយទៀតភរិយាអ្នកឯណា ប្រកបដោយសេចក្តីខ្ជិលច្រអូសដេកច្រើន មិនធ្វើការងារអ្វីទាំងអស់ ចិត្តសាហាវពោលពាក្យអាក្រក់ដូចផ្គាត់ កំហែង ប្រើស្វាមីឲ្យធ្វើការ ចំណែកអាត្មាមិនឲ្យស្វាមីស្រួលចិត្តឡើយ ភរិយាមាន សភាពដូច្នេះឈ្មោះថា អយ្យាសមាភរិយា ។

មួយទៀតភរិយាអ្នកឯណា មានចិត្តប្រកបដោយករុណា ស្វាមីក្តី មានចិត្តស្មោះស្ម័គ្រស្វែងរកផលប្រយោជន៍ឲ្យស្វាមី ចេះរក្សាទ្រព្យបាលថែ ទាំរក្សាស្វាមីដូចជាមាតារក្សាបុត្រ ភរិយាមានសភាពដូច្នេះឈ្មោះថា មា-តាសមាភរិយា ។

មួយទៀតភរិយាអ្នកឯណា មានសេចក្តីខ្មាសបាបខ្លាចបាប ហើយ គោរពកោតក្រែងស្វាមី ដូចប្អូនស្រីគោរពកោតក្រែងបងប្រុស ភរិយាមាន សភាពដូច្នេះឈ្មោះថា ភគិនីសមាភរិយា ។

មួយទៀតភរិយាអ្នកឯណា មានចិត្តជាកុសលប្រកបដោយសីល សមាចារ មានចិត្តស្មោះត្រង់ស្ងួតត្រង់មានវត្តប្រតិបត្តិស្វាមី មានចិត្តកក់តាក់

ស្ត្រីនោះស្រឡាញ់ស្វាមី មិនដែលពោលពាក្យទ្រគោះបោកបោះសំឡឹងមើលងាយស្វាមីឲ្យគាត់អន់អៀន ភរិយាមានសភាពដូច្នេះឈ្មោះថា សហាយាសមាភរិយា ។

មួយទៀតភរិយាអ្នកឯណា បើស្វាមីស្រដីជេរថា ឬគំរាមវាយដំមិនមានចិត្តតបប្រទូស្តវិញ មានចិត្តអំណត់អត់សង្កត់កំហឹងមិនបានចងគំនុំខឹងស្វាមី ប្រព្រឹត្តប្រតិបត្តិតាមអំណាចស្វាមី ដូចទាសីខ្ញុំម្ចាស់ ភរិយាមានសភាពដូច្នេះឈ្មោះថា ទាសីសមាភរិយា ។

ម្នាលនាងសុជាតា ភរិយាទាំង ៧ ចំពូកនេះតែងនឹងមានទៅក្នុងលោក ភរិយា ៣ ពួកខាងដើម គឺវធកាសមាភរិយា ចោរីសមាភរិយា អយ្យាសមាភរិយា ទាំង ៣ នេះ លុះចុតិរំលាយខន្ធទៅក៏ទៀងតែងនឹងទៅសោយទុក្ខក្នុងអបាយភូមិដោយផលនៃកម្មដែលខ្លួនធ្វើមិនគាប់នោះ ភរិយា ៤ ចំពួកខាងក្រោយ គឺមាតាសមាភរិយា ភគិនីសមាភរិយា សហាយាសមាភរិយា ទាសីសមាភរិយា ទាំង ៤ នេះ លុះចុតិរំលាយអត្តភាពអំពីជាតិនេះហើយ ទៀងតែងនឹងបានទៅសោយសម្បត្តិក្នុងសុគតិភពគឺមនុស្សសុគតិនិងទេវសុគតិប្រាសលែងទុក្ខផងទាំងពួង ដោយបុញ្ញកម្មដែលខ្លួនបានប្រតិបត្តិស្វាមីគួរតាមធម៌តាមគន្លងសុចរិត ។

កាលបើនាងសុជាតា បានស្តាប់ធម៌ទេសនាដូច្នេះហើយ ក៏ក្រាបនមស្សការព្រះបាទយុគល នៃសម្តេចព្រះត្រៃលោកនាថសាស្តាចារ្យ នាងក៏ទូលថ្វាយថា ករុណា បពិត្រព្រះអង្គដ៏ចំរើន ចាប់ដើមអំពីថ្ងៃនេះជាដើមទៅ ខ្ញុំសូមទទួលស្បថចំពោះព្រះពុទ្ធគុណ ធម្មគុណ សង្ឃគុណ ជាទីពឹងជាទីគា-

ស្រ័យផងអស់ជីវិតជាកំណត់ សូមឲ្យព្រះអង្គទ្រង់ចាំទុកខ្ញុំថាជាឧបាសិ-
កាក្នុងព្រះបវរពុទ្ធសាសនានេះ នាងសុជាតាថ្វាយខ្លួនជាឧបាសិកា ដំកល់
ទៅក្នុងព្រះត្រៃសរណគមន៍ហើយ គឺលះបង់នូវមិច្ឆាចារនោះចេញ មិនបាន
ពោលមិច្ឆាវាចា វៀរមិច្ឆាវាចា ដោយការមានចេតនាកុសលចិត្ត ដូច្នេះឈ្មោះថា
ដំកល់ទៅក្នុងសម្មាវាចាដ៏ជាលោកិយមគ្គ ព្រះអរិយសាវកទាំងឡាយ មាន
ព្រះសោតាបន្នជាដើម លោកវៀរចាកមិច្ឆាវាចាវិរតិចេតសិកកើតដោយ
សោតាបត្តិមគ្គចិត្តនោះ ឈ្មោះលោកុត្តរសម្មាវាចាជាសមុច្ឆេទវិរតិ កាត់នូវ
មិច្ឆាវាចាដាច់ចេញស្រឡះមិនបានកើតមានតទៅទៀត ដូចព្រះអរិយ-
សាវកទាំងឡាយក្នុងនគរសាវត្ថី កាលបើដល់កាលកំណត់នក្ខត្តឫក្សបុគ្គល
ពាលទាំងឡាយ គឺនាំគ្នាលេងមហោស្រពគំរប់ ៧ ថ្ងៃ មនុស្សពាលទាំង
ឡាយសឹងផឹកសុរាជាក្រុមជាគណ ដើរពោលអសប្បុរសវាចា ជាវាចាឥត
ប្រយោជន៍គ្រប់ភាសាផ្ទះអ្នកនគរ កាលបើអ្នកផ្ទះបានឲ្យទ្រព្យចំនួន ១
កហាបណៈ ទើបបានដើរចេញទៅ បណ្តាផងជាអរិយសាវកសឹងមិនចូលរួម
ផ្ទះឲ្យទ្រព្យបន្តិចបន្តួចទៅមនុស្សពាលនោះហើយ គឺបញ្ជូនឲ្យទៅវិញ ៗ
ទៅ សម្ងំនៅក្នុងផ្ទះចាំរក្សាពុទ្ធានុស្សតិ ធម្មានុស្សតិ សង្ឃានុស្សតិ អស់
ថ្ងៃគំរប់ ៧ លុះរួចស្រេចគឺនាំគ្នាទៅកាន់ព្រះវិហារនមស្ការព្រះពុទ្ធអង្គ
ហើយទូលថា មនុស្សពាលទាំងឡាយលេងមហោស្រពសឹងដើរពោលនូវ
អសប្បុរសវាចា មានប្រការផ្សេងៗ អស់ ៧ ថ្ងៃ យើងខ្ញុំទាំងឡាយគឺសម្ងំ
នៅតែក្នុងផ្ទះ ទើបមិនបានមកកាន់សំណាក់ព្រះអង្គអស់ ៧ ថ្ងៃ ទើបសម្តេច
ព្រះមហាករុណាទ្រង់ត្រាស់ទេសនាជាបទព្រះគាថាដូច្នេះថា

បមាទមនុយុញ្ជន្តិ   ពាលាទុម្មេធិនោជនា

អប្បមាទញ្ច   មេធាវី   ធនំសេដ្ឋំវ   រក្ខតិ

អធិប្បាយថា   ជនទាំងឡាយជាមនុស្សពាលមិនបានស្គាល់ប្រយោជន៍ក្នុងឥធលោកនិងបរលោក តែបញ្ញាមិនមាននោះ រមែងប្រកបខ្លួនសេចក្តីប្រមាទជានិច្ច ជនទាំងឡាយជាអ្នកមានបញ្ញា ស្គាល់ប្រយោជន៍ក្នុងឥធលោកនិងបរលោក   រមែងរក្សានូវអប្បមាទធម៌គឺមិនប្រមាទឲ្យខ្ជាប់នៅក្នុងសន្តាន មិនឲ្យវិនាសខូច ឧបមាដូចបុរសរក្សាទ្រព្យដ៏ប្រសើរគឺកែវ៧ប្រការ ដែលបានត ៗ មកអំពីវង្សត្រកូល   ដូច្នេះបានឈ្មោះថាព្រះអរិយសាវក រក្សានូវសម្មាវាចាដ៏ជាលោកុត្តរ   វិសេសនាមកក្នុងសម្មាវាចាតែប៉ុណ្ណោះ ។

ក្នុងបទសម្មាកម្មន្តនោះ   គឺវិរតិចេតសិកដ៏វៀរចាក បាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ វិរតិ ៣ ប្រការ គឺសម្បត្តវិរតិ ១ សមាទានវិរតិ ១ សមុច្ឆេទវិរតិ ១ សម្បត្តវិរតិនោះ ដូចជាចក្កនឧបាសក បងប្រុសប្រើឲ្យទៅរកសាច់ទន្សាយស្រស់យកមកឲ្យពេទ្យគេធ្វើថ្នាំឲ្យមាតា ដែលអាពាធ ចក្កនឧបាសកក៏ចាប់បានទន្សាយរស់មួយ ឮទន្សាយនោះស្រែកក៏គិតសង្វេគថា ឱ មិនគួរសោះ នឹងមកសម្លាប់ជីវិតសត្វដទៃ ព្រោះតែជីវិតនៃមាតាអាត្មាអញនេះ លុះគិតដូច្នោះហើយក៏ដោះទន្សាយនោះលែងទៅ យ៉ាងនេះឈ្មោះថាសម្បត្តវិរតិ ចាត់ជាសម្មាកម្មន្តប្រការ ១ ៗ

មួយវិញទៀតមានបុរសម្នាក់សមាទានសីលក្នុងសម្នាក់ព្រះមហាថេរ ១ អង្គ ហើយក៏ទៅភ្ជួរស្រែ ដល់វេលាលែងគោទៅឲ្យស៊ីស្មៅ គោនោះក៏ដើរចូលទៅបាត់ក្នុងព្រៃ បុរសនោះកាន់កំបិតព្រាដើរទៅរកគោក្នុងព្រៃឡើង

ទៅលើភ្នំឈ្មោះ ចន្ទវេណមានបពិត មានពស់ចាន់មួយធំមកក្នុងទីនោះ ឃើញបុរសនោះក៏ស្ទុះមកតម្រង់ដើម្បីចឹកដើម្បីនឹងឡើងទៅ បុរសនោះក៏គិតថាអញនឹងកាប់ពស់នេះដោយកំបិតព្រា ហើយបែរត្រឡប់គិតថា អាត្មាបានទទួលសមាទានសីល នឹងមកសម្លាប់សត្វព្រោះតែជីវិតអាត្មាយ៉ាងនេះមិនគួរសោះគិតដូច្នោះហើយក៏បោះកំបិតព្រាចោលទៅឆ្ងាយដោយគំនិតថា ជីវិតអាត្មានៃអាត្មានោះបាត់ចុះ កុំឲ្យខាតសីលអាត្មាដែលបានរក្សាមកនេះ ពស់នោះក៏បំបាត់ពិសនៅឡើយ ក៏សាយចេញទៅវិញ បុរសនោះក៏បានរួចជីវិតយ៉ាងនេះឈ្មោះថាសមាទានវិរតិ វិរតិទាំង ២ នេះកើតដោយកាមាវចរកុសលចិត្ត បានឈ្មោះថាសម្មាកម្មន្តជាលោកិយមគ្គ ឯសមុច្ឆេទវិរតិនោះ ដូចជាបុរសម្នាក់ឈ្មោះអរិយជាអ្នកស្ទូចត្រីចិញ្ចឹមជីវិតសព្វថ្ងៃ មានថ្ងៃមួយសម្តេចព្រះសព្វញ្ញូបរមគ្រូទ្រង់ពុទ្ធដំណើរទៅត្រង់ទីដែលបុរសនោះស្ទូច មួយអន្លើដោយភិក្ខុសង្ឃជាច្រើនអង្គ បុរសនោះលុះឃើញព្រះអង្គពីចម្ងាយ ក៏កើតហិរិឱត្តប្បៈមានសេចក្តីខ្មាសក៏យកសន្ទូចលាក់ទុក ព្រះអង្គទ្រង់ដំណើរដល់ទីនោះក៏ឈប់បែរសួរទៅព្រះសង្ឃសាវកវិញថា អ្នកនេះឈ្មោះអ្វី ព្រះសារីបុត្តក៏ទូលថាខ្ញុំឈ្មោះសារីបុត្ត ព្រះអង្គក៏សួរព្រះសង្ឃជាលំដាប់រៀងទៅ ព្រះសង្ឃក៏ទូលជាលំដាប់ៗទៅតាមនាមរបស់ខ្លួនៗ អរិយបុរសក៏គិតថា ព្រះសាស្តាសួរនាមព្រះសង្ឃសាវកហើយមុខជានឹងសួរឈ្មោះអញជាដើម អង្គព្រះសព្វញ្ញូទ្រង់ជ្រាបចិត្តបុរស

នោះទ្រង់ក៏មានព្រះពុទ្ធដីកាសួរថា អ្នកនេះឈ្មោះថាអ្វី បុរសនោះក៏ក្រាបទូលថា ខ្ញុំព្រះករុណាឈ្មោះអរិយ ព្រះអង្គក៏ទ្រង់ត្រាស់ទេសនាជាបទព្រះគាថាដូច្នេះថា ។

ន តេន អរិយោ ហោតិ   យេន បាណានិ ហឹសតិ

អហឹសា សព្វបាណានំ   អរិយោតិ បវុច្ចតិ

អធិប្បាយថា បុគ្គលឯណាមួយបៀតបៀននូវជីវិតសត្វទាំងឡាយ ដោយហេតុឯណា បុគ្គលនោះនឹងបានឈ្មោះថាអរិយដោយហេតុបៀតបៀននូវជីវិតនៃសត្វទាំងឡាយនោះឥតអង្គីមានឡើយ ឯពាក្យដែលគប្បីគេហៅថាអរិយដោយហេតុដែលមិនបានបៀតបៀននូវសត្វទាំងឡាយ ឯអរិយបុរសបានស្តាប់ព្រះធម៌ទេសនាដូច្នោះហើយ ក៏បានសម្រេចសោតាបត្តិផល ជាអរិយបុគ្គលវៀរបង់នូវអំពើបាណាតិបាត ដោយអំណាចសម្មាកម្មន្តដែលកើតដោយសោតាបត្តិមគ្គចិត្តនោះ ។

ឯសម្មាកម្មន្តដែលវៀរចាកអទិន្នាទាននោះ ដូចជានាងខុជ្ជុត្តរា ជាស្រីបម្រើនៃនាងសាមាវតីមហេសីព្រះបាទឧទេនរាជ ស្តេចទ្រង់ប្រទានព្រះរាជទ្រព្យឲ្យនាងសាមាវតី ១ ថ្ងៃ ៨ កហាបណៈ ជាថ្លៃផ្កាកម្រងសព្វៗ ថ្ងៃជានិច្ច នាងសាមាវតីប្រើនាងខុជ្ជុត្តរាឲ្យបើកទៅទិញផ្កាជាងមាលាការតែសព្វថ្ងៃមិនដែលដាច់ នាងខុជ្ជុត្តរាទិញផ្កាតែ ៤ កហាបណៈ តែយកជាប្រយោជន៍ខ្លួន ៤ កហាបណៈតែរាល់ថ្ងៃ វេលាថ្ងៃមួយជាងមាលាការនិមន្តព្រះសាស្តាព្រមទាំងព្រះភិក្ខុសង្ឃ មកធ្វើភត្តកិច្ចនាំនៅផ្ទះខ្លួនហើយប្រាប់ដល់នាងខុជ្ជុត្តរាថា ថ្ងៃនេះចូរនាងនៅជួយយើងអង្គាសព្រះសង្ឃ

មានអង្គព្រះសាស្តាជាប្រធានស្តាប់ព្រះធម៌ទេសនាសិន រួចសឹមយកផ្កាទៅចុះ នាងខុជ្ជុត្តរាក៏ទៅជួយអង្គាសព្រះសង្ឃ លុះរួចក៏ស្តាប់ធម៌ទេសនានៃសម្តេចព្រះសាស្តា នាងក៏លុះសោតាបត្តិផលហើយទិញផ្កាអស់ទាំង ៨ កហាបណ នាំយកទៅថ្វាយនាងសាមាវតី នាងឃើញផ្កាច្រើនទ្វេមួយជាពីរ ក៏សួរថា ថ្ងៃនេះប្រហែលជាទ្រង់ព្រះរាជទានព្រះរាជទ្រព្យឲ្យច្រើនជាងសព្វថ្ងៃដូចម្តេច ។ នាងខុជ្ជុត្តរាទូលថាមិនដូច្នោះទេ ព្រះរាជទ្រព្យដែលទ្រង់ព្រះរាជទានសព្វ ១ ថ្ងៃ ៨ កហាបណ ។ តែកាលថ្ងៃមុន ៗ ខ្ញុំទិញតែ ៤ កហាបណយកមកថ្វាយ បានជាផ្កាតិច ថ្ងៃនេះខ្ញុំបានស្តាប់ព្រះធម៌ទេសនាព្រះពុទ្ធជាម្ចាស់ ត្រាស់សម្តែងទោសអទិន្នាទាន ថាមានទោសជាទម្ងន់ ហេតុនោះបានជាខ្ញុំខ្លាចមិនហ៊ានលួចយកដូចថ្ងៃមុន ៗ សូមឲ្យព្រះនាងអត់ទោសខ្ញុំនេះចុះ នាងខុជ្ជុត្តរានេះ កាលបើបានដល់ព្រះសោតាបត្តិផលហើយក៏មិនបានពោលមុសាវាទ បែរជាប្រាប់តាមសេចក្តីពិត យ៉ាងនេះក៏ជាអង្គនៃព្រះអរិយមគ្គ គឺសម្មាវាចាទីនឹងសម្មាសង្កប្បប្រាកដដល់នាងខុជ្ជុត្តរាដោយប្រការដូច្នេះ ។

មួយវិញទៀតសម្មាកម្មន្តដែលវៀរចាកកាមេសុមិច្ឆាចារនោះ បានដូចសេដ្ឋីបុត្តម្នាក់ឈ្មោះខេមក ជាក្មួយអនាថបិណ្ឌិកសេដ្ឋី ឯខេមកនោះកាលជាតិអំពីមុន បានធ្វើផង់ទង់មាសដ៏ល្អប្រពៃបូជាព្រះចេតិយបញ្ចុះព្រះសារីរិកធាតុព្រះពុទ្ធកស្សប ហើយតាំងសេចក្តីប្រាថ្នាថា សូមតេជះផលានិសង្សដែលខ្ញុំបានធ្វើបូជាផង់ទង់មាសនេះ បើសកើតទាំងពួងវៀរលែងតែញាតិសាលោហិត ចាំបើបានឃើញរូបកាយនេះកាលណាក៏

ឲ្យមានចិត្តចង់ប្រតិព័ទ្ធស្នេហាកុំឲ្យទប់ទល់ឃាត់បាន ហេតុដោយសម្ពន្ធ នោះ កាលបើបានមកបង្កើតជាខេមកសេដ្ឋីបុត្តនេះ ស្ត្រីភាពឯណាតែបាន ឃើញហើយក៏សឹងមានចិត្តចង់ប្រតិព័ទ្ធរត់តាមខេមកជាច្រើន ខេមកក៏ប្រ-ព្រឹត្តធ្វើនូវអំពើកាមមិច្ឆាចារដោយភរិយាអ្នកដទៃ ៗ រឿយ ៗ មានកាលថ្ងៃ មួយ ពួកបុរសចាប់ខ្លួនខេមកបាន នាំយកទៅថ្វាយព្រះបាទបសេនទិកោ-សលរាជ ស្ដេចទ្រង់ត្រាស់ថាខេមកជាកូនអនាថបិណ្ឌិកសេដ្ឋីជាមហាឧបា-សកក្នុងព្រះពុទ្ធសាសនា បើនឹងធ្វើទោសចុះទណ្ឌកម្ម អនាថបិណ្ឌិកសេដ្ឋី គឺនឹងដល់សេចក្ដីអៀនខ្មាសអម្បូរយសដល់ជនទាំងឡាយ ស្ដេចទ្រង់ព្រះ ចិន្ដាដូច្នោះក៏មិនបានធ្វើទោសដោះលែងទៅ ខេមកក៏មិនចេះរាងចាលប្រ-ព្រឹត្តធ្វើមិច្ឆាចារដូច្នោះទៀត ពួកបុរសចាប់បានយកទៅថ្វាយព្រះមហា-ក្សត្រ ៗ ស្ដេចក៏ដោះលែងតែយ៉ាងនេះដល់ទៅ ៣ ដង មកឯក្រោយអនា-ថបិណ្ឌិកសេដ្ឋីក៏នាំខ្លួនខេមកមកក្រាបទូលសម្ដេចព្រះមហាករុណា ព្រះ អង្គទ្រង់ទេសនាដាស់ព្រះគាថាដូច្នេះថា ចត្តារិ ឋានានិ នរោ បមត្តោ ជាដើម អធិប្បាយថា បុគ្គលឯណារកស្មោះនឹងពិចារណាកុសលាកុសល គ្មាន ហើយប្រព្រឹត្តសេពគប់នឹងភរិយានៃបុគ្គលដទៃ បុគ្គលនោះរមែងដល់ នូវហេតុជាទោសឲ្យកើតទុក្ខ ៤ ប្រការ គឺនឹងឲ្យសោយផលនៃអកុសលនោះ ជាច្រើនប្រការ ១ សេចក្ដីព្រួយបារិតក្ក សោយសល់ដេកមិនលក់មិនស្កប់ ដោយភ័យខ្លាចប្រការ ១ នឹងបាននូវពាក្យដំណេះដំណៀលឥតមានអ្នកឯ-ណានឹងសរសើរប្រការ ១ លុះចុតិអំពីអត្តភាពនេះក៏ទៀងតែនឹងទៅសោយ ទុក្ខនៅក្នុងនរកដល់ទុក្ខវេទនាជាទម្ងន់ពន់ប្រមាណប្រការ ១ នឹងដល់នូវ

ទុក្ខ ៤ ប្រការផុតចេះ ។ ខេមកសេដ្ឋីបុត្រលុះបានស្តាប់ព្រះធម៌ទេសនាក៏បានសម្រេចព្រះសោតាបត្តិផលជាអរិយបុគ្គលក្នុងខណៈនោះ មិនបានប្រព្រឹត្តនូវអំពើកាមេសុមិច្ឆាចារតទៅនេះ ក៏ជាអង្គនៃព្រះអរិយមគ្គ គឺសម្មាកម្មន្តដ៏កើតដោយសោតាបត្តិមគ្គចិត្ត ។

អង្គនៃព្រះអរិយមគ្គជាគំរប់ ៥ គឺសម្មាអាជីវៈនោះ គឺកិរិយាដែលវៀរចាកការលក់ដូរជួញប្រែ រកចិញ្ចឹមជីវិតក្រៅក្រឹត្យក្រៅគន្លងធម៌ គឺជួញប្រែដោយជំនួញ ៥ ប្រការ សត្តវណិជ្ជា គឺជួញសត្វមានជីវិតជួញមនុស្សជួញគោក្របីជាដើម ១ សត្ថវណិជ្ជា ជួញគ្រឿងសាស្ត្រាវុធមានដាវលំពែងជាដើម ក៏សម្រាប់និងប្រហារជីវិតសត្វទាំងពួងមានមនុស្សជាដើម ១ មំសវណិជ្ជា ចិញ្ចឹមសត្វមានមាន់ទាជាដើមហើយសម្លាប់ខ្លួនឯងក្តី ឲ្យអ្នកដទៃសម្លាប់ក្តី យកសាច់នោះលក់ចិញ្ចឹមជីវិតប្រការ ១ មជ្ជវណិជ្ជា ជួញទឹកស្រវឹង គឺ សុរាមេរយប្រការ ១ វិសវណិជ្ជា ប្រកបថ្នាំពិសសម្រាប់សម្លាប់ជីវិតសត្វមានមនុស្សជាដើម លក់ដូរចិញ្ចឹមជីវិតប្រការ ១ ជំនួញទាំង ៥ ប្រការនេះធ្វើតែប្រការឯណាមួយក៏ជាមិច្ឆាអាជីវ ឈ្មោះថាចិញ្ចឹមជីវិតខុសធម៌ ។ ប្រការមួយទៀតបើបុគ្គលឯណារកស៊ីលក់ដូរ បំបាត់ដោយកូនជញ្ជីងស្រាលឬដោយរង្វាល់តិច យ៉ាងនេះក៏ឈ្មោះថាមិច្ឆាអាជីវដែរ កិរិយាប្រព្រឹត្តចិញ្ចឹមជីវិតវៀរចាកមិច្ឆាអាជីវនេះឈ្មោះថាសម្មាអាជីវៈ ជាអង្គនៃព្រះអរិយមគ្គជាគំរប់ ៤ ។

អង្គនៃព្រះអរិយមគ្គជាគំរប់ ៦ គឺសម្មាវាយាមៈនោះ គឺធ្វើកិច្ច ៤ ប្រការ គឺព្យាយាមមិនឲ្យអកុសលធម៌កើតឡើងបានប្រការ ១ ព្យាយាមលះបង់នូវអកុសលធម៌ដែលកើតឡើងហើយ ឲ្យបាត់ទៅវិញប្រការ ១ ព្យាយាមញុំាងកុសលធម៌ដែលមិនទាន់កើតមានឲ្យកើតមានឡើងប្រការ ១ ព្យាយាមចំរើនកុសលធម៌ដែលកើតមានឡើងហើយ ឲ្យរឹតតែចំរើនឡើង មិនឲ្យវិនាសបាត់ទៅវិញប្រការ ១ ត្រូវជា ៤ ប្រការដូច្នេះ ។

ព្យាយាមមិនឲ្យអកុសលធម៌ដែលមិនទាន់កើត មិនឲ្យកើតឡើងបាននោះ ដូចកាលព្រះបរមពោធិសត្វកើតជាកេកមាសជាបក្សីធំមានភក្ត្រ ពាំង ២ ដ៏ក្រហមដូចត្រាច់អង្រ្គីមអង្រ្គីម ឯចំពុះមាត់ដូចតែប្រាក់ឡូ ទានរើត្រាក្រហមលើងដុំខ្លួន ល្អប្លែកជាងសត្វកេកទាំងក្នុងដីជាស្ដេចនៃកេក មានកាលថ្ងៃមួយព្រះពោធិសត្វនាំពួកកេកជាបរិវាររបស់ខ្លួនហើរទៅ ចុះផឹកទឹកនៅស្រះមួយ ក៏ប្រមើលមើលរូបកាយឃើញរូបល្អប្រពៃក្រៃក្រ ពេកថា បើអាត្មានឹងនៅជាមួយពួកកេកនេះវា ក្រែងភ័យនឹងមានដល់អាត្មា ។ នឹងគេចទៅនៅក្នុងព្រៃហិមពាន្តតែម្នាក់ឯង ឲ្យបានសុខ កាលបើដល់វេលាព្រឹកស្អែក ព្រះពោធិសត្វមិនឲ្យកេកដទៃដឹង ក៏លបហើរចេញឆ្ពោះទៅសំដៅព្រៃហិមពាន្ត រំលងព្រៃភ្នំ ៧ ប្រមាណ ៣ ជាន់ចូលទៅដល់ភ្នំជាគំរប់ ៤ ឃើញស្រះធំមួយដេរដាសដោយបទុម- ជាតិនិងសេតក្រលជាតិមាន ព្រៃក្បាលតាល្ងៃ ដោយរកេមផិតជុំជារម្មណីយស្ថាន មានដើមស្រែ ១ ធំត្រសុំសាខានៅលើភ្នំនោះ ព្រះពោធិសត្វក៏ទៅចុះទាប់ អាស្រ័យនៅដើមស្រែនោះ សត្វដទៃមិនអាចនឹងឡើងទៅទីនោះបាន ដុត

ចាកក៏យកអង្គកាយទាំងពួង តែព្រឹកឡើងព្រះអាទិត្យរះទៅវ័យរះឡើង ព្រះពោធិសត្វបែរមុខឆ្ពោះទៅបូព៌ទិសចងការស្ដាប់នមស្សការចំពោះព្រះបរិត្តថា ឧទេតយំ ចក្ខុមា ឯករាជា ហរិស្សវណ្ណោ ជាដើមដូច្នេះ ដើម្បីនឹងរក្សាអាត្មាក្នុងវេលាថ្ងៃហើយ ហើយទៅរកគោចរ លុះវេលាល្ងាចហើយត្រឡប់មកទីលំនៅវិញ ក៏ឡើងមើលទៅបរិមណ្ឌលព្រះចន្ទ ហើយក៏នមស្សការពោលនូវបទព្រះគាថាដូច្នេះថា អបេតយំ ចក្ខុមា ឯករាជា ហរិស្សវណ្ណោ ជាដើមដូច្នេះ ហើយក៏នៅក្នុងវេលារាត្រីនោះ ដែលថាព្រះពោធិសត្វប្រតិបត្តិព្យាយាមយ៉ាងនេះជានិច្ចគ្រប់ថ្ងៃ គឺញ៉ាំងអកុសលធម៌ទាំងពួងមិនឲ្យកើតឡើងបានក្នុងសន្តានអស់កាលដរាបអស់ជីវិត យ៉ាងនេះក៏បាត់ឈ្មោះថាសម្មាវាយាមោ ជាលោកិយមគ្គកើតដោយកាមាវចរកុសលចិត្ត ។

ឯព្យាយាមលះបង់នូវអកុសលដែលកើតឡើងហើយនោះ ឲ្យវិនាសបាត់ទៅវិញ ដូចមានក្នុងបញ្ចុបោសថជាតក ក្នុងបកិណ្ណកនិបាតថា សម័យមួយព្រះពោធិសត្វយកព្រះជាតិកើតក្នុងត្រកូលព្រាហ្មណ៍មានសម្បត្តិច្រើន ក៏លះបង់សម្បត្តិចេញទៅបួសជាតាបសឫសី អាស្រ័យនៅក្នុងព្រៃពង់ស្ពានទីត្បូងជាទីដរម្រែកចិត្ត ដ៏មាននៅក្នុងបន្ទោះនគរទាំង ៣ មាននគរគន្ធារជាដើម មានសត្វព្រាបមួយមានភរិយា អាស្រ័យនៅគុម្ពឫស្សី ជិតអាស្រមបទព្រះតាបសនោះ មានពស់វែកមួយនៅក្នុងរន្ធដម្បូក ជិតអាស្រមបទ មានសត្វចចកមួយអាស្រ័យនៅក្នុងស៊ុំទ្រមព្រៃ ជិតអាស្រមបទនោះដែរ មានខ្លាឃ្មុំមួយអាស្រ័យនៅក្នុងទីនោះផង

មានកាលមួយថ្ងៃសត្វព្រាបនាំគ្នាកេចណៃ ថ្ងៃនីមួយៗហើរមកឃើញគំនាប
យកមេព្រាបនោះយកទៅធ្វើជាចំណី ព្រាបឈ្មោលកាលណាឃើញទោស
ការយាកក្តុកតាលខ្លាំង ក៏ចូលទៅកាន់សំណាក់ព្រះតាបស សមាទាន
ឧបោសថសីលក្នុងសំណាក់ព្រះតាបស ដើម្បីសង្កត់សង្កិនរាគៈនោះ ។
ឯពស់វិញក៏ចេញទៅរកចំណី បានគោឈ្មោលមួយស.បុទ្ធជាគោមង្គល
របស់នាយគោបាល គោនោះដើរទៅរកអាហារជិតជម្រកដែលពស់នោះ
នៅ ក៏ដើរទៅជាន់កន្ទុយ ។ ក្រឡប់ចឹកគោឈ្មោលនោះស្លាប់មួយរំពេច
ទៅ នាយគោបាលដើររកគោទៅឃើញគោនោះស្លាប់ ក៏យំស្ដាយគោ
ឯពស់នោះ កាលបើចឹកគោស្លាប់ហើយក៏គិតថាអាត្មាលុះអំណាចទោស
ចឹកគោសម្លាប់ ផងនាំនឹងឲ្យកើតទុក្ខសោកព្រោះតែអាត្មា គួរតែនឹង
បំបាត់ទោសនោះចេញ គិតដូច្នេះហើយក៏លូនចូលទៅកាន់អាស្រមបទ
ក៏នឹងសមាទានឧបោសថសីលក្នុងសំណាក់ព្រះតាបស គិតថាទោសនេះ
មិនទាន់រម្ងាប់ដរាបណា អាត្មាក៏មិនទៅស្វែងរកអាហារដរាបនោះ បើទោស
នេះរម្ងាប់ហើយ ទើបអាត្មានឹងទៅស្វែងរកអាហារ ។ ចំណែកឯសត្វចចក
ចេញដើរទៅស្វែងរកអាហារឃើញដំរីមួយស្លាប់ ចចកក៏ខាំត្រង់ទ្វារធ្លារ
ដំរីនោះធ្លុះជាប្រហោង ចចកក៏មមុលចូលទៅក្នុងពោះដំរីនោះ ស៊ីហើយ
សម្ងំដេកនៅក្នុងពោះដំរី រំលងពីរបីថ្ងៃសាកសពដំរីនោះត្រូវខ្យល់ក៏ស្ងួត
ស្វិតក្រៀមចុះ ទ្វារធ្លារក៏ខ្ទប់ជាប់ ចចកនោះក៏នៅក្នុងពោះដំរីទៅទុក្ខវេ-
ទនាជាទម្ងន់ មានកាលថ្ងៃមួយមានភ្លៀងធំហាក់ធ្លាក់ចុះមក ឯទ្វារធ្លារ
ដំរីត្រូវទឹកភ្លៀងនឹងទឹកជោគក៏របើកប្រហោងបន្តិចឡើង ចចកក៏ប្រឹងរំមមុល

ចេញតាមប្រហោងនោះរួចចេញមកបាន ចចកក៏គិតថាអាត្មាបានទុក្ខតាំង
នេះព្រោះតែសេចក្ដីលោភ អាត្មាស្អិតស្អិនសេចក្ដីលោភនេះមិនទាន់
បានផលបណា អាត្មាក៏មិនទៅរកអាហារផលបនោះ ចចកក៏ទៅកាន់អា-
ស្រមបទហើយ សមាទាននូវឧបោសថសីល ក្នុងសំណាក់នៃព្រះតាបស
ហើយដេកនៅក្នុងទីដ៏សមគួរ ឯខ្លាឃ្មុំសោតក៏មានសេចក្ដីព្រួយឋាក្នុងអាហារ
គ្របសង្កត់ក្រៃលែង ចេញអំពីទីលំនៅទៅដើរស្វែងរកអាហារក្នុងព្រៃ
មនុស្សទាំងឡាយក្រឡេកឃើញ ក៏កាន់នូវស្នាឈើដំបងដេញខ្លាឃ្មុំនោះ
ទៅសំពងវែកក្បាលខ្លាឃ្មុំ ៗ ក៏រត់រួចទៅបានហើយគិតថាអាត្មាដល់នូវទុក្ខ
តាំងនេះមិនពីព្រោះអ្វី ក៏ព្រោះតែមោហនាំឲ្យស្រេកដោយអាហារ អាត្មា
អត់សង្កត់មោហមិនទាន់បានផលបណា - អាត្មាក៏មិនបានទៅស្វែងរកអា-
ហារផលបនោះ គិតហើយក៏ចូលទៅកាន់អាស្រមបទព្រះតាបស ហើយ
សមាទាននូវឧបោសថសីលក្នុងសំណាក់នៃព្រះតាបសនោះ ឯព្រះតាបស
វិញសោតក៏ប្រកាន់មានះថា អាត្មានេះជាព្រាហ្មណជាតិដ៏ប្រសើរជាងជន
ដទៃ គិតដូច្នោះហើយក៏មិនអាចនឹងញុំាងឈានសមាបត្តិឲ្យកើតឡើងបាន
ចម្នេរមកកាលជាខាងក្រោយ មានព្រះបច្ចេកពុទ្ធមួយអង្គ ជ្រាបថាព្រះ
តាបសនេះជាពន្ធកពុទ្ធដែលនឹងបានត្រាស់ជាព្រះពុទ្ធ គួរអាត្មាអញនឹង
ញុំាងព្រះតាបសនេះឲ្យលះបង់នូវមានះចេញក្នុងកាលឥឡូវនេះ ព្រះបច្ចេក
ពុទ្ធទ្រង់ពិចារណាដូច្នោះហើយ ក៏និមន្តមកគង់លើផែនសិលាដ៏ជាអាសន
អង្គុយនៃព្រះតាបស ៗ ចេញមកឃើញព្រះបច្ចេកពុទ្ធ ក៏មិនបានថ្វាយ
បង្គំនមស្ការ ទើបព្រះបច្ចេកពុទ្ធមានព្រះពុទ្ធដីកាថា ម្នាលមហាបុរស

ដ៏ប្រសើរ ភព្វភាពនេះបានត្រាស់ដឹងបច្ចេកពោធិញ្ញាណ ឯអង្គអ្នកនេះមិនគឺអ្នកដទៃ គឺជាអង្គពុទ្ធង្កុរដែលនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលពិតប្រាកដមិនខានឡើយ ដូចម្តេចហើយក៏មកល្បងអំណាចបានដូច្នេះមិនគួរទេ សូម្បីតែព្រះបច្ចេកពុទ្ធមានព្រះពុទ្ធដីកាដូច្នោះ ព្រះតាបសក៏នៅតែប្រកាន់មានះថាខ្លួនប្រសើរជាងក៏មានវាចាទៅនឹងព្រះបច្ចេកពុទ្ធថា បើបើអ្នកប្រសើរជាងយើង ចូរអ្នកហោះទៅមើល ព្រះបច្ចេកពុទ្ធក៏ហោះទៅដោយអាកាស ហាក់ដូចជាឱឡឹកពេយយន្តក្លួន ព្រាបាទលើផងផ្ចិតសក់នៃព្រះតាបស ហើយក៏ហោះឆ្ពោះទៅកាន់ភ្នំគន្ធមាទបព៌ត ឯព្រះតាបសបានឃើញអានុភាពព្រះបច្ចេកពុទ្ធដូច្នោះក៏ចង្អើតចម្ងល់ស្ងើចថា ព្រះសមណៈនេះមានគុណវិសេសប្រសើរណាស់ហើយ លោកអាចហោះទៅដោយអាកាសបើនដូចជាសំឡីត្រូវខ្យល់ ឯអាត្មាអញមកកាន់មានះរឹងរូសយ៉ាងនេះទើងជាប្រយោជន៍អ្វី គិតដូច្នោះហើយក៏ព្យាយាមសង្កត់សង្កិនមានះមិនឲ្យកើតឡើងបាន ក៏តាំងពិតសំណាក់នាឲ្យបង្កើតអភិញ្ញាសមាបត្តិហើយចេញមកអង្គុយលើផែនថ្មសិលាក្នុងទីបំផុតនៃទីចង្ក្រមនោះៗ ឯសត្វព្រាបក៏តាំងព្យាយាមបំបាត់រាគៈ ពស់ក៏ព្យាយាមបំបាត់ទោស សត្វចចកក៏ព្យាយាមបំបាត់លោភៈ ខ្លាឃ្មុំក៏ព្យាយាមបំបាត់មោហៈ សេចក្តីព្យាយាមទាំង៤នេះក៏ឈ្មោះថា សម្មាវាយាមៈជាលោកិយមគ្គ កើតដោយអាការៈនៃកុសលចិត្ត ។

ព្យាយាមដែលនឹងញ៉ាំងកុសលធម៌ ដែលមិនទាន់កើតឡើងឲ្យកើតមានឡើងនោះ ដូចនិទានមានក្នុងព្រះធម្មបទថា មានព្រាហ្មណ៍ម្នាក់បានឃើញព្រះភិក្ខុសង្ឃ រៀបចេញទៅបិណ្ឌបាតឈរឃុំចីវរ នៅក្នុងស្ថានមួយ

ជាយចីវរត្រូវលើទឹកសន្សើមដែលធ្លាក់នៅលើស្មៅ ជាយចីវរក៏ទទឹកជោក ទៅដោយទឹកសន្សើមដូច្នោះហើយ ព្រាហ្មណ៍នោះបង្កើតកាមាវចរកុសលចិត្តផុលផុះផុះឡើងក៏គិតថាកក្នាទីដំរះស្មៅក្នុងទីនេះ គិតដូច្នោះហើយក៏កាន់ចបទៅដំរះទីនោះរលស្អាត ប្រាសចាកស្មៅនូវមន្ទិលទាំងពួង ថ្ងៃមួយឯក្រោយព្រាហ្មណ៍ឃើញជាយចីវរព្រះភិក្ខុសង្ឃប្រឡាក់ដោយផង់ធូលីដីក្នុងទីនោះ ព្រាហ្មណ៍ក៏យកដីខ្សាច់មកចាក់កោយកាយស្អាតល្អ ថ្ងៃឯក្រោយទៀតព្រាហ្មណ៍ឃើញព្រះភិក្ខុសង្ឃឈរឃ្លុំចីវរនៅទីនោះត្រូវកំដៅព្រះអាទិត្យមានសរីរកាយប្រែកប់ទៅដោយញើស ព្រាហ្មណ៍ក៏ធ្វើជាមណ្ឌបបាំងទីនោះឲ្យគត់ថ្ងៃ ថ្ងៃមួយឯក្រោយទៀតព្រាហ្មណ៍ឃើញព្រះភិក្ខុសង្ឃឃ្លុំចីវរនៅទីនោះមានភ្លៀងរលាព្រឹកព្រហាមទទឹកចីវរព្រះភិក្ខុសង្ឃ ព្រាហ្មណ៍ក៏ធ្វើសាលាឲ្យជាទីការពារកំដៅថ្ងៃនិងទឹកភ្លៀងជាទីមាំមួន ព្រះភិក្ខុសង្ឃក៏បានសេចក្ដីស្រួលក្នុងទីនោះ ព្រាហ្មណ៍រៀបនឹងឆ្លងសាលាក៏និមន្តព្រះសាស្ដាព្រមទាំងព្រះភិក្ខុសង្ឃមកធ្វើភត្តកិច្ចឆាន់នៅសាលានោះ ហើយព្រាហ្មណ៍ក៏ក្រាបទូលហេតុគ្រប់ប្រការ សម្ដេចព្រះសាស្ដាក៏ទ្រង់ទេសនាជាបទព្រះគាថាដូច្នេះ

អនុបុព្វេន មេធាវី ថោកំ បុញ្ញំ ខណោ ខណោ
កម្មារោ រជតស្សេវ និទ្ធមេ មលមត្តនោ

អធិប្បាយថា ជាងមាសដែលនឹងលាងមាសដុតលាងតែម្ដងក៏មិនអា- ចនឹងផុតមន្ទិលមាសនោះឲ្យអស់បាន លុះតែដុតដំរឿយ ៗ ជាច្រើនដង

ទើបមិនអស់មន្ទិលមាសនោះបាន ការចង់ធ្វើជាគ្រឿងអលង្ការផ្សេងៗបាន

នេះមានទទួលបានម្ដងម្ដងម៉្យាង បុគ្គលជាអ្នកប្រាជ្ញការពារមិនប្រាជ្ញពិចារណា

ឲ្យឥតមិនមន្ទិលមានលោភមច្ឆរិយជាដើមដែលកើតមាននឹងសន្តានចិត្ត ជំរះម្ដង

បន្តិចៗ ឬនឹងកាសនោះៗដោយលំដាប់ៗ គឺធ្វើឲ្យប្រាសចាកមន្ទិល ទាំងពួង

មានទទួលមេឃ្យផ្សេងៗ៉ាង ព្រាហ្មណ៍បានស្ដាប់ព្រះធម៌ទេសនាក៏បានសម្រេច

សោតាបត្តិផល ជាអរិយបុគ្គល ឬនឹងព្រះពុទ្ធសាសនា ព្រាហ្មណ៍ក៏ខំ

ព្យាយាមធ្វើការកុសលទាំងពួង យ៉ាងនេះឈ្មោះថាសម្មាវាយាមោ ជា

លោកិយមគ្គកើតដោយកម្លាំងកុសលចិត្តនោះ កាលបើព្រាហ្មណ៍បាន

សម្រេចព្រះសោតាហើយ សម្មាវាយាមោនោះលោកុត្តរៈក៏កើតព្រមដោយ

សោតាបត្តិមគ្គចិត្ត ។

ព្យាយាមញ៉ាំងកុសលធម៌ដែលកើតឡើងហើយកុំឲ្យវិនាសសូន្យទៅវិញ

ឲ្យរីកតែចំរើនឡើងទៀតនោះ គឺមាននិទានដូចបុរសក ៥០០ នាក់ បបួល

គ្នារក្សាសីល ៥ ប្រការ...... ហើយប្រាថ្នាចង់ឲ្យសីលនោះចំរើនឡើង ម៉

សមាទានសីល ៨ ហើយសមាទានសីល ១០ ហើយបួសជាសាមណេរ

ប្រតិបត្តិអធិសមាបត្តិ ហើយឧបសម្បទជាភិក្ខុទំនងចែងនឹងចតុបារិសុទ្ធសីល

ឯព្យាយាមយ៉ាងនេះឈ្មោះថា សម្មាវាយាមោ ជាលោកិយមគ្គកើតដោយ

កម្លាំងកុសលចិត្តនោះ ជាព្យាយាមញ៉ាំងកុសលដែលកើតឡើងកុំឲ្យ

វិនាសបាត់ទៅវិញ ឲ្យរីងរីកតែចំរើនឡើងទៀត។ ។

អង្គនៃព្រះអរិយមគ្គជាគំរប់ ៧ គឺ សម្មាសតិនោះ បានខាងឯសតិ

ដែលប្រកបដោយអារម្មណ៍ ៤ ប្រការ គឺតាំងសតិយកសរីរកាយជាអា-

ម្មណ៍ ហើយចំរើនសមថវិបស្សនានោះ ១ គឺតាំងដំកល់សតិយកវេទនា
ជាអារម្មណ៍ ហើយចំរើនសមថវិបស្សនានោះ ១ គឺតាំងដំកល់សតិយក
ចិត្តជាអារម្មណ៍ ហើយចំរើនសមថវិបស្សនានោះ១ គឺតាំងដំកល់សតិយក
ធម៌គឺសញ្ញាចេតសិកនិងសំខារចេតសិកជាអារម្មណ៍ ហើយចំរើនសមថ
វិបស្សនានោះ ១ សតិដ៏មានអារម្មណ៍ ៤ ប្រការដូច្នេះ មានលក្ខណ ២
ប្រការ គឺអបិលាបនលក្ខណាសតិ ១ ឧបគ្គហណលក្ខណាសតិ ១ អបិ-
លាបនលក្ខណាសតិនោះ ញុំាងព្រះយោគាវចរកុលបុត្រឲ្យចេះចាំកុសល
ធម៌ទុកយប់ព្រឹកកាលវេលាមិនឲ្យភ្លេចកុសលធម៌នោះ មានឧបមាដូចភណ្ឌា-
គារិក គឺនាយឃ្លាំង របស់សម្ដេចព្រះបរមចក្រពត្រាធិរាជ ចាំយបញ្ជី
ព្រឹកល្ងាចកាលវេលាជានិច្ចនិរន្តរជា ថាមានប៉ុណ្ណេះសេះដំរីរថពលនិកាយ
មានប៉ុណ្ណេះៗ ជាដើម យ៉ាងនេះមានឧបមាដូចម្ដេច- អបិលាបនលក្ខណា
សតិនោះ គឺញុំាងព្រះយោគាវចរឲ្យរឭកដល់គុណកុសលធម៌ដូច្នេះថា
ឥមេចត្តារោសតិបដ្ឋានា ធម៌ទាំងឡាយ ៤ ប្រការនេះឈ្មោះសតិ-
បដ្ឋាន ឥមេចត្តារោសម្មប្បធានា ធម៌ទាំងឡាយ ៤ ប្រការនេះ
ឈ្មោះសម្មប្បធាន ឥមេចត្តារោឥទ្ធិបាទា ធម៌ទាំងឡាយ ៤ ប្រការ
នេះឈ្មោះឥទ្ធិបាទ ធម៌ទាំងឡាយ ៥ ប្រការនេះឈ្មោះឥន្ទ្រិយ ធម៌ទាំង-
ឡាយ ៥ ប្រការនេះឈ្មោះពល ធម៌ទាំងឡាយ ៧ ប្រការនេះឈ្មោះ
ពោជ្ឈង្គ ធម៌ទាំងឡាយ ៨ ប្រការនេះឈ្មោះអរិយមគ្គមានអង្គ ៨ ប្រការ
ធម៌ទាំងឡាយពួកនេះឈ្មោះសមថ ធម៌ទាំងឡាយពួកនេះឈ្មោះវិបស្សនា
ធម៌ទាំងឡាយពួកនេះឈ្មោះសច្ច ធម៌ទាំងឡាយពួកនេះឈ្មោះវិមុត្តិ ធម៌

តាំងឡាយពួកនេះជាលោកុត្តរ  ឧបដ្ឋានលក្ខណា សតិនោះ  មានឧប-
មេយ្យដូចជានាយឃ្លាំងនៃស្តេចបរមចក្រពត្រាធិរាជដូច្នោះឯង  ឯឧបរិគ-
ហណលក្ខណា សតិនោះ មានឧបមាដូចបរិនាយកមន្ត្រីរតន៍ស្តេចបរមច-
ក្រពត្តិរាជដឹងពិចារណាមើលនូវពពួកជនទាំងពួង ដឹងថាជនទាំងឡាយនេះ
មិនធ្វើនូវអំពើជាប្រយោជន៍ដល់ព្រះមហាក្សត្រ គឺញ៉ាំងជនទាំងឡាយនោះ
ឲ្យចៀសចេញទៅ  ជនទាំងឡាយឯណា ធ្វើនូវអំពើជាប្រយោជន៍ដល់ព្រះ
មហាក្សត្រ គឺញ៉ាំងជនទាំងឡាយនោះឲ្យចូលទៅជិតព្រះមហាក្សត្រ នេះ
មានឧបមាដូចម្តេច  ឧបរិគ្គហណលក្ខណា សតិនោះគឺស្វែងរកគតិនៃធម៌
ទាំងឡាយថា  ធម៌ទាំងឡាយមានកាយទុច្ចរិតជាដើមមិនប្រយោជន៍គ្មាន
គឺបន្ទោបង់ចោល  ធម៌ទាំងឡាយមានកាយសុចរិតជាដើម  ជាប្រយោជន៍
ហើយគឺកាន់យក  គឺមានឧបមេយ្យដូចបរិនាយកមន្ត្រីរតន៍នៃព្រះមហា-
ក្សត្រិបរមចក្រពត្តិរាជ  នេះជាអង្គនៃព្រះអរិយមគ្គជាគំរប់ ៧ ប្រការ ។

អង្គនៃព្រះអរិយមគ្គជាគំរប់ ៨  គឺសម្មាសមាធិនោះមានលក្ខណា ២
ប្រការគឺបាមោក្ខលក្ខណា ១ អវិក្ខេបនលក្ខណា ១  បាមោក្ខលក្ខណាសមាធិ
នោះជាប្រធានដល់កុសលធម៌ទាំងឡាយ  ឧបមាដូចកំពូលកូដាគារប្រា-
សាទ  ជាប្រធានដល់បន្ទំទាំងឡាយ  ហេតុដូច្នោះព្រះនាគសេនថេរ
លោកឧបមាថ្វាយសម្តេចព្រះមិលិន្ទាធិរាជថា បពិត្រព្រះរាជសម្ភារ បន្ទំ
ទាំងឡាយនៃកូដាគារប្រាសាទទាំងប៉ុន្មាន  មានកំពូលជាប្រធាន  កំពូល
ជាទីប្រជុំនៃបន្ទំទាំងឡាយ  កំពូលប្រសើរលើសជាងបន្ទំទាំងឡាយ
នោះមានឧបមាដូចម្តេច កុសលធម៌ទាំងឡាយទាំងប៉ុន្មាននោះ គឺឧនញោច

ចុះទៅក្នុងសម្មាសមាធិទាំងអស់ សម្មាសមាធិនេះជាទីប្រជុំនៃកុសលធម៌ទាំងឡាយ មានឧបមេយ្យដូច្នោះ ។

អវិក្ខេបនលក្ខណសមាធិនោះ មានសភាវញុំាងធម៌ទាំងឡាយឲ្យកើតដោយសម្មាសមាធិនោះ មិនឲ្យរាយមាយខ្ចាត់ខ្ចាយដោយឧទ្ធច្ចៈហើយឲ្យដំកល់មាំទាំងនៅក្នុងអារម្មណ៍តែ ១ ហេតុដូច្នោះទើបលោកឧបមាយ៉ាងនេះ ធម្មតាព្រះមហាក្សត្រចូលកាន់សង្គ្រាមយុទ្ធ គឺងតមើលសេនាយោធាទាំងពួង បើឃើញសេនាក្នុងទីស្ថានឯណាអន់ថយកំលាំង ស្តេចក៏យាងទៅត្រង់ស្ថានទីនោះញុំាងសេនាយោធាឲ្យបរិបូណ៌ ហើយញុំាងសេនាយោធាបច្ចាមិត្តឲ្យអបរាជ័យពាលពាញបែកខ្ចាត់ខ្ចាយទៅ នេះមានឧបមាដូចម្តេច សម្មាសមាធិដែលឈ្មោះថាអវិក្ខេបនលក្ខណសមាធិ ព្រោះថាសម្មាសមាធិនោះមិនឲ្យកុសលធម៌ទាំងឡាយដែលកើតឡើងហើយរាយរាយខ្ចាត់ខ្ចាយទៅដោយឧទ្ធច្ច ឲ្យគ្រប់សង្កត់បំបាត់បង់នូវឧទ្ធច្ចមិនឲ្យឧទ្ធច្ចកើតឡើងបាន ហើយឲ្យដំកល់នៅក្នុងអារម្មណ៍តែ ១ តាមអំណាចនៃសម្មាសមាធិ មានឧបមេយ្យដូចជាព្រះមហាក្សត្រនោះ សម្មាសមាធិនោះមានប្រការ ១ ដោយអំណាចនៃសភាវមិនបានរាយមាយទៅ សម្មាសមាធិនោះមានប្រការ ២ ដោយអំណាចនៃឧបចារសមាធិនឹងអប្បនាសមាធិ សម្មាសមាធិ មានប្រការ ៣ ដោយអំណាចនៃហីនសម្មាសមាធិនឹងមជ្ឈិមសម្មាសមាធិនឹងបណីតសម្មាសមាធិ សម្មាសមាធិមានប្រការ ៤ ដោយអំណាចនៃទុក្ខាបដិបទាទន្ធាភិញ្ញា ១ ទុក្ខាបដិបទាខិប្បាភិញ្ញា ១ សុខាបដិបទាទន្ធាភិញ្ញា ១ សុខាបដិបទាខិប្បាភិញ្ញា ១ សម្មាសមាធិមានប្រការ ៥

ដោយអំណាចនៃបឋមជ្ឈានសមាធិ ១ ទុតិយជ្ឈានសមាធិ ១ តតិយជ្ឈានសមាធិ ១ ចតុត្ថជ្ឈានសមាធិ ១ បញ្ចមជ្ឈានសមាធិ ១ ប្រភេទនៃសមាធិមាន ៥ ប្រការ ដោយប្រការដូច្នេះ អង្គនៃព្រះអរិយមគ្គជាគំរប់ ៨ ចប់តែប៉ុណ្ណេះ ។

សម្តេចព្រះសព៌េជ្ញសព្វញ្ញូទ្រង់ព្រះមហាករុណាត្រាស់ទេសនាព្រះធម្មចក្កប្បវត្តនសូត្រនោះ គឺសម្តែងពោធិបក្ខិយធម៌និងបដិច្ចសមុប្បាទធម៌ និងចតុរារិយសច្ចធម៌ ទាំងអស់នេះដ៏ជ្រៅជ្រាលក្រៃលែងគ្នា មានទេសនាដូចជាផ្ទៀងនឹងទំនោរទេវតានិងនាគទាំងទេវ យ៉ាងនេះឈ្មោះថាធម្មចក្រ ប្រការ ១ ទៀតព្រះធម្មចក្រនោះមាន ២ ប្រការ គឺបដិវេធញាណធម្មចក្រប្រការ ១ ទេសនាញាណធម្មចក្រប្រការ ១ ត្រូវជា ២ ប្រការដូច្នេះ បដិវេធញាណធម្មចក្រនោះ បានខាងឯញាណដ៏ត្រាស់ដឹងនូវព្រះចតុរារិយសច្ច មានបរិវដ្ដ ៣ មានអាការ ១២ សម្លាប់នូវសត្រូវគឺកិលេសជាសមុច្ឆេទប្រហាន ដាច់ចេញស្រឡះអំពីសន្តាន ហើយនាំមកនូវអរិយផល កាលដែលព្រះអង្គគង់លើអបរាជិតបល្ល័ង្កក្រោមដើមមហាពោធិព្រឹក្ស ឯទេសនាញាណធម្មចក្រនោះ បានខាងព្រះញាណដ៏អប់រំដោយព្រះមហាករុណាទិគុណ ព្រះអង្គទេសនាព្រះចតុរារិយសច្ច មានបរិវដ្ដ ៣ មានអាការ ១២ ញ៉ាំងសាវកទាំងឡាយមានព្រះអញ្ញាកោណ្ឌញ្ញត្ថេរជាប្រធាន ឲ្យបានសម្រេចព្រះអរិយមគ្គអរិយផល កាត់កិលេសជាសមុច្ឆេទប្រហាន ឯព្រះធម្មចក្រទាំង ២ ប្រការមានន័យដូចបានពណ៌នាមកដូច្នេះ ប្រាជ្ញនឹងលើកឡើងសម្តែងក្នុងទីនេះ តែទេសនាញាណធម្មចក្រដែលមានបរិវដ្ដ ៣ មាន

អាការ ១២ នោះដូចម្ដេច ៗ មានពាក្យវិសជ្ជនាថា បរិវដ្ដ ៣ ប្រការនោះ បានខាងឯបញ្ញា ៣ ប្រការ គឺសច្ចញាណប្រការ ១ កិច្ចញាណប្រការ ១ កតញាណប្រការ ១ សច្ចញាណនោះ គឺប្រាជ្ញាត្រាស់ដឹងនូវព្រះចតុរ-អរិយសច្ចៈដោយព្រះអង្គឯង ឥតបុគ្គលឯណាមួយជាគ្រូជាអាចារ្យព្រះអង្គគ្មាន កិច្ចញាណនោះគឺប្រាជ្ញាដឹងកិច្ចៈរបស់ហេតុនៅក្នុងចតុសច្ចកិច្ច ត្រាស់ដឹងជាក់ច្បាស់ថា ទុក្ខំ បរិញ្ញេយ្យំ ទុក្ខសច្ចនេះសមគួរព្រះអរិយបុគ្គលគប្បីនឹងកំណត់កត់សំគាល់យកជាអារម្មណ៍ ទុក្ខសមុទយោ បហា-តព្វោ ទុក្ខសមុទយអរិយសច្ចនេះសមគួរព្រះអរិយបុគ្គលគប្បីនឹងលះបង់ចេញ ទុក្ខនិរោធោ សច្ឆិកាតព្វោ ទុក្ខនិរោធសច្ចគឺព្រះនិព្វាននោះសមគួរព្រះអរិយបុគ្គលគប្បីនឹងធ្វើឲ្យជាក់ច្បាស់ក្នុងខន្ធសន្ដាន ទុក្ខ-និរោធគាមិនីបដិបទា ភាវេតព្វា មគ្គសច្ចដែលជាផ្លូវប្រតិបត្តិឲ្យដល់នូវទីរលត់ទុក្ខគឺព្រះនិព្វាននោះសមគួរព្រះអរិយបុគ្គលគប្បីនឹងចំរើនក្នុងខន្ធសន្ដានព្រះប្រាជ្ញាដែលត្រាស់ដឹងក្នុងកិច្ចដែលគប្បីនឹងធ្វើក្នុងព្រះចតុរារិយ-សច្ចទាំង ៤ ប្រការដូចបានពណ៌នាមកនេះ កតញាណនោះគឺប្រាជ្ញាដឹងដឹងច្បាស់ក្នុងចតុសច្ចកិច្ចដ៏សម្រេចហើយ ១ ដឹងថា ទុក្ខំ បរិញ្ញាតំ ទុក្ខសច្ចនេះអាត្មាបានកំណត់យកជាអារម្មណ៍ហើយ ទុក្ខសមុទយោ បហីនោ សមុទយសច្ចគឺតណ្ហា អាត្មាក៏បានលះបង់ចេញដាច់ស្រឡះអំពីសន្ដានហើយ ទុក្ខនិរោធោ សច្ឆិកតោ ទុក្ខនិរោធសច្ចគឺព្រះនិព្វានធម៌នោះ អាត្មាក៏បានធ្វើឲ្យជាក់ច្បាស់ក្នុងសន្ដានហើយ ទុក្ខ-និរោធគាមិនីបដិបទា មគ្គសច្ចដែលជាផ្លូវប្រតិបត្តិឲ្យដល់នូវទីរលត់ទុក្ខ

នោះ គាត្មាក៏បានចំរើនបរិបូណ៌ហើយ ប្រាជ្ញាដែលដឹងជាក់ហើយច្បាស់ ដឹងប្រាកដហើយពិតកិច្ចក្នុងចតុរារិយសច្ចនោះ បានធ្វើហើយស្រេចគ្រប់ ប្រការដូចបានពណ៌នាមកនេះឈ្មោះថា កតញ្ញាណ ។

សច្ចញាណ ១ កិច្ចញាណ ១ កតញ្ញាណ ១ ទាំង ៣ ប្រការនេះ ឯងឹតាត់ជាបរិវដ្ដ ៣ ប្រការ ឯអាការ ១២ ប្រការនោះឲ្យតាំងអរិយសច្ចទាំង ៤ ចុះ ហើយទើបយកញាណទាំង ៣ គឺ សច្ចញាណ កិច្ចញាណ កតញ្ញាណ មកគុណនឹងមួយគ្នា បួន ៣ ដងត្រូវជាអាការ ១២ ប្រការ ព្រះប្រាជ្ញាដ៏ប្រកបដោយបរិវដ្ដ ៣ និងអាការ ១២ នេះឈ្មោះថាព្រះធម្មចក្រ ដោយអត្ថថា វិលបក់កំចាត់បង់នូវសត្រូវគឺកិលេស ដ៏មុតលើស លែងប្រសើរជាងវដ្ដីក្នុងសម្ដេចអមរិន្ទទេវរាជ ធម្មចក្រនេះមុតក្រៃលើងមុត រកអ្វីនឹងប្រៀបពុំបានឡើយ សម្ដេចព្រះបរមសាស្ដាព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងព្រះចតុរារិយសច្ច គឺព្រះធម្មចក្កប្បវត្តនសូត្រចប់ស្រេចកាលណា បញ្ចវគ្គិយភិក្ខុទាំង ៥ អង្គមានព្រះអញ្ញាកោណ្ឌញ្ញជាដើម និងពួកព្រហ្មទាំង ១៨ កោដិក៏បានសម្រេចមគ្គផលទាំងអស់ សម្ដែងមកក្នុងសច្ចទាំង ៤ ប្រការក៏ចប់បរិបូណ៌តែប៉ុណ្ណោះហោង ។៚

# បញ្ជីសៀវភៅដែលព្រះរាជបណ្ណាល័យបោះពុម្ពផ្សាយ

| | | |
|---|---|---|
| ព្រះត្រៃបិដក (បាលីនិងប្រែ) ១ ចប់ ....... | ចំនួន ១០០ សៀវភៅថ្លៃ | ៤៩០១, ០០ |
| ព្រះចង្កូមកែវ ........................ | ១ សៀវភៅថ្លៃ | ០១, ១០ |
| អដ្ឋទោសកថា ........................ | — | ១, ០៥ |
| អនត្តលក្ខណសូត្រ ........................ | — | ១, ៣០ |
| អភិធម្មត្ថសង្គហ បាលី ........................ | — | ០, ៩១ |
| អភិធម្មត្ថសង្គហ សម្រាយ ........................ | — | ០, ៧០. |
| អរិយសច្ចកថា ........................ | — | ១, ៥០ |
| អំពីព្រះពុទ្ធសាសនា ........................ | — | ១, ៥០ |
| អំពីប្រាសាទទ្វះនៅនគរ ........................ | — | ០, ២៥ |
| កាលាមសូត្រនិងបរាភវសូត្រ ........................ | — | ១, ១៥ |
| គិរិមានន្ទសូត្រ ........................ | — | ០, ១៥ |
| ច្បាប់ថ្មី ........................ | — | ១, ១៥ |
| ញាណកថា ........................ | — | ០, ១០ |
| ដំណាលពុទ្ធចេតិយ ........................ | — | ០, ៨០ |
| ធម្មប្បទីប ........................ | — | ០, ៤០ |
| កាណាភរ ........................ | — | ១, ៥០ |
| នាគោធមាទិកថា ........................ | — | ០, ០៧ |
| បករណវិសេសោ ........................ | — | ៩, ០០ |
| បាយាសិរាជញ្ញសូត្រ ........................ | — | ០, ០៧ |
| ពាក្យកាព្យក្រមង៉ុយ ........................ | — | ១, ០៣ |
| ឧនោបុត្តកថា ........................ | — | ០, ១៥ |
| មរណានុស្សតិ ........................ | — | ០, ២០ |
| មាតាបិតុបដ្ឋានកថា ........................ | — | ០, ៣៥ |

| | | |
|---|---|---|
| ១០០ គាថា | ១ សៀវភៅថ្លៃ | ០រ, ១០ |
| វិជ្ជាចរណកថា | — | ០, ៣០ |
| វុត្តោទយ | — | ០, ២៧ |
| សប្បុរិសធម៌ | — | ០, ០៥ |
| សត្តបរិត្តនិងទ្វាទសបរិត្ត | — | ០, ៥០ |
| សីមាវិនិច្ឆ័យ | — | ០, ១០ |
| សុរិយាត្រទៀងស័ក | — | ០, ៣០ |
| សុភាសិតច្បាកាសិន | — | ០, ៦០ |
| សេចក្តីដាស់តឿន | — | ០, ០៦ |
| បច្ចតណាធាវិធី និងប័ក្ខសម្រេច | — | ០, ៣០ |
| សម្ពន្ធមាលា | — | ១, ២៧ |
| សីលនិទ្ទេស | — | ០, ៥០ |
| សារទេសនា | — | ០, ០៨ |
| ពាក្យខ្មែរជាប់និងរូបសព្ទ | — | ០, ២០ |
| ប្រស្នាវិនយបិដកសង្ខេប | — | ១, ០០ |
| រតនប្បកា | — | ០, ៦០ |
| វិធីបង្ការរោគ | — | ០, ០៣ |
| ឧភតោបាតិមោក្ខ | — | ០, ៧០ |
| គោលសមថកម្មដ្ឋាន | — | ០, ១៥ |
| ពុទ្ធមាមកវិធី (បែបធម្មយុត្តិ) | — | ០, ៦០ |
| សាមណេរវិន័យ | — | ០, ៦០ |
| បញ្ចកភិក្ខុប្បច្ចវេក្ខណៈ | — | ០, ១០ |
| សិក្ខាលោភទសូត្រ | — | ០, ៣០ |
| អនុមោទនាវិធី | — | ០, ៥០ |
| ត្រៃត្រៃលក្ខណ៍ និងសង្កេតវត្ថុ | — | ០, ១០ |

| | | | |
|---|---|---|---|
| ពាក្យកាព្យថ្លែងរឿងពុទ្ធប្រវត្តិ . . . . . . . . . . . . . . . . | ១ សៀវភៅថ្លៃ | | ០៛, ១៨ |
| វែសលស្សូត្រ . . . . . . . . . . . . . . . . . . . . . . | | — | ០, ១៨ |
| នានាជាតក . . . . . . . . . . . . . . . . . . . . . . | | — | ១, ៦០ |
| សតិបដ្ឋានសូត្រ . . . . . . . . . . . . . . . . . . . . . . | | — | ០, ៨០ |
| អវសានកិច្ច . . . . . . . . . . . . . . . . . . . . . . | | — | ០, ៤៨ |
| វិជ្ជាប្រាំបីប្រការ . . . . . . . . . . . . . . . . . . . . . . | | — | ០, ៦៨ |
| រឿងកាកី . . . . . . . . . . . . . . . . . . . . . . | | — | ០, ២៨ |
| ទសបារមីកថា . . . . . . . . . . . . . . . . . . . . . . | | — | ០, ៣៨ |
| បាដិមោក្ខសង្ខេប . . . . . . . . . . . . . . . . . . . . . . | | — | ០, ៤០ |
| សៀវភៅយានជំនិះខ្មែរ . . . . . . . . . . . . . . . . . . . . . . | | — | ០, ៤៨ |
| វេរសារ . . . . . . . . . . . . . . . . . . . . . . | | — | ០, ៦១ |
| ទានកថា . . . . . . . . . . . . . . . . . . . . . . | | — | ០, ៦០ |
| វេយ្យាករណ៍សំស្ក្រឹត . . . . . . . . . . . . . . . . . . . . . . | | — | ០, ៦៤ |
| សិលាចារឹកនគរវត្ត . . . . . . . . . . . . . . . . . . . . . . | | — | ១, ០១ |
| ជ័យវរ្ម័ន ទី ៧ (ភាសាខ្មែរ) . . . . . . . . . . . . . . . . . . . | | — | ០, ៩០ |
| " " (ភាសាបារាំង) . . . . . . . . . . . . . . . . | | — | ០, ៣១ |
| បទានុក្រមកមកេរ្តិ៍ . . . . . . . . . . . . . . . . . . . . | | — | ០, ០៨ |
| កមកេរ្តិ៍ លក់រាយ . . . . . . . . . . . . . . . . . . . . | | — | ០, ១០ |
| " លក់ដុំ . . . . . . . . . . . . . . . . . . . . | ១៧ | — | ១, ៨០ |
| ទស្សនាវដ្តី (១ ឆ្នាំ) . . . . . . . . . . . . . . . . . . . . | ២៤ | — | ៦, ៨០ |
| សាសនកិច្ចានុក្រម (១ ឆ្នាំ) . . . . . . . . . . . . . . . . . . | ១២ | — | ១, ៨០ |
| វចនានុក្រមខ្មែរ ក្របរឹង . . . . . . . . . . . . . . . . . . | ១ | — | ៩, ៨០ |
| " ក្របទន់ . . . . . . . . . . . . . . . . . . | | — | ៧, ០០ |
| គិហិបដិបត្តិសង្ខេប . . . . . . . . . . . . . . . . . . . . . . | | — | ០, ១៥ |
| គិហិបដិបត្តិពិស្តារ . . . . . . . . . . . . . . . . . . . . . . | | — | ០, ៨០ |

| | | | |
|---|---|---|---|
| បុប្ផាទន្ទកសង្វៀប | ........................ | ១ សៀវភៅថ្លៃ | ០, ៩៥ |
| សុភាទោសកថា | ........................ | — | ០, ១០ |
| ខត្តុទ្វេសក់ខតរ | ភាគទី ១ .................. | — | ០, ៤៩ |
| " | ភាគទី ២ .................. | — | ១, ០០ |
| ក្រុងសុភមិត្រ | ភាគទី ១ .................. | — | ០, ០០ |
| " | ភាគទី ២ .................. | — | ០, ០០ |
| " | ភាគទី ៣ .................. | — | ០, ០០ |
| មិលិន្ទបញ្ហា | ភាគទី ១ .................. | — | ០, ៥០ |
| " | ភាគទី ២ .................. | — | ០, ៧០ |
| ខន្តិលត្តទីបនី | ភាគទី ១ .................. | — | ២, ០០ |
| " | ភាគទី ២ .................. | — | ២, ៥១ |
| " | ភាគទី ៣ .................. | — | ៣, ០០ |
| " | ភាគទី ៤ .................. | — | ០, ០០ |
| កច្ចាយនូបត្ថម្ភក | ភាគទី ១ .................. | — | ១, ២០ |
| " " | ភាគទី ២ .................. | — | ១, ៤០ |
| ធម្មបទដ្ឋកថា | ភាគទី ១ .................. | — | ០, ៩០ |
| " | តាំងពីភាគទី ២ ដល់ភាគទី ៨ .......... | — | ០, ៦៥ |
| គតិលោក | ភាគទី ១ .................. | — | ០, ១៥ក |
| " | ភាគទី ២-៣ .................. | — | ០, ១២ក |
| " | ភាគទី ៤-៥-៦-៧-៨-៩-១០ .......... | — | ០, ២៥ |
| រឿង ១ពាន់ ១យប់ | ភាគទី ១ .................. | — | ០, ០២ |
| " | ភាគទី ២-៣-៤-៥-៦-៧-៨-៩ ...... | — | ០, ២៥ |

# រូបផ្តិតពុម្ពផ្សេងៗ

| | | | |
|---|---|---|---|
| ព្រះពុទ្ធរូបមានអគ្គសាវកអម (របនាណោះ) . . . . . . . . . . . . | ១ សន្លឹកថ្លៃ | | ០, ១៥ |
| " សិញ្ជាន . . . . . . . . . . . . . . . . . . . . . | | — | ០, ១៥ |
| រូបបេសកម៍យប់ត្រៃគ្រប់បែប . . . . . . . . . . . . . . . . . | | — | ០, ១៥ |
| ព្រះពុទ្ធរូបបាយ័ន . . . . . . . . . . . . . . . . . . . . | | — | ០, ០២ |
| " មានព្រះឥន្ទ្រនិងព្រះព្រហ្មឈរអម . . . . . . . . . . | | — | ០, ១៥ |
| ព្រះរូបសម្តេចព្រះមហាសង្ឃរាជ (ទៀង) . . . . . . . . . . . | | — | ០, ១៣ |
| ព្រះរូបព្រះបាទសម្តេច ព្រះស៊ីសុវត្ថិមុនីវង្ស ក្រដាសរឹង . . . . | | — | ០, ១៥ |
| " " ក្រដាសទន់ . . . . . | | — | ០, ១០ |
| " ព្រះស៊ីសុវត្ថិ . . . . . . . . . . . | | — | ០, ២០ |
| " ព្រះនៅក្រុងកម្ពុជា ៤ ព្រះអង្គ . . . . . | | — | ០, ១០ |
| រូបព្រះពុទ្ធបាទ . . . . . . . . . . . . . . . . . . . . . . | | — | ០, ១៥ |
| រូបព្រះឥន្ទ្រហាសំពត់រឿងពុទ្ធប្រវត្តិ . . . . . . . . . . . . . | | — | ០, ១៥ |
| រូបវេស្សន្តរជាតក ១៣ សន្លឹក . . . . . . . . . . . . . . . . | | — | ០, ១៦ |
| រូបតំនូរតេមិយជាតក . . . . . . . . . . . . . . . . . . . | ១០ | — | ០, ២៥ |
| " មហាជនកជាតក . . . . . . . . . . . . . . . . . . | ១០ | — | ០, ២៥ |
| " សុវណ្ណសាមជាតក . . . . . . . . . . . . . . . . | ១០ | — | ០, ២៥ |
| រូបសម្តេចព្រះវររាជជននី . . . . . . . . . . . . . . . . . | ១ | — | ០, ១២ |
| រូបលោកសង្ឃស្រូចទឹកតាចាស់ . . . . . . . . . . . . . . . . | | — | ០, ១៥ |
| ប្រក្រតិទិនឆ្នាំថ្មី (សន្លឹកស្តើង) . . . . . . . . . . . . . . . | | — | ០, ១៥ |
| " " (បន្ទះក្រាស់) . . . . . . . . . . . . . . . . | | — | ០, ៣០ |
| " (បក) . . . . . . . . . . . . . . . . . . . . | | — | ០, ០០ |